00878214

E1/158.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 15-Jan-2013, 09:35
CMS/CFO: Uch Arun

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

**ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង**

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១០ ខែមករា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០៥នាទី**

**សវនាការលើកទី១៤៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)

*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ហ្វៃហ្សា ស៊ូអាគ្រី

*(Ms. Faiza ZOUAKRI)*

លោក រ៉ូជឺ ហ្វីលីព *(Mr. Roger Phillips)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ(*Mr.Victor KOPPE*)

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ទី ស្រ៊ុនណា

លោកស្រី បេនី យេ *(Ms. Beini YE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធារី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក វិុចទ័រ កូប៉េ | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក អាកទួរ វែកគែន | បារាំង |
| លោក អ៊ុង រ៉េន (TCW-754) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក អ៊ុំ រ៉ែន** (TCW-754)


សួរបន្តដោយលោក ឌេល លីសាក់ ផ្តើមពី ....................................ទំព័រ ៣
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ....................................ទំព័រ ២៣
សួរដោយលោក សុន អរុណ ផ្តើមពី ....................................ទំព័រ ២៨
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី....................................ទំព័រ ៣៨
សួរដោយលោក អាង ឧត្តម ផ្តើមពី....................................ទំព័រ ៤៥
សួរដោយលោក គង់ សំអុន ផ្តើមពី ....................................ទំព័រ ៦៥
សួរដោយលោក អាកទួរ វែកគែន ផ្តើមពី ....................................ទំព័រ ៦៩

# កិច្ចដំណើរការនីតិវិធី

*( ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៥:៤៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពអវត្តមាន វត្តមានភាគី និងបុគ្គល ដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃ គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះ មានវត្តមាន។ លើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ដោយមូលហេតុសុខភាព។ ហើយសាក្សីដែលត្រូវបន្តផ្ដល់សក្ខីកម្មនៅក្នុងថ្ងៃនេះ គឺលោក អ៊ុង រ៉ែន ហើយលោកមានវត្តមានរួចហើយ នៅក្នុងបន្ទប់សវនាការ។

នៅក្នុងសវនាការថ្ងៃនេះដែរ មិនមានសាក្សីបម្រុងនោះទេ ដោយសារតែសាក្សីមិនអាចធ្វើដំណើរមកចូលរួមដំណើរការសវនាការឲ្យបានទាន់ពេលវេលា។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ជាបន្ត អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ ហើយអង្គជំនុំជម្រះក៏សូមជម្រាបជូនផងដែរ តំណាងសហព្រះរាជអាជ្ញា រួមទាំងក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានពេលវេលាតែមួយពេលប៉ុណ្ណោះ បានន័យថាពីពេលនេះទៅរហូតដល់សម្រាក។ នៅព្រឹកនេះ គឺចប់ហើយ។

**លោក សុន អរុណ៖**

ខ្ញុំសូម--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន។ ដោយមានកំណត់ហេតុសុខភាព មុនពេលសវនាការសម្រាប់លោក នួន ជា។ ក្នុងនេះ ខាងវេជ្ជបណ្ឌិត តុង ហុង ដែលជាអ្នកប្រចាំការនៅថ្ងៃនេះ សូមឲ្យលោក នួន ជា ឡើងមកសវនាការ ស្ដាប់សវនាការនៅសាមសិប -- រវាង៣០នាទី រួចអនុញ្ញាតឲ្យគាត់ចុះមកបន្ទប់តាមដានខាងក្រោម។ គាត់បានឡើងខាងលើហើយ ប៉ុន្តែមកដល់ --ឡើងមកដល់លើ គាត់បានប្រាប់យើងខ្ញុំជាមេធាវីការពារគាត់ គាត់ថា មិនអាចអង្គុយបានតទៅទៀតទេ ក្បាលគាត់ធ្វើទុក្ខខ្លាំងណាស់ ហើយចង្អោះ។ ហ្នឹងជារឿងសំខាន់ ហើយគាត់មិនអាចអង្គុយបានយូរ ហើយស្ដាប់អីក៏មិនបានដែរ។ សូមលោក -- សូមតុលាការមេត្តាពិចារណា និងអនុញ្ញាតឲ្យគាត់ចុះទៅខាងក្រោមដើម្បីតាមដាននៅបន្ទប់ខាងក្រោម។ សូមអរគុណ។

[០៩:០៨:៣៥]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១១:៤១]

**ប្រធានអង្គជំនុំ៖**

បាទ នៅព្រឹកមិញនេះ អង្គជំនុំជម្រះបានទទួលរបាយការណ៍ពីលោកវេជ្ជបណ្ឌិតដែលប្រចាំការនៅ អ.វ.ត.ក ដែលបានពិនិត្យសុខភាពលោក នួន ជា មុនពេលសវនាការនេះ ហើយនិងបានកត់សម្គាល់ឃើញថា លោក នួន ជា មានបញ្ហាសុខភាព មានអាការៈហេវហត់ គួបផ្សំនឹងមានអាការៈវិលមុខផង។ ហើយលោកគ្រូពេទ្យបានផ្ដល់អនុសាសន៍ថា គប្បីឲ្យគាត់ចូលរួមនៅក្នុងកិច្ចដំណើរការសវនាការក្នុងរយៈពេលខ្លីប្រហែលជា៣០នាទី ហើយរួចគប្បីអនុញ្ញាតឲ្យគាត់ចុះទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ហើយនាពេលអម្បាញ់មិញនេះគឺលោក នួន ជា បានស្នើសុំជាបន្ទាន់ទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយដោយបញ្ហាសុខភាព ដែលមិនអាចចូលរួមសូម្បីតែរយៈពេលខ្លីក៏ដោយ។ ហើយសំណើសុំនេះគឺមានលក្ខណៈសមស្របទៅនឹងការកត់សម្គាល់ និងអនុសាសន៍របស់លោកគ្រូពេទ្យដែលប្រចាំការនៅ អ.វ.ត.ក ហើយបានពិនិត្យសុខភាពរបស់ជនជាប់ចោទ នួន ជា មុនពេលចូលមកក្នុងបន្ទប់សវនាការនេះ។ ហេតុដូច្នេះ -- ហើយគាត់អាចចូលរួមសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមបាន ហេតុដូច្នេះដើម្បីជៀសវាងការពន្យារពេលសវនាការ និងដើម្បីប្រយោជន៍យុត្តិធម៌ ដោយផ្អែកលើរបាយការណ៍របស់វេជ្ជបណ្ឌិតដែលបានពិនិត្យសុខភាពជនជាប់ចោទ និងសំណើ

សុំរបស់លោក នួន ជា អង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយថ្ងៃនេះ។

[០៩:១៣:៤៥]

ហើយអង្គជំនុំជម្រះបង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះអាចចូលរួម និងតាមដានកិច្ចដំណើរការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយដែលស្ថិតនៅក្រោមសាលសវនាការនេះសម្រាប់រយៈពេលនៃកិច្ចដំណើរការសវនាការពេញមួយថ្ងៃនេះ។

អនុរក្សមន្ទីរឃុំឃាំងនាំលោក នួន ជា ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោម ដែលរៀបចំឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួមនិងតាមដានកិច្ចដំណើរការពីចម្ងាយ។

នាំទៅចុះ!

[០៩:១៤:១០]

*(ជនជាប់ចោទចាកចេញពីបន្ទប់សវនាការ)*

[០៩:១៤:២២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក ខេល លីសាក់៖**

**ស៖** ជម្រាបសួរលោកសាក្សី! ខ្ញុំចង់សួរលោកសំណួរបន្តអំពីចម្លើយដែលលោកបានឆ្លើយទៅការសម្ភាសទី១ របស់ការិយាល័យរបស់សហចៅក្រមស៊ើបអង្កេតគឺ E3/402 ខ្មែរទំព័រ 00379449, អង់គ្លេស ERN 00381036, បារាំង ERN 00424050 នៅក្នុងឯកសារនោះ លោកបាននិយាយថា "មេបញ្ជាការ សារឿន តែងតែរៀបចំអង្គប្រជុំ ហើយបានប្រាប់ខ្ញុំអំពីខ្មាំង ដូចជា ស៊ី.អ៊ី.អា, កា.ហ្សេ.បេ ហើយនិងខ្មាំងយួនផងដែរ" ចប់សេចក្ដីដកស្រង់។ តើលោកអាចជម្រាបតុលាការបានទេ ថាតើការប្រជុំនោះនៅកន្លែងណា ដែល សារឿន ជាលេខាវរសេនាធំ និងកងពលនោះដែលនិយាយអំពីខ្មាំង

សេ.អ៊ី.អា, កា.ហ្សេ.បេ និងខ្មាំងយួននោះ គេប្រជុំនៅកន្លែងណា?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ គឺតាមពិតក្នុងកងពល៨០១ គឺមាន ស៊ូ សារឿន គាត់បានប្រជុំនៅវ៉ឺនសៃ ហើយនិយាយរួម គឺនិយាយអំពី កា.ហ្សេ.បេ ហើយនិងខ្មាំងយួន។ ហើយទី២ គឺថាសុំអង្គភាពនីមួយៗ គឺពិនិត្យតាមដាន និងសកម្មភាពឲ្យជាប់ ក្រែងលោមាននៅក្នុងអង្គភាពរបស់អង្គភាពមួយៗ។

[០៩:១៦:៣៩]

**ស៖** ខ្ញុំចង់បង្ហាញជូនលោកនូវឯកសារមួយ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមបញ្ជាក់ថាឯកសារ E3/1164 គឺជារបាយការណ៍ថ្ងៃទី២៥ វិច្ឆិកា ឆ្នាំ១៩៧៦ គឺមកពី រឿន ដែលជាលេខាកងពល៨០១ ហើយសូមអនុញ្ញាតដើម្បីបង្ហាញលើអេក្រង់ និងជូនទៅសាក្សីផងដែរលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាស់ពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** នៅក្នុងផ្នែកទី២ នៃរបាយការណ៍នេះ និយាយពីបញ្ហាហ្នឹង ទំព័រទី២ ដែលនិយាយអំពីការពិភាក្សារបស់ខ្មាំងនៅក្នុងកងពលដែលរាប់ទាំងខ្មាំងបង្កប់ និងរបាយការណ៍អំពីទទួលមកពីយុទ្ធជនដែលស្ថិតនៅក្នុងវរសេនាធំ៨៣។ ផ្នែកមួយដែលខ្ញុំចង់ផ្តោតអារម្មណ៍ឲ្យលោកសាក្សីពិនិត្យនោះគឺថា វិធានការនៅក្នុងផ្នែកទី៤ នៃរបាយការណ៍នេះ និយាយពីវិធានការ។ បាទ ជាពិសេស គឺបញ្ជីវិធានការ៥ដែលរកឃើញនៅក្នុងទំព័រខ្មែរគឺ 00052327 ហើយអង់គ្លេស ERN 00516711 ផ្នែកទី៤នៃរបាយការណ៍នេះ។

[០៩:១៨:៥១]

វិធានការអង្គការទី១ និយាយថា "ជនសង្ស័យថាខ្មាំងត្រូវចាប់ជាដាច់ខាត, ទី២ ចំពោះអ្នកដែលខ្មាំងឆ្លើយដាក់ត្រូវពិនិត្យឯកសារ ហើយស្នើចាប់ខ្លួនជាបណ្តោះអាសន្ន" ហើយបន្ទាប់មកចូលទៅដល់ចំណុចទី៥ ជាវិធានការនោះនិយាយថា សូមដកស្រង់ "អ្នកមាននិន្នាការពាក់ព័ន្ធផ្នែកនយោបាយ គឺដកជាបណ្តើរៗ ជារយៈដំបូងពិនិត្យចំពោះសមាសភាពនេះ សកម្មភាពល្អ ឬអាក្រក់ចំពោះបដិវត្តន៍។ អ្នក

ណាល្អទុកសិន អ្នកណាប្រឆាំងមិនសកម្មដកដាក់មួយដុំ"។ ហើយបន្ទាប់មកនិយាយថា សូមដកស្រង់ "សរុបមក បើអ្នកណាល្មើសវិន័យអប់រំមិនស្តាប់ បីបួនដងត្រូវចាប់ ឬដកចេញពីអង្គភាព"។ ចប់សេចក្តីដកស្រង់។ ហើយក៏សូមលោកមើលផងដែរនៅចុងបញ្ចប់នៃរបាយការណ៍នេះ សារឿន ជាលេខាកងពលបាននិយាយថា "នេះជារបាយការណ៍គណៈ៨០១ ទាក់ទងទៅនឹងសកម្មភាពខ្មាំង និងវិធានការដូចបានបញ្ជាក់ខាងលើ ហើយយើងសូមឲ្យអ៊ំបញ្ជាក់ពីយោបល់ ហើយយើងខ្ញុំរង់ចាំការណែនាំរបស់អង្គការ របស់បក្ស។ សូមអរគុណ"។ សំណួររបស់ខ្ញុំចំពោះលោកសាក្សីផ្អែកលើអ្វីដែលលោកបានដឹងនៅជាលេខាវរសេនាធំ៨២ នោះ តើមាន -- តើបញ្ហាដែលត្រូវបង្កើតឡើងជាវិធានការហ្នឹង តើកងពលជាអ្នកសម្រេច ឬក៏ត្រូវមានការឯកភាពពីមជ្ឈិមដើម្បីនឹងអនុវត្តនូវវិធានការទាំងអស់នេះប្រឆាំងនឹងអ្នកណាដែលជា -- ដែលគេចោទថា ជាខ្មាំងនោះ?

[០៩:២១:០៩]

**ឆ៖** បាទ ខ្ញុំសូមឆ្លើយនឹងសំណួរ។ តាមពិតសភាពការណ៍ដូចខ្ញុំបានជម្រាបពីខាងដើមហើយ គឺសភាពការណ៍រួមនៅមុខសញ្ញាកងពល៨០១ ហើយតាមពិតក្នុងរបាយការណ៍នេះ គឺចង់បញ្ជាក់តាមវរសេនាធំមួយៗ ហើយក្នុងរបាយការណ៍នេះបញ្ជាក់ថា ក្នុងវរសេនាធំ៨១ នូវសភាពការណ៍នៅសាលាខោម។ ដូច្នេះសភាពការណ៍នេះ គឺសម្រាប់អង្គភាព សម្រាប់ខ្ញុំវិញនៅអង្គភាព គឺអត់មាននៅជាប់នឹងនេះទេ ព្រោះអង្កាល់នុ៎ង ខ្ញុំនៅក្នុងវរសេនាធំ។ តាមពិត គឺខ្ញុំដឹង គ្រាន់តែដឹងមកប្រជុំអីថា អូ៎! ឥឡូវសភាពការណ៍នៅសាលាខោមអីវាអ៊ីចេះៗអី ដឹងអ៊ីចឹង ហើយដូច្នេះ វិធានការរបស់ ស៊ូ សារឿន ហ្នឹងធ្វើម៉េចគឺនៅខាងព្រំដែលលាវ ឬយកចិត្តទុកដាក់តាមដានសភាពការណ៍ខ្មាំង។ ហ្នឹងហើយ នេះគឺខ្ញុំចង់បញ្ជាក់ក្នុងសំណួរនេះទី១។

[០៩:២២:១៥]

ទី២ ចំពោះបញ្ហានេះក៏ខ្ញុំបានស្តាប់គាត់សរុបមតិឡើងវិញ ដូចក្នុងឯកសារនេះបានបញ្ជាក់នេះហើយ គឺអ្នកដែលមានសកម្មភាព។ ទី១ គឺក្នុងវរសេនាធំ ឬក៏វរសេនាតូចនីមួយៗពិនិត្យតាមដាន តើសកម្មភាពនេះយ៉ាងម៉េច? ហើយដោះស្រាយយ៉ាងម៉េច? ហើយតាមពិតយកចិត្តទុកដាក់អប់រំ បើអប់រំមិនបានរយៈទី១ ទី២ ហើយគឺវិធានការ។ វិធានការដូចក្នុងឯកសារនេះហើយ គឺមានតែចាប់ មានតែចងប៉ុណ្ណោះឯង។ តែសម្រាប់ផ្ទាល់ខ្លួនក្នុងអង្គភាពរបស់ខ្ញុំ ក្នុងរយៈពេលនោះមិនទាន់មានបញ្ហានេះទេ។ ដូច្នេះសភាពការណ៍ គឺថាសរុបមកវិញ គឺមាននៅតែសាលាខោមម្តុំអង្គភាព៨០១ វរសេនាធំ៨១ ទេ។

ខ្ញុំសូមជម្រាបប៉ុណ្ណឹង។

[០៩:២៣:៣០]

**សៈ** តើលោកដឹងដែរឬទេថា លេខាកងពល សារឿន មានអំណាចក្នុងការសម្រេចលើវិធានការផ្សេង ដោយខ្លួនឯងទេ? ឬក៏គាត់ត្រូវការ ការឯកភាពពីមជ្ឈិមដើម្បីដាក់វិធានការហ្នឹងឲ្យអនុវត្តបាន។ ចង់សួរលោកបែបនេះ?

**ឆៈ** បាទ ចំពោះបញ្ហាសំណួរនេះ ខ្ញុំឆ្លើយ អ៎! ខ្ញុំបញ្ជាក់ថា បញ្ហានេះគឺខ្ញុំក្តាប់វាមិនបានត្រង់ថា គាត់មានការណែនាំពីលើទៅក៏មិនដឹង ឬក៏គាត់សម្រេចត្រឹមតែម្នាក់ឯង។ តើបើសម្រេចជារួមនៅក្នុងកងពលលើបញ្ហាអីមួយៗ។ ដូច្នេះវរសេនាធំនីមួយៗត្រូវតែដឹងបញ្ហាដែលសម្រេចយ៉ាងម៉េចៗ គឺត្រូវតែដឹង ហើយបើរឿងអីដែលគាត់មិនឲ្យដឹង គឺខាងខ្ញុំអត់ដឹងទេ។ ឧបមាថា ឥឡូវផែនការពីខាងលើទៅរៀបចំកម្លាំងយ៉ាងម៉េចៗ ហើយអង្គភាពគេត្រៀមយ៉ាងម៉េចៗអីគាត់ទៅប្រជុំអីចឹងបានខ្ញុំដឹង។ ដូច្នេះបើឲ្យខ្ញុំដឹងថា ឥឡូវដោះស្រាយយ៉ាងម៉េចអីយ៉ាងម៉េច? គឺឯកភាពត្រឹមគាត់ ឬក៏ខាងលើបញ្ជា? ខ្ញុំក្តាប់វាអត់បានទេ។

**សៈ** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំចូលទៅដល់ផ្នែកមួយទៀត ឥឡូវនេះ ខ្ញុំចង់សួរលោកអំពីបញ្ហារយៈពេលដែលលោកស្ថិតនៅ -- ធ្វើការងារនៅសេនាធិការ។ នៅក្នុងចម្លើយរបស់លោកទៅសហចៅក្រមស៊ើបអង្កេតនោះ លោកនិយាយថា "លោកបានចាកចេញសៀមប៉ាង នៅខែកក្កដា ឆ្នាំ១៩៧៧ ហើយនៅខែសីហា ឆ្នាំ១៩៧៧ លោកបាន -- គេឲ្យលោកមកភ្នំពេញ"។ ហើយពីម្សិលមិញ នៅពេលដែលខ្ញុំបានបង្ហាញឯកសារទៅលោកអំពីហេតុការណ៍កើតនៅសៀមប៉ាង នៅមីនា ឆ្នាំ១៩៧៧ លោកបាន -- ប្រហែលជាចាកចេញសៀមប៉ាងរួចទៅហើយ។ លោកក៏បានប្រាប់តុលាការដែរម្សិលមិញថា "សោម គឺជាសមាជិកម្នាក់នៅក្នុងសេនាធិការ ដែលលោកបានឃើញធ្វើការ -- គាត់ធ្វើការនៅទីនោះ នៅពេលដែលលោកនៅសេនាធិការ"។ តើសេចក្តីសង្ខេបនេះ ត្រូវតាមអ្វីដែលលោកបានដឹងដែរឬទេ?

[០៩:២៦:១១]

**ឆៈ** បាទ ក្នុងសំណួរនេះ ដូចខ្ញុំបានបញ្ជាក់រួចមកហើយ គឺតាមពិត ខ្ញុំចេញពីសៀមប៉ាង គឺខែ៧ ៨៧ (ស៊ីក) ហើយខ្ញុំមកដល់នោះ គឺរដូវខែ៧ គឺរដូវនៅកំពុងតែស្ទូងដកហើយ ហើយក៏បានប្រហែលមិនដល់កន្លះខែទេ ខ្ញុំក៏ត្រូវមកភ្នំពេញវិញ មក១រៀន។

**ស៖** មូលហេតុដែលខ្ញុំសួរលោកនោះ គឺម្សិលមិញលោកនិយាយថា "សោម ជាសមាជិកម្នាក់នៃសេនាធិការ ដែលធ្វើការនៅមន្ទីរនោះ នៅពេលដែលលោកបានទៅទីនោះ"។ ប៉ុន្តែ ស-២១ គឺបញ្ជើៗ ស-២១ គឺ D108/26.86, ខ្មែរ 00009223, អង់គ្លេស ERN 00783461 និយាយ "កេត ចាន់ ឈ្មោះ សោម គឺជាសមាជិកនៃសេនាធិការ គឺមកដល់ ស-២១ គឺថ្ងៃទី១៤ ខែមីនា ឆ្នាំ១៩៧៧ ហើយក៏បានបង្ហាញថា គឺជាពេលដែលលោកនៅភ្នំពេញ ដែលលោកធ្វើការនៅសេនាធិការ ហើយប្រហែលជាលោកមកមុនខែមីនា ឆ្នាំ១៩៧៧"។ អ៊ីចឹង ខ្ញុំចង់សួរលោក ហើយនិងបង្ហាញលោកឯកសារមួយពីរ ដើម្បីរំឭកការចងចាំ ដើម្បីឲ្យដឹងថា តើការចងចាំរបស់លោកត្រូវ ឬក៏ខុស ដែលថាតាមពិត ឆ្នាំ១៩៧៦ ទេ នៅពេលដែលលោកមកភ្នំពេញ គឺចង់បញ្ជាក់បែបនេះ។

[០៩:២៨:០៧]

**លោក ឌេល លីសាក់៖**

លោកប្រធាន ឯកសារទី១ ដែលខ្ញុំសូមអនុញ្ញាតបង្ហាញជូនសាក្សីនោះ គឺឯកសារ E3/810 បាទ គឺ E3/810 គឺជារបាយការណ៍ -- កំណត់ហេតុថ្ងៃ១៩ ខែ៩ របស់លេខាភូមិភាគនោះ អ៊ំ! លេខាកងពលនោះ។ សូមអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ផ្នែកមួយនៃឯកសារដែលខ្ញុំចង់ឲ្យលោកចាប់អារម្មណ៍ពិនិត្យនោះ គឺនៅត្រង់ផ្នែកដែលសរសេរផ្ទាល់ដៃ បាទ ដែលនៅខាងលើ ខាងស្តាំដៃ នៅទំព័រទី១ បញ្ជើថែងបែងចែកនេះ គឺមានដូចខាងក្រោមនេះ "ទី១ គឺទៅ៨៩, ទៅ២ ទៅ៨១, ទី៣ ទៅ ណាត, ទី៤ ទៅ សោម, ទី៥ ទៅ រ៉ែន, ៨០១"។ យើងបានពិនិត្យឯកសារសេនាធិការទាំងអស់តាមលំដាប់លំដោយ នេះគឺជាឯកសារទី១ ដែលមានឈ្មោះរបស់លោកនៅឯកសារនេះ។

[០៩:២៩:៥៤]

លោកប្រធាន ដើម្បីកំណត់ត្រាតុលាការ ឯកសារនេះ គឺអាចនឹងជាកំណត់ហេតុនៃខែកញ្ញា ឆ្នាំ ១៩៧៧ គឺ E3/799 គឺកំណត់ហេតុនេះ គឺកំណត់ហេតុអង្គប្រជុំថ្ងៃទី១៦ ខែមីនា គឺ E3/822 ដែលបញ្ជើចែកឯកសារនេះគឺថាមានមនុស្សទី -- មានតែបួនទេដែលគេបានទៅជូនឯកសារនេះទៅ។ សំណួររបស់

ខ្ញុំជូនទៅសាក្សីគឺ មនុស្សដែលហៅថា រ៉ែន ៨០១ នេះ ដែលស្ថិតនៅក្នុងបញ្ជីដែលគេជូនឯកសារ E3/810 តើជារូបលោកផ្ទាល់ ឬអ្នកណា? អ៊ីចឹងតើធ្វើឱ្យលោកនឹកឃើញដែរឬទេ ដែលថាពេលដែលលោកមកសេនាធិការភ្នំពេញនោះគឺតាមពិតគឺខែកញ្ញា ឆ្នាំ១៩៧៦ នោះទេ មិនមែនឆ្នាំ១៩៧៧ តើលោកអាចនឹកឃើញដូចម្ដេចបានផ្អែកលើអ្វីដែលខ្ញុំជម្រាបជូននេះ?

**លោក អ៊ុំង រ៉ែន៖**

**ឆ៖** បាទ ខ្ញុំចង់ជម្រាបដែរថា តាមពិតគឺខ្ញុំចាំ គឺចេញពីសៀមប៉ាងមកគឺដឹងថា ខែ៧ ៧៧, ខែ៧។ ហើយមកដល់គឺថារយៈពេលស្នងដកនោះគឺបានប្រើខ្ញុំកន្លះខែ ឬក៏ជិត១ខែ ខ្ញុំក៏ត្រូវវត់មកភ្នំពេញវិញមក។ នេះគឺតាមខ្ញុំចាំ ខ្លួនខ្ញុំអ៊ីចឹង។

[០៩:៣១:៤៥]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ហើយ តើធ្វើម្ដេចបានជាលោកជឿជាក់ថាឆ្នាំ១៩៧៧ តែមិនមែន១៩៧៦ ដែលជារយៈពេលលោកមកភ្នំពេញនោះ? ម៉េចបានលោកជឿថាឆ្នាំនោះទៅវិញ?

**ឆ៖** បាទ ខ្ញុំកត់សម្គាល់ខ្លួនខ្ញុំគឺថាទី១ គឺ៧៦ ខ្ញុំធ្វើស្រែនៅសៀមប៉ាង ហើយ ៧៧ ក៏ខ្ញុំនៅធ្វើស្រែនៅសៀមប៉ាង ហើយដល់តែខែ៧ បានខ្ញុំមករ៉ុនសៃ អ៎នែ! ហ្នឹងមកហើយមកកន្លែងកងពលនៅរ៉ុនសៃ។

**ស៖** ខ្ញុំសូមបង្ហាញឯកសារមួយចំនួនទៀតទៅឱ្យលោកមើល បន្ទាប់ពីកាលបរិច្ឆេទខែកញ្ញា ៧៦ គឺនៅក្នុងបញ្ជីចែកចាយឯកសាររបស់ រ៉ែន មកពីកងពល៨០១។ នៅពាក់កណ្ដាលខែកញ្ញា ឆ្នាំ ១៩៧៦ ដែលក្នុងនោះគឺថាបញ្ជីរៀបរាប់ឈ្មោះនេះគឺមានឈ្មោះរបស់លោកផងដែរ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្ហាញនូវឯកសារមួយចំនួននេះជូនទៅសាក្សី ដែលឯកសារនេះគឺជាឯកសារនៅក្នុងបញ្ជី។ ហើយខ្ញុំនឹងបង្ហាញជូននូវលេខកូដឯកសារ តែខ្ញុំសូម -- ឯកសារនេះមានទាំងអស់ចំនួន៦មាន E3/1024, E3/1104, E3/1212, E3/1151, E3/1107 និង E3/1079។ សូមបង្ហាញឯកសារនេះជូនទៅសាក្សី។

[០៩:៣៣:៥៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[០៩:៣៤:៣១]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី តើមានអ្នកណាម្នាក់ផ្សេងទៀតឈ្មោះ វ៉ែន ដែរមកពីកងពល៨០១ ដែលបានមកសេនាធិការនៅភ្នំពេញ? ឬតើមាន វ៉ែន ណាផ្សេងទេដែលៗមកកាន់សេធិការក្នុងពេលនោះ?

**លោក អ៊ុង វ៉ែន៖**

**ឆ៖** បាទ ខ្ញុំដូចបានជម្រាបក្នុងឯកសារនេះហើយ គឺតាមពិតនៅក្នុងសេនាធិការហ្នឹងមានតែខ្ញុំម្នាក់ទេ ហើយក្រៅពីនោះមាន សោម ហើយនិង ណាត ដូចខ្ញុំបាទបញ្ជាក់ពីម្សិលហើយ។

**ស៖** ដោយការទទួលស្គាល់ថា ឈ្មោះរបស់លោកនៅក្នុងកន្លែងចម្លងជូននៃការឯកសារនេះ តើនេះជួយដល់រំឭកដល់ការចងចាំរបស់លោកអំពីអំឡុងពេលដែលលោកនៅសេនាធិការនោះទេ? ហើយថាតើលោកអាចជម្រាបបានទេមានតែលោកម្នាក់គត់ដែលមានឈ្មោះថា វ៉ែន នៅក្នុងបញ្ជីឯកសារដែលដាក់ថាចម្លងជូននេះ?

[០៩:៣៦:១២]

**ឆ៖** តាមពិត គឺខ្ញុំមិនដែលបានទទួលឯកសារទៅ ៨០១ទេ។

**ស៖** បញ្ជីឯកសារបន្ថែមបញ្ជាក់ថា "ជូនបង៨១" លោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ បង៨១ជាអ្នកណា?

**ឆ៖** ខ្ញុំមិនស្គាល់ទេ បង៨១។

**ស៖** តើលោកស្គាល់អ្នកដែលនៅសេនាធិការឈ្មោះ សៀត ឆែ ហៅ ទុំ នោះដែរឬទេ?

**ឆ៖** មិនស្គាល់ទេ។

**ស៖** បាទ ពេលនេះខ្ញុំសូមទៅកំណត់ត្រាខ្លះបានមកពីវគ្គសិក្សាដែលគេបើកនៅសេនាធិការនៅខែតុលា និងខែវិច្ឆិកា ឆ្នាំ៧៦។ បាទ ដើម្បីជាប្រតិចារឹក លោកប្រធាន ខ្ញុំសូមបង្ហាញឯកសារ E3/13 ចុះថ្ងៃទី០៩ ខែតុលា ៧៦ ជាកំណត់ហេតុកិច្ចប្រជុំនៅសេនាធិការជាមួយនឹង សុន សេន។ ផ្នែកទី២នៃឯកសារនេះ និយាយអំពីវគ្គសិក្សាដែលបានបើកនៅសេនាធិការនៅក្នុងខែ អំឡុងនៃខែនោះ ដែល

ឯកសារនេះបញ្ជាក់ថា លេខារបស់កងវរសេនាធំទាំងអស់មកពីកងពលនីមួយៗត្រូវបានអញ្ជើញឲ្យមកចូលរួមនៅក្នុងកិច្ចប្រជុំនេះ។ លោកសាក្សី ឯកសារដែលខ្ញុំចង់ឲ្យលោកពិនិត្យមើលនោះ គឺឯកសារដែលបញ្ជាក់ពីវត្តមានវគ្គសិក្សានៅសេនាធិការចំនួនពីរវគ្គ។ ហើយខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះ ដើម្បីបង្ហាញឯកសារនេះជូនទៅសាក្សី។ ឯកសារទី១ គឺE3/1585 នេះគឺជាបញ្ជីអ្នកចូលរួមក្នុងវគ្គសិក្សានៅសេនាធិការនៅថ្ងៃទី២០ តុលា ឆ្នាំ១៩៧៦។ ហើយនិងឯកសារ E3/847 ជាបញ្ជីវត្តមានដែលសិក្សាលើកទី២ នៅសេនាធិការចាប់ផ្ដើមនៅថ្ងៃទី២៣ ខែវិច្ឆិកា ៧៦។

**លោក ឌេល លីសាក់៖**

បាទ ដូច្នេះខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីបង្ហាញជូនឯកសារទាំងពីរនេះទៅឲ្យសាក្សីពិនិត្យមើល។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

[០៩:៤០:០០]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោក អ៊ុង វ៉ែន ខ្ញុំសូមចាប់ផ្ដើមជាមួយនឹងឯកសារ E3/1585 ដែលជាបញ្ជីវត្តមាននៃអ្នកដែលចូលរួមវគ្គសិក្សាលើកទី១ នៅថ្ងៃទី២០ តុលា ៧៦ នៅឯសេនាធិការ។ ខ្ញុំសូមឲ្យលោកផ្ដោតការយកចិត្តទុកដាក់ទៅលើឈ្មោះបុគ្គលមួយចំនួននៅក្នុងបញ្ជីឯកសារនេះ គឺលេខរៀង៩២ ទៅដល់រហូត១២២។ បាទ សូមមើលពីត្រឹមលេខរៀង៩២ ទៅដល់ ១២២ នៅក្នុងបញ្ជីវត្តមាននេះ។ យើងមានអនុសេនា -- មានកងវរសេនាធំដែលចូលមករៀនសូត្រទាំងអស់មាន ៣១នាក់ មកពីកងពល៨០១។ បាទ សូមពិនិត្យមើលមើល៍ ចាប់ពីលេខរៀង៩២ រហូតមកដល់១២២ និងសូមជម្រាបជូនអង្គជំនុំជម្រះផងថា តើលោកមានចាំឈ្មោះសមមិត្ត ឬកម្មាភិបាលណាខ្លះដែលមកពីកងពល៨០១ នោះ?

[០៩:៤១:៤៤]

**លោក អ៊ុង វ៉ែន៖**

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា ទី១ ក្នុងនេះ គឺខ្ញុំសូមរៀបពីឈ្មោះដែលខ្ញុំស្គាល់ក្នុងកងពល ទី១ រឿន ហើយដែលទី២ គឺ ហ៊ាន ហើយមួយទៀតគឺ ខេន ហើយនិង ឆោម។ ខ្ញុំស្គាល់តែប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ សូមលោកមើលឯកសារមួយទៀត គឺឯកសារ E3/847 ក៏ជាបញ្ជី

ឯកសារវត្តមានសម្រាប់កម្មាភិបាលដែលចូលរួមវគ្គសិក្សាលើកទី២ នៅឆ្នាំ -- នៅថ្ងៃទី២០ ខែវិច្ឆិកា ៧៦ វគ្គទី២ នៅឯសេនាធិការ។ បាទ ហើយក្នុងឯកសារនេះ ខ្ញុំសូមឲ្យលោកយកចិត្តទុកដាក់ត្រឹមលេខរៀង ៣៦ ទៅដល់ ៦៣។ ដោយសារថា មានអ្នកចូលរួមមកពីកងវរសេនាតូច វរសេនាធំហ្នឹងច្រើន មកពីកងពល៨០១ ក៏មានអ្នកចូលរួមនៅក្នុងវគ្គសិក្សាលើកទី២នេះផងដែរ។ សូមលោកពិនិត្យមើលដូចគ្នានេះ គឺមើលត្រឹមពីលេខរៀង៣៦ ទៅដល់លេខរៀងទី៦៣ បានហើយ។ ហើយសូមជម្រាបជូនអង្គជំនុំជម្រះផងថា តើលោកនៅចាំឈ្មោះកម្មាភិបាល ឬសមមិត្តណាខ្លះដែលមកពីកងពល៨០១ នោះ?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយទី១ គឺ រឿន ហើយមួយទៀតគឺ កែវ ហើយទី៣ គឺ ប្រ, សឿន, ស៊ន។

[០៩:៤៥:១៧]

**ស៖** លោកសាក្សី ខ្ញុំសូមឲ្យពិនិត្យមើលត្រឹមតែលេខរៀង ៣៦ ទៅ ៦៣ បានហើយ តើមនុស្សណាខ្លះដែលលោកបានស្គាល់ថា មកពីកងពល៨០១នោះ ដែលលោកអាចនៅចាំបាន? ក្នុងនោះ ក្រៅពីហ្នឹងផងដែរ ក្នុងចន្លោះលេខរៀងហ្នឹង ក្រៅពីអ្នកមកពីកងពល៨០១ផង លោកស្គាល់អ្នកណាខ្លះ?

**ឆ៖** ខ្ញុំមើលក្នុងនេះ គឺខ្ញុំស្គាល់ឈ្មោះ កែវ ហើយនិង ហ៊ន នៅក្នុងកងពល៨០១ ហើយជាពិសេសនៅក្នុងវរសេនាធំ ដែលខ្ញុំទទួល ហើយក្រៅពីនោះ នៅក្នុងកងពល៨០១ ដែរ ប៉ុន្តែខ្ញុំមិនស្គាល់ឈ្មោះគេទេ។ បាទ ដូច្នេះនៅក្នុងនោះ មានកង៨៣, ៨១ នោះទៅ ម៉េចខ្ញុំអត់ស្គាល់។

**ស៖** តើលោកចាំវគ្គសិក្សាលើកទី១ និងលើកទី២ ដែលបានរាយការណ៍នៅលើឯកសារនេះថាបានធ្វើឡើងនៅក្នុងខែតុលា និងវិច្ឆិកា ឆ្នាំ៧៦ទេ លោកនៅចាំវគ្គសិក្សាទាំងពីរនេះទេ?

**ឆ៖** បាទ ខ្ញុំអត់ចាំ។ ខ្ញុំអត់បានចាំទេ។

**ស៖** តើលោកមាននៅចាំទេថា ហេតុអ្វីបានជាឈ្មោះលោក គេមិនបានចុះជាអ្នកដែលចូលរួមមកពីកងពល៨០១ នៅក្នុងវគ្គសិក្សានុ៎ង? ហេតុម៉េច ក៏គេមិនៗឃើញមានឈ្មោះលោកនៅក្នុងបញ្ជីវត្តមាននេះ?

[០៩:៤៧:២៣]

**ឆ៖** បាទ ខ្ញុំឃើញថា វាអត់ឃើញនៅក្នុងបញ្ជីវត្តមាននេះ ហើយខ្ញុំ អង្គាល់ខ្ញុំនៅមុខឯណោះនៅមន្ទីរអង្គភាព។ ខ្ញុំមិនមកប្រជុំដែរមិនដឹង។ ព្រោះវគ្គសិក្សាមួយៗ វាជួនកាល វាមានតែ-- ជួនកាលបើថានេះ ត្រូវមានបង្គោលមួយនៅក្នុងអង្គភាព។

**ស៖** លោក អ៊ុង រ៉េន មូលហេតុដែលថា លោកមិនមានឈ្មោះជាមកពីកងពល៨០១ គឺថា

នៅពេលនោះ ដោយសារលោកថាពេលនោះ ត្រូវគេចាត់តាំងឱ្យមកសេនាធិការ។ ហើយអ៊ីចឹងហើយ បានជាសួរហេតុម៉េច បានមិនមានឈ្មោះលោកហ្នឹង?

**ឆ៖** តាមពិត គឺដូចខ្ញុំបានបញ្ជាក់ពីខាងដើមហើយ គឺចំពោះផ្ទាល់ខ្លួនខ្ញុំ គឺអត់មានកងពល ឬក៏មេបញ្ជាការកងពលចាត់តាំងឱ្យមកសេនាធិការទេ គឺថាដោយមូលហេតុដែលខ្ញុំមករៀន ហើយគ្រុន។ ហើយដល់ពេលគ្រុនហ្នឹង ជិត១ខែ បានជាៗ ក៏នៅក្នុងមន្ទីរនេះតែម្តង។ ដូចខ្ញុំបានបញ្ជាក់ពីម្សិលគឺគ្មានប្រកាស គ្មានស្អីធ្វើអី ហើយដូច្នេះ អត់មានធ្វើការងារអ្វីទេ។

[០៩:៤៩:១៨]

**ស៖** ដើម្បីប្រតិចារឹក ដោយសារតែពេលវេលា គឺខ្ញុំមិនបង្ហាញឯកសារច្រើនទៅសាក្សីទេ ប៉ុន្តែ ដើម្បីប្រតិចារឹកនៃដំណើរការនីតិវិធីនេះ គឺឯកសារ E3/1045 នៅទំព័រខ្មែរ 00160061 ដល់160063, ជាភាសាអង់គ្លេស 00335265 ដល់ 335267។ នេះគឺជាអង្គការលេខ ឬក៏អង្គការចាត់តាំងរបស់កងពល៨០១ ដែលបានបង្ហាញជូននៅក្នុងវគ្គសិក្សារៀនសូត្រ។ លោកសាក្សីឯកសារចុងក្រោយ ដែលខ្ញុំចង់លើកយកមកសួរលោកគឺ ឯកសារមកពីសេនាធិការ ដែលមានយោងឈ្មោះ សមមិត្តវ៉ែន។

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមឱ្យបង្ហាញឯកសារពីរទៀតជូនទៅសាក្សីគឺឯកសារ E3/1109 និង E3/820។ E3/1109 គឺចុះថ្ងៃទី៣១ កញ្ញា ៧៦ ដែលផ្ញើទៅសមមិត្តវ៉ែន និយាយអំពីកិច្ចប្រជុំជីវភាព ហើយឯកសារ E3/820 គឺជារបាយការណ៍ចុះថ្ងៃទី០១ តុលា ១៩៧៦ របស់សមមិត្តវ៉ែន នៅឯសេនាធិការនិយាយអំពីកិច្ចប្រជុំដែលបានធ្វើឡើងនៅឯកងពល៨០១។ គឺដូច្នោះខ្ញុំសូមការអនុញ្ញាតដើម្បីបង្ហាញជូនឯកសារទាំងពីរជូនទៅសាក្សីពិនិត្យមើល។

[០៩:៥១:២៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ អម្បាញ់មិញនេះគឺថាមួយសន្ទុះដែលតំណាងសហព្រះរាជអាជ្ញាធ្វើសេចក្តីជាសន្និដ្ឋានអំពីការបង្ហាញឯកសារ តែលោកមិនបានបង្ហាញឯកសារទៅសាក្សីឱ្យឆ្លើយទៅលើឯកសារណាជាក់លាក់ទេ។ ហើយការកត់សម្គាល់បែបនេះ វាប្រាសចាកពីការសាកសួរដេញ

ដោលនៅក្នុងនីតិវិធីយើងបច្ចុប្បន្ននេះ។ អ៊ីចឹងបើសិនជាលោកធ្វើការ -- ចង់ធ្វើការកត់សម្គាល់គួរតែលើកទៅចាំពេលការធ្វើការកត់សម្គាល់នៅពេលក្រោយ នៅពេលដែលយើងធ្វើសេចក្ដីសន្និដ្ឋាន។ ហើយដំណាក់កាលនេះគួរតែលើកឯកសារហ្នឹងឲ្យចំៗ សួរទៅសាក្សីតែម្ដងទៅ។ បាទ សូមអរគុណ។

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមធ្វើការឆ្លើយតប។ ពាក់ព័ន្ធថាតើឯកសារដែលនេះ គឺថាវាជាពេលវេលាដែលខាងសហព្រះរាជអាជ្ញាដែលត្រូវសាកសួរ។ ដូច្នេះដើម្បីជាប្រតិចារឹកគឺថាយើងត្រូវបង្ហាញជូនទូវឯកសារទាំងអស់នេះហើយ។

ដូច្នេះលោកប្រធានបើសិនណាជាលោកប្រធានអនុញ្ញាត ខ្ញុំសូមសួរទៅឯកសារដែលបានសួរអម្បាញ់មិញបន្តទៅទៀត។ សូមអរគុណ។

[០៩:៥៣:០៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកសាក្សី បើលោកមើលរបាយការណ៍ទាំងពីរនេះ គឺសំណួររបស់ខ្ញុំ ថាតើលោកមានធ្លាប់បានចាត់តាំងឲ្យចូលរួមប្រជុំជីវភាព ឬទិតៀន ស្វ័យទិតៀននៅ -- ដើម្បីរាយការណ៍ជូនទៅសេនាធិការគឺកិច្ចប្រជុំ-- លោកសាក្សីតើលោកនៅចាំទេ លោកធ្លាប់បានចាត់តាំងឲ្យប្រជុំជីវភាព និងប្រជុំទិតៀន និងស្វ័យទិតៀននៅកងពល៤៥០ និងកងពល១៧០ លោកចាំទេ ធ្លាប់បានអញ្ជើញប្រជុំនៅក្នុងកងពលទាំងពីរនេះទេ?

**លោក អ៊ុង វ៉ែន៖**

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា ក្នុងបញ្ហាកងពលទាំងពីរនេះគឺ ខ្ញុំបានប្រជុំនៅកងពល៧០ម្ដងហើយនិងកងពលស្ទីប៉ុន្មានទេ ៤៥០អ៊ីចឹងទៅម្ដង។ ពេលនោះ គឺតាមពិត ជាតម្រូវការគឺ សោម ទេដែលត្រូវការទៅប្រជុំនៅអង្គភាពនោះ។ នោះតែដោយឡែកគេជាប់រវល់ទៅ គេឲ្យខ្ញុំទៅជំនួស។ ខ្ញុំសូមមានមតិប៉ុណ្ណឹង។

[០៩:៥៦:០១]

**ស៖** តើ សោម បានឲ្យ ស្នើឲ្យលោកធ្វើអ្វីខ្លះនៅក្នុងកិច្ចប្រជុំទាំងពីរហ្នឹង?

**ឆ៖** បាទ គឺធម្មតាទៅប្រជុំ គឺយើងអត់មានផែនការអី ដាក់ជារបៀបវរៈអីលើប្រធានអង្គភាពរបស់គេទេ គឺថាទៅគ្រាន់តែរបៀបតាមមើលគេប្រជុំយ៉ាងម៉េចអីយ៉ាងម៉េច របៀបវរៈអីយ៉ាងម៉េច ហើយសភាពការណ៍ផ្ទៃក្នុងអង្គភាពនោះយ៉ាងម៉េចៗ តែប៉ុណ្ណោះឯង។ ហើយសរសេរកត់ត្រាអី រាយ-ការណ៍ជូនប្រាប់មកខាងលើប៉ុណ្ណោះឯង។

**ស៖** បើខ្ញុំយល់មិនយល់ច្រឡំទេ គឺលោកចូលរួមប្រជុំ គឺគ្រាន់តែរាយការណ៍នូវអ្វីដែលបានកើតឡើង ឬក៏ថាដើម្បីមករាយការណ៍វិញថា តើកិច្ចប្រជុំនៅកងពលទាំងពីរនោះ គេនិយាយអ្វីខ្លះ តើនេះអ៊ីចឹងមែនទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

[០៩:៥៧:២៨]

**ស៖** បញ្ហាមួយទៀត ដែលខ្ញុំចង់សួរទៅកាន់លោកនោះ លោកសាក្សី! នៅថ្ងៃទី១៨ តុលា ៧៦ គឺកំណត់ហេតុនៃកិច្ចប្រជុំនៅថ្ងៃនោះ គឺឯកសារ E3/815, ERN ជាភាសាខ្មែរ 00095530, ជាអង់គ្លេស 00143502, ERN ជាភាសាបារាំង 00623946។ នៅក្នុងកំណត់ហេតុអង្គប្រជុំនេះមានផ្នែកមួយដែលបង៨៩ បានផ្តល់មិតយោបល់ គឺវាពាក់ព័ន្ធនឹងមតិបង៨៩ គឺសូមដកស្រង់ "គម្រោងស្នើរៀបចំផែនការប្រយុទ្ធ សូមរៀបចំគណៈកម្មការមួយ មានមិត្តណាត, ទាញ, វ៉ែន និង សោម។ គណៈកម្មាធិការទាំងអស់នេះ គឺត្រូវពិនិត្យមើលថា តើត្រូវការពារទីក្រុងភ្នំពេញដោយរបៀបណា? ហើយនិងថាតើត្រូវការផ្លាស់ប្តូរកងពលដោយរបៀបណា និងត្រូវការពារភ្នំពេញដោយរបៀបណា?"។ នៅពេលដែលលោក គឺថាស្នើសុំឲ្យផ្តល់ជាមតិយោបល់ដើម្បីការពារនៅទីក្រុងភ្នំពេញហ្នឹង អ៊ីចឹងលោកមានយោបល់ថាម៉េចដែរ?

[០៩:៥៩:១៩]

**ស៖** បាទ ខ្ញុំសូមជម្រាបបញ្ហានេះ គឺខ្ញុំអត់មានបញ្ហារៀបចំផែនការប្រយុទ្ធជាមួយ ណាត និង សោម ទេបាទ។ ពីព្រោះដូចខ្ញុំបានបញ្ជាក់ខាងដើមអ៊ីចឹង ខ្ញុំនៅកន្លែងដោយឡែក មានតែបីរូបទេ ដែលខ្ញុំបានជម្រាបដូចកាលមុន ប៉ុន្តែខ្ញុំបានបញ្ជាក់ក្នុងមន្ត្រីទៅសង្កេតការណ៍ ខ្ញុំបានបញ្ជាក់ថា ពេលដែលសត្រូវ វ៉ៃនៅកន្លែងគគីរសោម នេះខ្ញុំក៏ សុន សេន នេះឲ្យៗ បញ្ជាឲ្យទៅមើល ដល់ខ្ញុំទៅដល់នុំងក៏ខ្មាំងសត្រូវទៅអស់ ហើយក៏ឡប់មកវិញបាទ។ ដូច្នេះ ខ្ញុំពិនិត្យខ្លួនខ្ញុំតាំងពីនោះមក គឺខ្ញុំឃើញតែប៉ុណ្ណឹងឯង។ ឯសម្រាប់ផែនការប្រជុំអី ការពារភ្នំពេញអីយ៉ាងម៉េចៗអី ខ្ញុំអត់បានប្រជុំទេ អត់បានប្រជុំជាមួយក្នុង

ដូចក្នុងសំណួរនេះទេ។

**ស៖** សូមអរគុណចំពោះចម្លើយរបស់លោក។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្ហាញជូនឯកសារ នូវឯកសារមួយទៀត គឺ E3/1163។ នេះគឺជាកំណត់ហេតុចុះថ្ងៃទី១៤ វិច្ឆិកា ៧៦ ដែលរាយការណ៍ដោយសមមិត្តរ៉ែន ជូនទៅសេនាធិការ។ ខ្ញុំបង្ហាញឯកសារនេះជូនទៅសាក្សី។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១០:០១:៣៦]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោក អ៊ុង រ៉ែន នេះជាឯកសារមួយទៀតមកពីអគ្គសេនាធិការដែលជារបាយការណ៍មួយដែលមានឈ្មោះលោកនៅទីនោះ។ នេះជារបាយការណ៍និយាយអំពីកងពល៤៥០ ជាពិសេស គឺទាក់ទងទៅនឹងកម្មាភិបាលនៅក្នុងកងពល -- កម្មាភិបាលឈ្មោះ ឆោត ហើយនិងមនុស្សមួយចំនួនដែលគាត់ឆ្លើយដាក់បន្ទាប់ពីគេចាប់ខ្លួនគាត់។ នៅក្នុងរបាយការណ៍នេះ ខ្ញុំបន្តទៅរៀបរាប់មួយចំនួនអំពីមនុស្សមួយចំនួនដែល ឆោត នោះគាត់បានឆ្លើយដាក់នៅក្នុងកងពល៤៥០, កងពល៣១០ ហើយនិងមន្ទីរពាណិជ្ជកម្មផ្សេងៗទៀត។ នៅក្នុងខាងចុងនោះនិយាយថា "ស្នើសុំរាយការណ៍ពីស្ថានភាពនេះជូនអង្គការហើយនិងធ្វើការជាមួយផង សឿន នៅកងពល៤៥០ តើលោកអាចនឹកឃើញទេ ហើយអាចជម្រាបតុលាការបានទេអំពីអ្វីៗ អំពីបញ្ហាមួយចំនួនដែលលោកអាចនៅចងចាំ ឬនៅនឹកឃើញឡើងវិញនោះ?

[១០:០២:៥៨]

**លោក អ៊ុង រ៉ែន៖**

**ឆ៖** បាទ ខ្ញុំសូមឆ្លើយនឹងសំណួរនេះ។ បើនិយាយក្នុងកងពលនោះ ខ្ញុំក្តាប់មិនបាន ៗត្រង់ថាអត់មានឈ្មោះ ឮដូចអត់មានឈ្មោះ សឿន ទេ។

**ស៖** តើលោកនៅចាំទេថា តើមានការពិភាក្សាជាមួយកម្មាភិបាលមួយឈ្មោះ សឿង មកពី ៤៥០ ដែរឬទេ?

**ឆ៖** ខ្ញុំ ដូចខ្ញុំបានបញ្ជាក់អ៊ីចឹង គឺខ្ញុំអត់ស្គាល់ទេ ឈ្មោះ សឿង។ ហើយមិនដែលបានពិភាក្សា

ជាមួយក្នុងអង្គភាព៤៥០ហ្នឹងទេ គឺដូចខ្ញុំបានបញ្ជាក់ហើយថា បើប្រជុំខ្ញុំបានប្រជុំតែពីរកងពលហ្នឹងម្តង។

[១០:០៤:០៦]

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញជូនសាក្សីនូវឯកសារមួយទៀត E3/1131 គឺបាទ E3/1131 គឺជារបាយការណ៍ថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៧៦ បាទ ជូនទៅអគ្គសេនាធិការ បាទអំពីសមមិត្ត រ៉ែន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោក អ៊ុង រ៉ែន នេះជាឯកសារដែលជារបាយការណ៍ ដែលធ្វើឡើងដោយសមមិត្ត រ៉ែន ដែលជាឈ្មោះរបស់លោក ហើយកាលបរិច្ឆេទ គឺថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ដែលជាវគ្គសិក្សាទី២ ក្នុងអគ្គសេនាធិការ ដូចដែលខ្ញុំបានបង្ហាញជូនលោកដែលចាប់ផ្តើមនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៧៦ នោះ។ នេះជារបាយការណ៍មួយនិយាយអំពីការធ្វើការជាមួយ បងអឿន នៅក្នុងកងពល៣១០។ កថាខណ្ឌទី១ និយាយថា “មានមនុស្សពីរនាក់ដែលគេឆ្លើយដាក់ ដែលខ្មាំងឆ្លើយដាក់ ក៏បានចូលរួមក្នុងវគ្គសិក្សា គឺឈ្មោះ ជា មកពីកង ពល៣១០ ហើយនិង ហម កងពលនៅក្នុងកងពល៣១០”។ ហើយនៅខាងក្រោមនោះគឺថា “កងពលបានក្តាប់ពីរនាក់នេះ គឺថាមិនមានសកម្មភាពអ្វីទេ ពួកគេផ្លាប់រស់នៅជាមួយ បងអឿន នៅក្នុងកងពល១៧០ ហើយគាត់ក្តាប់បាននូវបញ្ហានេះ” សូមចប់សេចក្តីដកស្រង់។ តើលោកនៅចាំពីបញ្ហានេះដែរទេ? ដែលថាធ្វើការជាមួយ បងអឿន នៅកងពល៣១០នោះ។ តើលោកនៅចាំទេ?

[១០:០៦:៣០]

**ឆ៖** ខ្ញុំអត់ចាំទេ។ ហើយតាមពិត អឿន ហ្នឹង ក៏ខ្ញុំស្គាល់ ប៉ុន្តែត្រង់ថា អ្នកដែលមានសកម្មភាពឈ្មោះអីពីរនាក់ទៀតនោះ ខ្ញុំអត់ដែលបាន -- និយាយរួមមកគឺក្នុងសភាពការណ៍ ឬក៏សកម្មភាពអីក្នុងកងពលនីមួយៗគឺអត់ៗ ខ្ញុំអត់ដឹង បាទគឺអត់មានពាក់ព័ន្ធនឹងបញ្ហាអង្គភាព។ ហើយបើនិយាយពីភារកិច្ចការងារនៅក្នុងសេនាធិការដែលខ្ញុំនៅមួយរយៈហ្នឹងឃើញថា ទី១ គឺខាងផ្នែកយោធាហ្នឹងគឺ អ៊ិន ណាត នេះ ឯង ហើយទី២ នយោបាយគឺ សោម នេះឯង ហើយភ័ស្តុភារគឺ ឆាន នេះឯង នេះខ្ញុំដឹងប៉ុណ្ណឹង។

ប៉ុន្តែដោយឡែកបើសិនណាជា គេប្រាប់ឲ្យខ្ញុំ "អេ៎! កុំនៅទំនេរពេក ទៅប្រជុំត្រង់នេះ ត្រង់នោះអី ខ្ញុំទៅបានបាទ"។ ប៉ុន្តែនេះ -- ព្រោះខ្ញុំអត់ចាំទេ តាមពិតខ្ញុំដឹងថាប្រជុំមានតែពីរដង ដែលខ្ញុំមកនៅនេះ នៅកងពល១៧០ ហើយនិង៤៥០ហ្នឹង តែម្តងទេ។

[១០:០៧:៥២]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ដើម្បីកំណត់ត្រាតុលាការរបាយការណ៍ ដែលនិយាយពី E3/1130 ដែលសាក្សីលោកបានពិភាក្សានេះ គឺបញ្ជាក់ពីមនុស្សពីរនាក់ដែលត្រូវបានគេឆ្លើយដាក់ ប៉ុន្តែអ្នកទាំងពីរនោះឈ្មោះ ជា ហើយនិង ហម។ បញ្ជីវត្តមាននៅថ្ងៃ២៣ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ជាវគ្គសិក្សាទី២ អគ្គសេនាធិការ ឯកសារ E3/847 គឺថាមនុស្សលេខ២១៧ គឺថាឈ្មោះ ជា មកពីកងពល៣១០ ហើយលេខរៀង២២០ គឺឈ្មោះ ហម មកពីកងពល៣១០ ផងដែរ។

ឯកសារបន្ទាប់ទៅទៀត ដែលខ្ញុំនឹងបង្ហាញជូនសាក្សីនោះ គឺឯកសារ E3/1166 គឺថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៧៦ ចេញមកពីកម្មាភិបាលម្នាក់ ហើយខ្ញុំសូមអនុញ្ញាតតុលាការដើម្បីបង្ហាញជូនឯកសារនេះដើម្បីសាក្សីពិនិត្យបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

*(មន្ត្រីតុលាការជូនឯកសារសាក្សីពិនិត្យ)*

[១០:០៩:៣៨]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ឯកសារ E3/1166 នេះ គឺជា -- គឺចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៧៦ គឺដែលចុះហត្ថលេខាដោយ សមមិត្តរ៉ែន "របាយការណ៍គឺ ស្នើសុំរាយការណ៍ជូនបងអំពីស្ថានភាពទូទៅនៅកងពល៤៥០ ដែលបានទៅធ្វើការជាមួយ បងសួង ហើយនិង បងយ៉ាន។ ហើយនិយាយអំពីសំណើសុំដកសមមិត្តម្នាក់ចេញពីអង្គភាព។ តើលោកនៅចងចាំពីអ្វី បញ្ហានេះដែរទេ គឺថាសុំដក សមមិត្តលំ ពីអង្គភាពចេញនេះបាទ?

**លោក អ៊ុង រ៉ែន៖**

**ឆ៖** បញ្ហានេះគឺខ្ញុំ ខ្ញុំដឹង គឺពេលដែលខ្ញុំទៅជួបប្រជុំជាមួយ សួង និង យ៉ាន ហ្នឹងគឺ តាមពិតគឺ

សភាពការណ៍រួមនៅក្នុងអង្គភាពរបស់គេដែលគេត្រូវការស្នើមកកន្លែងខាងលើ។ ហើយកន្លែងសេនាធិការហ្នឹងគឺដែលខ្ញុំទៅហ្នឹង គឺគេស្នើថា "ឥឡូវសុំដក"។ តែឥឡូវដកហ្នឹងគឺមិនមែនខាងខ្ញុំសម្រេចទេ ខ្ញុំគ្រាន់តែរាយការណ៍ទៅជូនខាងលើ ដើម្បីខាងលើយល់ថាក្នុងអង្គភាពទាំងមូលនេះគេសំណូមពរឲ្យដកឈ្មោះនេះឯង។

**ស៖** តើអ្នកណានៅក្នុងសេនាធិការ ដែលណែនាំឲ្យលោកទៅធ្វើការជាមួយបងទាំងពីរនាក់នេះ ដើម្បី បងសួង ហើយនិង បងយ៉ាន នេះដើម្បីធ្វើការងារហ្នឹង?

**ឆ៖** ទៅកន្លែងធ្វើការនៅជាមួយ សួង ហើយនិង យ៉ាន នេះគឺមានតែ ណាត ទេដែលអ្នកចាត់ចែងឲ្យទៅ។

**ស៖** សូមអរគុណលោកសាក្សី។

[១០:១២:០១]

**លោក ខេល លីសាក់៖**

លោកប្រធាន ដើម្បីកំណត់ត្រាតុលាការបុគ្គលម្នាក់ដែលមានឈ្មោះថា ម៉ៅ –ម៉ៅ សុខា ហៅ លំ– គេកំណត់អត្តសញ្ញាណថាជាជំនួយការកងពល៤៥០ ហើយចូលទៅដល់ស-២១ នៅថ្ងៃទី ឆ្នាំ -- បាទ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៦។ ឈ្មោះរបស់គាត់នៅលើឯកសារមួយ D108/26.22។ ខ្មែរទំព័រ ERN 00088720 បាទ គឺនៅទី៦ នៅក្នុងបញ្ជីរាយនាមអ្នកទោសស-២១។ ខ្ញុំមានឯកសារពីរទៀតមកពីសមមិត្តវ៉ែន ដែលសុំអនុញ្ញាតពីលោកប្រធានដើម្បី -- ដោយមានការអនុញ្ញាតនោះនឹងសូមបង្ហាញឯកសារនេះទាំងពីរ គឺទី១ ឯកសារ E3/1161 ដែលជារបាយការណ៍ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៧៧ របស់ វ៉ែន គឺឯកសារទី២ E3/1044 ថ្ងៃ៣០ ខែតុលា ឆ្នាំ១៩៧៧ ដោយសមមិត្តវ៉ែន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! ប៉ុន្តែតំណាងសហព្រះរាជអាជ្ញាអាចបង្ហាញបានទេ ថាឥឡូវនេះសល់តែ១៤មីនុតទេ ទៀតទេភាគី រួមទាំងភាគីក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីផង តើការប្រើប្រាស់ពេលវេលាហ្នឹងយ៉ាងម៉េចដែរ? លោកអាចបញ្ជាក់បានទេ?

[១០:១៤:១៨]

**លោក ខេល លីសាក់៖**

បាទ លោកប្រធាន ខ្ញុំមានឯកសារតែមួយពីរទៀតទេដើម្បីសួរលោកសាក្សី ហើយនិងខ្ញុំបាន

ទទួលសញ្ញាពីដើមបណ្ដឹងរដ្ឋប្បវេណី ហើយគាត់នឹងប្រើពេលដែលនៅសេសសល់ពីខ្ញុំដើម្បីសាកសួរទៅលោកសាក្សីរូបនេះបាទ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោក អ៊ុំង វ៉ែន សូមលោកពិនិត្យមើលឯកសារ E3/1161។ នេះ គឺជារបាយការណ៍ថ្ងៃទី ១២ ខែមីនា ឆ្នាំ៧៧ ដែលលោកជាអ្នកធ្វើរបាយការណ៍នេះ ដែលមានចំណងជើង និយាយថា "ខ្ញុំសូមរាយការណ៍ពីសភាពការណ៍រួមនៅកងពល៣១០ និង៤៥០" ដែលនិយាយថាលោកបានជួបជាមួយបងប្រុសបងស្រីអំពីការណែនាំរបស់អង្គការមួយចំនួន។ តើលោកនៅចាំដែរឬទេ ថាតើមានអ្វីខ្លះដែលលោកនឹកឃើញថា នៅក្នុងការប្រជុំនោះ ដែលលោកអាចជម្រាបជូនអង្គជំនុំជម្រះថ្ងៃនេះបាន?

**លោក អ៊ុំង វ៉ែន៖**

**ឆ៖** បាទ ចំពោះបញ្ហានេះ ខ្ញុំទទួលស្គាល់ថា ខ្ញុំបានចូលរួមប្រជុំនៅកន្លែងនោះមែន។ ទី១ គឺសភាពការណ៍រួមនៅក្នុងអង្គភាពនោះ គឺមានការប្រែប្រួល ចង់និយាយថា សតិអារម្មណ៍នយោបាយអីគឺអ៊ីចឹងទេ "សោម នេះគេថាឥឡូវទៅខាងច្បារអំពៅ ជួបនឹង១៧០ ហើយខាង វ៉ែន ឯងទៅជួយខាងនោះ ដើម្បីប្រជុំបងប្អូន" ហើយសភាពការណ៍ គឺពិនិត្យអំពីសភាពការណ៍ខ្មាំងហ្នឹងឯង។ ហើយសភាពការណ៍ក្នុងកងទ័ពយ៉ាងម៉េចៗ ក៏សភាពការណ៍ពេលនោះ គឺប្រែប្រួលហើយ ក្នុងអង្គភាពមួយៗ គឺវាមានការប្រែប្រួល។ ដូច្នេះ គឺតែទៅគឺពិនិត្យសភាពការណ៍ផ្ទៃក្នុងយ៉ាងម៉េច ក្រោយពេលដែលយើងខានបានជួបគ្នាយូរអ៊ីចឹង មកទល់ពេលនេះ មានអីលំបាក ហើយការគោរពវិន័យ គោរពអង្គការយ៉ាងម៉េច បាទ។ ដូច្នេះ បញ្ហានេះគឺខ្ញុំបានចូលរួមធ្វើ។

[១០:១៧:៣៣]

**ស៖** នៅពេលដែលគេណែនាំឲ្យលោកទៅចូលរួមប្រជុំនោះ ដែលប្រជុំជាមួយកងពល៣១០ និង១៧០ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៧នេះ។ តើគេប្រាប់លោកថាលេខានៃកងពលទាំងពីរហ្នឹង ត្រូវបានគេចាប់ខ្លួនដែរឬទេ គឺថាមុនខែមីនានោះ? គឺទាំង សមមិត្តសឿង ហើយនិងសមមិត្ត ហ៊ាន ហ្នឹង តើលោកបានដឹងទេ នៅពេលដែលគេណែនាំឲ្យលោកទៅប្រជុំនោះ គឺលេខាកងពលទាំងពីរនោះ ត្រូវបានគេបោសសម្អាតរួចហើយនោះ?

**ឆ៖** ខ្ញុំក៏ក្ដាប់មិនបានដែរ ព្រោះគេឲ្យខ្ញុំទៅធ្វើការ ដូចខ្ញុំបានបញ្ជាក់ខាងដើមហើយ គឺមិនដឹងថាកងពល ប្រធានកងពល ឬក៏វរសេនាធំណាមានបញ្ហាអី គឺខ្ញុំក្ដាប់មិនបានទេ ឲ្យទៅប្រជុំ គឺទៅប្រជុំ

ប៉ុណ្ណោះឯង។ ក្តាប់សភាពការណ៍ បើមានអីប្លែក វាមានស្មុគស្មាញ ក៏រាយការណ៍មកប្រាប់ សោម វិញ អីចេះៗ រាយការណ៍ ដូចខ្ញុំបញ្ជាក់ខាងដើមហើយ។

**សៈ** ឯកសារចុងក្រោយរបស់សេនាធិការដែលខ្ញុំចង់សួរលោកនោះ គឺឯកសារ E3/1044 គឺជារបាយការណ៍ថ្ងៃទី៣០ តុលា ឆ្នាំ១៩៧៧ រៀបចំដោយសមមិត្តរ៉ែន អគ្គសេនាធិការ។ នេះគឺជារបាយការណ៍ដែលស្នើសុំដកសមាសភាពមិនល្អដែលមានជាបីប្រភេទ។ នៅក្នុងកថាខណ្ឌទី១ "ប្រភេទទី១ គឺជាមនុស្សបីនាក់ ដែលសុំបញ្ជូនទៅបង ឌុច ចំនួនបីនាក់"។

[១០:១៩:៣១]

កថាខណ្ឌទី២ "នាផ្នែកដែលនិយាយពីមនុស្ស៧នាក់ដែលបញ្ជូនទៅ បងហ៊ុយ ចំនួន៧នាក់"។ ហើយផ្នែកទី៣ "ស្នើដកមនុស្ស២៦នាក់ ដើម្បីបញ្ជូនទៅព្រៃស ដែលយើងបានតាមដាន ហើយទៅធ្វើស្រែនៅទីនោះ គឺយើងនឹងបញ្ជូនពួកគាត់ទៅទីនោះ។ តើលោកនឹកឃើញអ្វីខ្លះ បន្ថែមលើនេះ ដើម្បីឲ្យតុលាការបានជ្រាបដែលទាក់ទងទៅនឹងរបាយការណ៍មួយនេះបាទ?

**ឆះ** ខ្ញុំសូមជម្រាបផងដែរ ចំពោះបញ្ហារបាយការណ៍នេះ គឺខ្ញុំតាមពិត ខ្ញុំពិនិត្យខ្លួនខ្ញុំ គឺដូចខ្ញុំមិនដែលរាយការណ៍រឿងការដកទៅដាក់នៅកន្លែងនេះ កន្លែងនោះ។ ការពិតគឺផ្ទាល់ខ្លួនខ្ញុំ គឺសម្រេចអីបានបាទ ខ្ញុំចង់បញ្ជាក់អីចេះ។ ដូច្នេះគឺបើមានបញ្ហាអីនៅក្នុងកងពល គឺរាយការណ៍សកម្មភាពល្អប៉ុន្មាននាក់ៗ ខ្ញុំគ្រាន់តែមានសិទ្ធិរាយការណ៍ប្រាប់ សោម។ សោម ហ្នឹងក៏រាយការណ៍ជូនទៅលើប៉ុណ្ណោះឯង។ ប៉ុន្តែខ្ញុំចង់បញ្ជាក់អីចឹងទេ ហើយមានសិទ្ធិដាក់ទៅ ស-២១ ឬក៏ទៅធ្វើស្រែឯណាៗអី អត់ទេ។ ហើយតាមពិតគឺទាល់តែកងពលគេថា សកម្មភាពមិនល្អអីចេះៗអី ពីព្រោះខ្ញុំមិនមែនទៅគ្រប់គ្រងគេដឹងគេយ៉ាងម៉េចៗអីអាហ្នឹងគឺវាអត់ត្រូវរឿង។ អីចឹងទេ បានថាខ្ញុំចង់បញ្ជាក់ឲ្យវែងឆ្ងាយបន្តិច។ ក្នុងសភាពការណ៍ពេលនោះ បើយើងពិនិត្យទៅ វាចេះតែវែងឆ្ងាយ។

[១០:២១:១៨]

ឧបមាថា នៅក្នុងសហករណ៍មួយចុះ ខ្ញុំចង់បញ្ជាក់ដើម្បីអស់លោកយល់ រៀបចំសហករណ៍ទៅធ្វើស្រែ ភ្ជួរបាក់នង្គ័លរនាស់ហ្នឹង តើសេនាធិការដឹងទេ បើប្រធានភូមិមិនរាយការណ៍។ ហើយមេភូមិ មេឃុំហ្នឹង សហករណ៍ហ្នឹង បើមិនមានក្រុមប្រាប់គាត់ តើគាត់ដឹងអត់? ខ្ញុំចង់បញ្ជាក់ទេ។ ដូច្នេះខ្ញុំគ្រាន់តែចុះទៅធ្វើ ប៉ុន្តែរាយការណ៍ជាក់ស្តែងៗ សកម្មភាពអ្វីៗ គឺខ្ញុំជូនទៅរាយការណ៍ឲ្យ សោម។ សោម ក៏រាយការណ៍ទៅខាងលើទៀត ដូចខ្ញុំថា ខ្ញុំគ្មានសិទ្ធិអីទៅសម្រេចអីដល់ថ្នាក់នេះទេ អាហ្នឹងគឺវា

អត់ទំនង ខ្ញុំចង់បញ្ជាក់ជូនអ៊ីចឹង។

[១០:២២:១៣]

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំយល់ហើយ ហើយកុំយល់ថា លោកជាអ្នកមានអំណាចក្នុងការស្នើ ហើយមិនមានការអ្វីចោទប្រកាន់ទៅលើរូបលោក អំពីថាលោកជាអ្នកទទួលខុសត្រូវចំពោះបញ្ហានេះទេ។ ខ្ញុំយល់លោកនិយាយថា លោកមិនមានអំណាចក្នុងការស្នើសុំដកមនុស្សណានោះទេ។ ថាតើលោកសរសេររបាយការណ៍នេះក្នុងនាមអ្នកផ្សេងទៀតដែលជាអ្នកមានអំណាចក្នុងការដកមនុស្សទាំងនោះ ហើយលោកធ្វើរបាយការណ៍ក្នុងនាមអ្នកនោះ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំធ្វើការ គឺខ្ញុំរាយការណ៍តាមដូចខ្ញុំបានបញ្ជាក់ខាងដើមហើយ។ សភាពការណ៍យ៉ាងម៉េចៗ ខ្ញុំរាយការណ៍ប៉ុណ្ណឹងហើយ។ គេទៅកែច្នៃ ជួនកាលគេដាក់ឈ្មោះខ្ញុំ ក៏លោកក្តាប់មិនបានដែរ។ ហើយធម្មតា គឺខ្ញុំគ្មានសិទ្ធិអីទៅ ដូចខ្ញុំបញ្ជាក់ខាងដើម។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំមានប្រធានបទចុងក្រោយមួយដែលខ្ញុំចង់សួរលោកបន្ត ហើយបន្ទាប់មកគឺខ្ញុំនឹងបញ្ចប់។ នេះនិយាយអំពីអង្គភាពមួយគឺហៅថា “សភាតំណាងប្រជាជនកម្ពុជា” នៅឆ្នាំ១៩៧៦ តើលោកបានដឹងអំពីអង្គភាពមួយដែលហៅថា សភាតំណាងប្រជាជនកម្ពុជាដែរឬទេកាលនោះ?

[១០:២៤:០៣]

**ឆ៖** ខ្ញុំអត់បានដឹងទេ ប៉ុន្តែគ្រាន់តែឮ ហើយមិនដែលបានចូលរួមសភាប្រជាជនអីទេ។

**ស៖** តើលោកបានដំណឹងពីអ្នកណាម្នាក់ដែរឬទេ ថានៅពេលដែលកម្ពុជាប្រជាធិបតេយ្យរដ្ឋាភិបាលបានប្រកាសអំពីការជ្រើសតាំងសមាជិកសភាតំណាងប្រជាជនកម្ពុជានៅខែមីនា ឆ្នាំ១៩៧៦ ហើយគេដាក់ឈ្មោះលោក -- មនុស្សមួយចំនួនជាតំណាងកងទ័ពបដិវត្តន៍កម្ពុជានៅកាលនោះផង?

**ឆ៖** បាទ តាមពិត គឺមេបញ្ជាការខ្ញុំគាត់បានប្រាប់ដែរ គាត់ថា ឥឡូវគេរៀបចំស្អីដូចបានបញ្ជាក់អំមិញអ៊ីចឹង ខ្ញុំភ្លេចហើយ។ គឺក្នុងកងពលខ្ញុំគឺគាត់ប្រាប់ដែរ គឺថាមានតែគាត់ ០៥ ហ្នឹងឯង និង ០៦ នេះឯង។ ហើយតាំងពីនោះមកគាត់ថា អ្ហែ! ឥឡូវត្រូវរៀបចំធ្វើអី បើតាំងពីនេះមកមិនដែលឃើញប្រជុំឃើញអីយ៉ាងម៉េចៗផង បាទ។

**ស៖** តើលោកដឹងដែរឬទេថា តាមពិតនោះតើមានការបោះឆ្នោត ឬក៏ការជ្រើសទេនៅទីតាំងរបស់លោកនៅខេត្តស្ទឹងត្រែងនោះ នៅខែមីនា ឆ្នាំ១៩៧៦? តើមានការបោះឆ្នោតនៅទីនោះទេ នៅស្ទឹង

ត្រែង ដើម្បីជ្រើសតាំងសមាជិកសភាតំណាងប្រជាជនកម្ពុជានៅកាលនោះ?

[១០:២៦:១៧]

**ឆ៖** គ្មានទេ តាមខ្ញុំមើលដូចគ្នាបានប្រជុំ បានបោះឆ្នោតអីទេ។ ការងារអីគឺសម្រេចទៅយកទៅប្រាប់ៗយកទៅផ្សាយហ្នឹងតែម្តង ដូច្នេះបើមានការប្រជុំពិនិត្យអំពីប្រជាធិបតេយ្យខ្ញុំឃើញថា ដូចជាមិនដែលឃើញមាន។ ហើយការងារអីក៏ដោយគឺសម្រេច ឧទាហរណ៍ថា អ្វីក៏ដោយគឺថាមាន ជាមតិអីក៏ដោយគឺមានច្រើនតែសរសេរហើយហ្នឹង យកទៅឲ្យអានឲ្យគេស្តាប់តែម្តង។ ដូច្នេះការប្រជុំធ្វើ ឬក៏ជាលទ្ធិប្រជាធិបតេយ្យ ឬក៏ធ្វើឲ្យមាន ឲ្យថាទូលំទូលាយគឺអត់បាទ។ ដូច្នេះការប្រជុំដូចបាន ក្នុងសំណួរនេះខ្ញុំថាអត់ដែលឃើញមាន។ តែបើក្នុងមូលដ្ឋានដែលគេធ្វើអីយ៉ាងម៉េចក៏ខ្ញុំមិនដឹងដែរ ព្រោះខ្ញុំនៅខាងជួរមុខនោះ គឺខ្ញុំក្តាប់មិនបាន ប៉ុន្តែដូចជាអត់មានដល់ដំណាក់កាលធ្វើមីទ្ទិង ឬក៏អីយ៉ាងម៉េចទេ គឺអត់ឃើញ។

**ស៖** តើពេលណាមួយគេអញ្ជើញលោកទៅចូលរួមប្រជុំនៅក្នុងការប្រជុំរបស់សភាតំណាងប្រជាជនកម្ពុជាដែរឬទេ នៅសម័យនោះ?

**ឆ៖** បាទ ខ្ញុំគឺមិនដែលបានទៅប្រជុំទេបាទ ហើយក៏មិនដែលថា ខ្ញុំមានឈ្មោះក្នុងសភានោះដែរ។ ដូចខ្ញុំបានបញ្ជាក់ខាងដើម ប៉ុន្តែមេបញ្ជាការខ្ញុំគាត់ប្រាប់ថា មានឈ្មោះ សាន ហើយគាត់តែប៉ុណ្ណោះឯង។ តែការប្រជុំអីខ្ញុំមិនដឹងទេ មិនដឹងប្រជុំសភារបៀបម៉េចផង។

**ស៖** តើលោកធ្លាប់បានបោះឆ្នោតទៅលើសេចក្តីព្រាងច្បាប់ ឬក៏បទបញ្ជាអ្វីទេ ដែលសភាតំណាងប្រជាជនគេបានធ្វើជាសេចក្តីព្រាង ឬក៏ច្បាប់អ្វីនោះ? បាទ តើលោកធ្លាប់បានឃើញមានសេចក្តីព្រាងច្បាប់ ឬក៏ច្បាប់អ្វីមួយដែលគេស្នើឲ្យលោកពិនិត្យមើលដើម្បីផ្តល់ការអនុម័តយល់ព្រមក្នុងនាមជាសភាតំណាងប្រជាជនកម្ពុជាដែរឬទេ?

[១០:២៩:០៣]

**ឆ៖** បាទ ដូចខ្ញុំបានជម្រាបខាងដើមអ៊ីចឹង គឺអត់មានទេ។

**លោក ខេល លីសាក់៖**

សូមអរគុណលោក អ៊ុង វ៉ែន ដែលលោកបានព្យាយាមឆ្លើយនូវសំណួរដ៏ច្រើនទាក់ទងទៅនឹងបញ្ហាមួយចំនួន ហើយសូមអរគុណដែលលោកបានចំណាយពេលវេលា។ ហើយសូមអរគុណលោកប្រធាន លោកស្រីចៅក្រម ខ្ញុំអត់មានសំណួរអ្វីទៀតទេ បាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណណាស់លោកតំណាងសហព្រះរាជអាជ្ញា ហើយការប្រើប្រាស់ពេលវេលារបស់លោកព្រះរាជអាជ្ញា គឺរួមទាំងពេលវេលាដែលចែកឲ្យទៅមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ឃើញថា អស់ត្រឹមហ្នឹងហើយ។ ហើយក៏ស្រួបពេលដែលដល់ពេលសម្រាកផងដែរ។

អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្រាបសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះសម្រាកនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនេះវិញ នៅវេលាម៉ោងដប់មួយខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣០ នាទី ដល់ម៉ោង ១០:៥៣ នាទី)*

[១០:៥៣:១១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយមុននឹងផ្ដល់វេទិការទៅក្រុមមេធាវីការពារក្ដី ខ្ញុំសូមសួរទៅលោក លោកស្រីចៅក្រម តើមានសំណួរអ្វីចង់សួរដល់សាក្សីរូបនេះដែរឬទេ?

បាទ ប្រសិនបើមានសូមអញ្ជើញ។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោកសាក្សីខ្ញុំឈ្មោះចៅក្រម ឡាវែន៍ ខ្ញុំមានសំណួរមួយចំនួនចោទសួរលោក។

ដើម្បីបំពេញបន្ថែមទៅលើសំណួររបស់សហព្រះរាជអាជ្ញាអម្បាញ់មិញនេះ គឺទាក់ទងទៅនឹងសភាតំណាងប្រជាជន។ បើសិនជាខ្ញុំយល់មិនច្រឡំទេ អំពីចម្លើយរបស់លោកកាលពីព្រឹកមិញនេះ គឺថាលោកបានឆ្លើយថាលោក ដឹងថាឈ្មោះលោកមាននៅក្នុងបញ្ជីសភាតំណាងប្រជាជននៅក្នុងប្រភេទគេហៅថាអ្នកតំណាងឲ្យកងកម្លាំង ហើយលោកដឹងរឿងនេះនៅពេលដែលមានសេចក្ដីសម្រេចនោះ គេធ្វើរួចទៅហើយ។ តើខ្ញុំយល់យ៉ាងដូច្នេះត្រឹមត្រូវដែរឬទេ?

**លោក អ៊ុង វ៉េន៖**

**ឆ៖** ខ្ញុំសូមឆ្លើយចំពោះសំណួរនេះ ដូចខ្ញុំបានបញ្ជាក់ពីមុនហើយ។ តាមពិតគឺក្នុងអង្គភាពដែលប្រាប់ខ្ញុំនោះគឺមានតែពីររូបនេះឯង ឯសម្រាប់ខ្ញុំវិញ ខ្ញុំអត់ដឹង អត់ដឹងទេ បាទ អត់ដឹងថាខ្ញុំមានឈ្មោះក្នុង នៅក្នុងនុ៎ងទេ។

**ស៖** តើលោកដឹងនៅពេលណាមួយ ថាឈ្មោះលោកស្ថិតនៅក្នុងចំណោមអ្នកតំណាងឲ្យសភាតំណាងឲ្យប្រជាជន។ តើក្នុងពេលណាមួយលោកបានដឹងទេ?

**ឆ៖** ខ្ញុំទាល់តែប្រជុំម្ដងហើយ បានថ្ងៃក្រោយមកបានមេបញ្ជាការខ្ញុំថា មាននៅក្នុងន៎ែ ឈ្មោះនៅក្នុងហ្នឹងដែរ។ ប៉ុន្តែកន្លងមក តាំងពីដឹងថាមានឈ្មោះដែរ ប៉ុន្តែអត់ដែលឃើញបានប្រជុំបានស្អី ដឹងសភាហ្នឹងគេប្រជុំរបៀបណា អីរបៀបណាទេ។ ប៉ុន្តែដឹងថាសភាតំណាងឲ្យ ឧទាហរណ៍ខាងទាហានគឺតំណាងឲ្យទាហានទៅ គឺនៅខាងប្រជាជនទៅ តែប៉ុណ្ណឹង។ ដូច្នេះរបៀបវារៈ កន្លែងប្រជុំសភាយ៉ាងម៉េចៗអី ខ្ញុំអត់ដែលបានប្រជុំទេ។

[១០:៥៦:៣២]

**ស៖** តើនៅពេលណាមួយនោះ នៅពេលគេពន្យល់ប្រាប់លោកថា អំពីតួនាទីនិងមុខងារ មុខការនៃសភាតំណាងប្រជាជននេះ តើមានពេលណាមួយគេពន្យល់ប្រាប់លោកពីមុខងារ ហើយនិងមុខការនៃសភាតំណាងប្រជាជននេះទេ?

**ឆ៖** បាទ គ្រាន់តែដឹងថាមានឈ្មោះក្នុងហ្នឹង ប៉ុន្តែអំពីរបៀបរបបសភាអីយ៉ាងណាៗ ដូចខ្ញុំបានបញ្ជាក់ពីខាងដើម ព្រោះមិនដែលបានប្រជុំ មិនដែលបានរៀនសូត្រអីពីរបៀបរបបនេះទេ រហូតទល់នឹងសព្វថ្ងៃនេះក៏ តាំងពីនោះមកដល់ឥឡូវក៏មិនដែលឃើញ ថាវាខ្ចាត់ខ្ចាយអស់ទៅចុះ ប៉ុន្តែរហូតដល់តាំងពីដឹងថាមានឈ្មោះក្នុងនុ៎ង ហើយដោយសារកងពលប្រាប់ ហើយតាំងពីកងពលប្រាប់មកមិនដែលឃើញការប្រជុំអីយ៉ាងម៉េចៗអី ដូចខ្ញុំបានបញ្ជាក់ពីខាងដើមអ៊ីចឹង។

[១០:៥៧:៤២]

**ស៖** បាទ នៅក្នុងសំណុំរឿង យើងមានឯកសារពីរដែលខ្ញុំយល់ឃើញថា វាមានលក្ខណៈពាក់ព័ន្ធ គឺឯកសារទី១ គឺថាជាកំណត់ហេតុវ៉ាដ្យូ ផ្សាយវ៉ាដ្យូនៅថ្ងៃទី២២ មីនា ឆ្នាំ១៩៧៦ គឺជាសេចក្ដីសង្ខេបនៃការផ្សាយព័ត៌មានអំពី ប៊ី.ប៊ី.ស៊ី នៅក្នុងការផ្សាយចេញពីក្បូតូញូវស៍ ហើយថាក្នុងឯកសារនេះគឺមានលេខកូដដូចតទៅ គឺថា E3/1241 ហើយលេខ ERN ជាភាសាអង់គ្លេសគឺ 00081741 ទៅដល់ 46, ជាភាសាខ្មែរគឺ 00323878 ទៅដល់ 323888, ជាភាសាបារាំង 00662284 ទៅដល់ 00662290។ បាទ នៅក្នុងឯកសារទី១ មានសរសេរដូចតទៅ "សម្រង់កិច្ចប្រជុំនៃសភាតំណាងរាស្ត្រ ដែលចុះហត្ថលេខាលោក ខៀវ សំផន ហើយនិង សុក ណោត ឬ សុក ជុត (តាមសំឡេងដើម)។ សម្រាប់គណៈកម្មការ ដែលជ្រើសតាំងដោយ ហ៊ូ នឹម ដែលជារដ្ឋមន្ត្រីក្រសួងឃោសនាការ។ បន្ទាប់ពីចុះប្រជាជនយើងមានចំនួន ៧លាន--

[១០:៥៩:៤០]

**អ្នកបកប្រែ៖**

លោកប្រធាន សូមឲ្យគាត់អានលេខសាថ្មី លេខ លឿនពេក។

**ប្រធានអង្គជំនុំ៖**

លោកចៅក្រម សូមលោកអាននូវលេខ ERN ឡើងវិញ ពីព្រោះអ្នកបកប្រែ បកប្រែមិនទាន់ទេ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ERN ជាភាសាអង់គ្លេសគឺ 00081741 ទៅ 46, ជាភាសាខ្មែរគឺ 003878 *(ស៊ីក)* ទៅ 88, ជាភាសាបារាំង 0076 -- 00662284 ទៅដល់ 90 លេខនៅចុងកន្ទុយ។ បាទទាក់ទងទៅនឹងតួលេខអម្បាញ់មិញ ខ្ញុំនិយាយអម្បាញ់មិញនេះ គឺបើតាមការចុះ ការបោះឆ្នោតនោះប្រជាជនយើងមានចំនួនទូទៅ គឺថា៧លាន -- ជាង៧លាននាក់។ ប្រជាជនដែលមានអាយុលើសពី១៨ អ្នកដែលចូលរួមបោះឆ្នោតនោះឡើង មានចំនួន៣លាន ៤សែននាក់ជាង ហើយបី -- គឺស្មើនឹង ៩០ភាគរយនៃចំនួនមនុស្សដែលអាចមានសិទ្ធិបោះឆ្នោតបាន។ ចំនួនបេក្ខជននៅសភា គឺ៥១៥នាក់ ហើយក្នុងលើនោះមានចំនួន២១៥ ដែលត្រូវបានជ្រើសរើស។ ហើយសភានោះចាប់ដំណើរការពីមីនា ឆ្នាំ១៩៧៦ ទៅដល់ ឆ្នាំ៨១។ ហើយបន្ទាប់នេះមានបញ្ជីតំណាងរាស្ត្រ តំណាងប្រជាជនមួយចំនួនទៀត នៅក្នុងទំព័រចុងក្រោយនៃឯកសារនេះ គឺថានៅលេខរៀងទី១៥ យើងមានឃើញមានឈ្មោះ អ៊ុង វ៉ែន។ លេខអម្បាញ់មិញនេះ

លេខ២៥ ឈ្មោះ អ៊ុង វ៉ែន។ លោកតើលោកស្គាល់សេចក្ដីប្រកាសនេះទេ? គឺថាសេចក្ដីប្រកាសតាមវ៉ាដ្យូនេះលោកសាក្សី។

[១១:០២:៣៩]

**លោក អ៊ុង វ៉ែន៖**

**ឆ៖** បាទ ខ្ញុំដូចខ្ញុំបញ្ជាក់ពីដើមហើយ គឺក្នុងសេចក្ដីប្រកាសតាមវិទ្យុអី វ៉ាដ្យូនេះគឺខ្ញុំមិនបានដឹងទេ។ ដឹងគឺថាដោយសារមេកងពលខ្ញុំជម្រាប ដូចជាបានជម្រាបពីខាងដើមអ៊ីចឹង។ ដូច្នេះខ្ញុំជម្រាបបានតែប៉ុណ្ណឹង។

**ស៖** បាទ ឥឡូវយើងមានឯកសារមួយទៀត ដែលពាក់ព័ន្ធដែរ គឺឯកសារ E3/165 គឺជាឯកសារដែលត្រូវបង្ហាញទៅសាក្សី។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូម -- លោកប្រធានខ្ញុំសូមការអនុញ្ញាតជូនឯកសារនេះទៅលោកសាក្សី លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីចៅក្រម យកជូនសាក្សីពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[១១:០៤:៤៩]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** បាទ ឯកសារនេះគឺជាឯកសារចេញមកពីខាងទួលស្លែង ដែលទាក់ទងទៅនឹងសភាតំណាងប្រជាជន ហើយនិងកិច្ចប្រជុំសមាជសន្និបាតលើកទី១ ដែលកើត -- ដែលប្រព្រឹត្តទៅនៅថ្ងៃទី១១ ដល់ ១៣ មេសា ឆ្នាំ១៩៧៦ គឺជាឯកសារចេញពីមន្ទីរស-២១។ លេខ ERN គឺជាភាសាបារាំង 00301334 ទៅដល់ 00301362, ERN ជាភាសាខ្មែរគឺ 00053603 ទៅដល់ 00053645 ហើយជាភាសាអង់គ្លេស ខ្ញុំឃើញមាន ERN គឺថា 00184048។ គឺខ្ញុំមិនច្បាស់អំពីលេខ ERN នេះទេពីព្រោះថាទំព័រចុងក្រោយខ្ញុំអត់មាន។ លោកសាក្សី តើលោកស្គាល់ឯកសារនេះដែរឬទេ ដែលនៅក្នុងឯកសារនេះគឺថាយើង ឃើញថានៅទំព័រទី ERN ជាភាសាខ្មែរហ្នឹងថា 00360607 គឺថាមានរូបថតមួយដែលមានចំណងជើងដូចតទៅនេះ “ព្រឹកថ្ងៃទី១១ មេសា ឆ្នាំ១៩៧៦ សមាជិកទាំង២៥០នាក់ នៃសភាតំណាងប្រជាជនកម្ពុជាបានមកពីតាមមូលដ្ឋាន ហើយនិងអង្គភាពផ្សេងៗទូទាំងប្រទេសតែម្ដង ដើម្បីចូលរួម

នៅក្នុងសមាជទី១ នៃសភាតំណាងប្រជាជនកម្ពុជា"។ នេះគឺជាទិសដៅទូទៅមុននឹងចាប់ផ្ដើមប្រជុំជាចំណងជើងទូទៅ។ ខ្ញុំមិនដឹងថាលោកឃើញចំណង -- រូបថតនិងចំណងជើងនេះដែរឬអត់ទេ? ខ្ញុំមិនដឹងថាលោកដឹង ធ្លាប់ឃើញឯកសារនេះ ឬក៏ទេ? ឬក៏អត់ទេ? តើលោកអាចធ្វើការអត្ថាធិប្បាយខ្លះបានដែរឬទេ លើឯកសារនេះ?

[១១:០៦:២៣]

**ឆ៖** បាទ ខ្ញុំសូមឆ្លើយនឹងសំណួរនេះគឺ ខ្ញុំនៅតែ -- តាំងថាខ្ញុំមិនបានដឹង ពីព្រោះទាល់តែការប្រជុំហើយអីហើយហ្នឹង បានគាត់ប្រាប់ខ្ញុំដូចជម្រាបពីមុន។ ប្រាប់ថាខ្ញុំមានឈ្មោះនៅក្នុងសភានេះដែរនេះទី១។ ទី២ ចំពោះឯកសារនេះ ខ្ញុំអត់ៗដែលឃើញ អត់ដែលៗឃើញទេ។

**ស៖** បាទ លោកសាក្សីនេះជាសំណួរចុងក្រោយរបស់ខ្ញុំ ដើម្បីឲ្យច្បាស់ថាយើងយល់គ្នា។ តើលោកធ្លាប់បានឮ និយាយអំពីមុខងារសភានេះនៅពេលដែលមានការតែងតាំងប្រធាន គណៈប្រធានរដ្ឋ ទាក់ទងទៅនឹងការតែងតាំងសមាជិករដ្ឋាភិបាលថ្មី ទាក់ទងទៅនឹងការតែងតាំងគណៈអចិន្ត្រៃយ៍នៃកម្ពុជាប្រជាធិបតេយ្យ។ ទាក់ទងទៅនឹងការតែងតាំងគណៈកម្មាធិការតុលាការ ព្រមទាំងទាក់ទងទៅនឹងសេចក្ដីណែនាំសភាតំណាងប្រជាជនកម្ពុជា ទាក់ទងទៅនឹងការដឹកនាំទិសដៅគោលនយោបាយក្នុងប្រទេសនិងក្រៅប្រទេស និងនៅក្នុងគណៈប្រធានរដ្ឋ ហើយនិងក្នុងចំណោមសមាជិករដ្ឋាភិបាល។ តើនៅក្នុងចំណោមសេចក្ដីណែនាំទាំងអស់នេះ តើមានការអនុវត្តគ្រប់ជ្រុងជ្រោយទាំងអស់ និងនៅក្នុងជំពូកទាំងអស់? តើលោកមានការយល់ឃើញយ៉ាងម៉េចដែរ ទាក់ទងនឹងអ្វីដែលខ្ញុំអានអម្បាញ់មិញនេះគឺថានៅក្នុងរដ្ឋធម្មនុញ្ញក៏មាននិយាយអ្វីខ្លះ? ហើយនិងទាក់ទងនឹងការតែងតាំងបុគ្គលិក សមាជិករដ្ឋាភិបាលអីជាដើមនេះ លោកមានយល់ មានគំនិតអ្វីខ្លះទេដែលចង់ផ្ដល់ជូនទៅតុលាការ?

[១១:០៨:៤៧]

**ឆ៖** ខ្ញុំសូមឆ្លើយនឹងសំណួរ។ នេះគឺតាមពិតគឺខ្ញុំយល់តែខ្ញុំបានដឹងគឺ ឧទាហរណ៍ ចាត់តាំងជាក្រុម ចាត់តាំងជាកងពល ចាត់តាំងជាអី ខ្ញុំឃើញថាមាន។ ប៉ុន្តែចាត់តាំងជាស្អីផ្សេងៗទៀតទៅលើៗ ខ្ញុំអត់ដែលបានដឹងទេ។ បាទ ខ្ញុំអត់ដែលបានដឹងទេ។ ហើយអត់ដែលឮថាមានការសម្រេចប្រជុំ ពិគ្រោះពិភាក្សាយ៉ាងម៉េច ចាត់ចែងយ៉ាងម៉េចៗ ជួយ រៀបរយយ៉ាងម៉េចអី គឺអត់មានទេ។ ដូចខ្ញុំបានបញ្ជាក់ពីខាងដើមអ៊ីចឹង។ បើការងាររបស់ខ្ញុំ គឺរៀបរយម៉េច ឧទាហរណ៍ចាត់តាំងរៀបចំអង្គភាពយ៉ាងម៉េចៗ អាហ្នឹង ខ្ញុំឃើញ។ ប៉ុន្តែចាត់តាំងរៀបចំអ្នកដឹកនាំ ឬក៏អចិន្ត្រៃយ៍អីយ៉ាងម៉េចៗ អាហ្នឹងខាងលើ ខ្ញុំក្ដាប់

មិនបានទេ ព្រោះខ្ញុំអត់បានទៅចូលរួម។

[១១:១០:០៥]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ លោកសាក្សីខ្ញុំសូមអរគុណ។ បាទ លោកប្រធាន ខ្ញុំអស់សំណួរសួរទៅលោកសាក្សីហើយ លោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណចៅក្រម។ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក សុន អរុណ៖**

**ស៖** ហើយជម្រាបសួរលោក អ៊ុង វ៉ែន។ ខ្ញុំឈ្មោះ សុន អរុណ មេធាវីការពារលោក នួន ជា។ ខ្ញុំមានសំណួរមួយចំនួននៅព្រឹកនេះដើម្បីសួរលោក។

សំណួរទី១ នៅក្នុងឯកសារដែលខ្ញុំបានទទួលមកទាំងប៉ុន្មាន ហាក់ដូចជាមិនសូវច្បាស់អំពីប្រវត្តិរបស់លោកផ្ទាល់។ ម្ល៉ោះហើយបើសិនជាលោកអាច ខ្ញុំសូមឲ្យលោកជម្រាបតុលាការម្តងទៀតអំពីប្រវត្តិរបស់លោកផ្ទាល់ តើលោកបានចូលបដិវត្តន៍ពីពេលណា? ហើយចាប់ពីពេលចូលបដិវត្តន៍មកលោកពេលនោះលោកបានធ្វើជាអ្វី? ហើយមានឋានៈជាអ្វី?

**លោក អ៊ុង វ៉ែន៖**

**ឆ៖** បាទ ខ្ញុំសូមឆ្លើយសំណួរនេះ គឺពីមុនមកគឺដំបូង គឺមានឈ្មោះ ហេង មេឃុំនៅភូមិខ្ញុំហ្នឹង គាត់ណែនាំឲ្យរួបរួមគ្នាជាកម្លាំងៗ។ ហើយខ្ញុំគឺយល់ថាបញ្ហានេះ គឺតាមពិតក៏ចង់បានដែរ គឺរួបរួមកម្លាំង សាមគ្គីគ្នាដើម្បីធ្វើការងារ ឬធ្វើអ្វីមួយ បើបែកបាក់កម្លាំង អត់មាន -- បើបែកបាក់កម្លាំងគឺធ្វើអីក៏មិនបានដែរ។ ដូច្នេះគាត់ ពីបញ្ហាហ្នឹងគឺ នេះគឺចង់និយាយថា ការទូន្មាន ការអប់រំរបស់គាត់គឺអ៊ីចឹងហើយ គឺថាឈ្មោះ ហេងៗ នេះឯង។

[១១:១២:២២]

ហើយដល់តែក្រោយៗមកទៀត ខ្ញុំមិនចាំថ្ងៃចាំខែទេ គឺកន្លងគឺមានបញ្ហា ហៅថា គេហៅថា កុបកម្មនោះ បាទ។ បាទ គាត់ថាឥឡូវនៅស្រុកមិនបានទេ ពួកទាហាន លន់ នល់ ដេញអ៊ីចេះអ៊ីចុះក៏រត់ចូលព្រៃ។ ចូលព្រៃបានមួយខែពីរ ហ្នឹងនៅឆ្នាំ៦៨ហើយ។ ១ខែ២ខែ ខ្ញុំក៏ត្រឡប់មកផ្ទះវិញបាទ។ មកផ្ទះវិញ ដល់១៩៧៩ -- ចុងឆ្នាំ១៩៧៩ នេះខ្ញុំក៏ចូលមកម្ដងទៀត អ៊ីចេះ។ ចូលម្ដង ហើយដល់ពេលអ៊ីចឹងទេ ទទួលឆ្នាំ៧០ នេះរដ្ឋប្រហារដោយសារសម្ដេច នរោត្តម សីហនុ នេះត្រូវរដ្ឋប្រហារនេះ ក៏ប្រកាសទៅ ក៏ចេះតែចូលតៗរហូត។ ដល់អ៊ីចឹងទេមកនៅវត្តថ្មីដងទង់នេះ ក្រោយមកទៀតមកនៅវ៉ាបាត់ដឹងនេះ មានឈ្មោះដូចខ្ញុំថាអ៊ីចឹង គឺ ចេង អន និង សឿន ហើយ លឿន គាត់ជាអ្នកទទួលខុសត្រូវនៅនោះ។ ហើយខ្ញុំក៏នៅធ្វើសកម្មភាពនៅម្ដុំនោះ មាន -- គាត់ឲ្យខ្ញុំធ្វើជានៅក្នុងនោះជាយុវជន បាទ។ ហើយដល់បានកម្លាំងច្រើនមកហើយ រៀបចំជាក្រុម ជាពួក រហូតដល់កងតូច មកឈរជើងនៅភ្នំអដ្ដរស្ស អមៗអដ្ដរស្សមកដល់នេះ ក៏រត់ទៅទាហានទៅ។ មកឈប់ឈរខាងត្បូងអដ្ដរស្សហ្នឹង អ៎!ខាងលិចអដ្ដរស្ស ភ្នំ -- អដ្ដរស្ស ប៉ុន្តែអូរខាងនេះភ្នំ ផ្លូវ២៦ ហើយរហូតមកក៏ទទួលធ្វើជាអនុសេនាធំឯករាជ្យនៅម្ដុំនោះ។ បាទ អាហ្នឹងខ្ញុំចង់បញ្ជាក់ប៉ុណ្ណឹង។

[១១:១៤:៤១]

**ស៖** អ៊ីចឹងខ្ញុំសូមបញ្ជាក់ម្ដងទៀត លោកបានចូលធ្វើកងបដិវត្តន៍យោធានៅឆ្នាំ១៩៧០ ពេលក្រោយពេលទម្លាក់សម្ដេច សីហនុ អ៊ីចឹងណ៎ាប្រាកដ។ ហើយពេលដែលលោកចូល ចូលនៅភ្នំអដ្ដរស្សពេលហ្នឹងលោកមានឋានៈជាអ្វីនៅក្នុងកងទ័ព?

**ឆ៖** ខ្ញុំសូមឆ្លើយគឺថា នៅខាងលិចអដ្ដរស្ស -- អ៊ូ! ខាងលិចភ្នំប្រសិទ្ធិ៍។ ពេលនោះគឺថាខ្ញុំ មុនដំបូងមកដល់អត់មានកម្លាំងទេ មកជួបជួយ -- ជួប ចេង អន ហ្នឹងគឺគាត់មានកម្លាំងបួនដប់នាក់ ខ្ញុំហ្នឹងឲ្យខ្ញុំហ្នឹងនៅជាមួយនឹងឯង។ ដល់អ៊ីចឹងក៏រៀបចំកម្លាំងមកពីនិរតីខ្លះមក ក៏ឲ្យខ្ញុំទទួលជាកងតូច។ បាន១ខែ២ខែ កម្លាំងចេះក៏កើនទៅ ក៏មាន ក៏ឲ្យកាន់ជាអនុសេនាធំ។ ពីរនាក់ឈ្មោះ សឿន ហើយនិង លឿនបីនាក់ហ្នឹងឯងបាទ។ ដូច្នេះនៅប្រចាំខាងលិចបាត់ដឹងទេ ២៦ គឺមានតែអង្គភាពខ្ញុំទេ។ ហើយក្រោយមកបានមានកម្លាំងមកពីនិរតីមក បានគេរៀបចំវរសេនាធំ។ បាទ រៀបចំវរសេនាធំនៅ ប្រចាំនៅខាងលិចភ្នំប្រសិទ្ធិ៍ហ្នឹងដដែល ហើយធ្វើការមកក្រសាំង មកភូមិម្ហូ មកភូមិ ស្អឹមកកើតៗ ទួលលាភអ៊ីចេះមក។ ហើយភារកិច្ចអង្គភាពនេះ គឺអត់មានធ្វើការងារយុវជនទេ គឺដើរពិនិត្យសភាពការណ៍ខ្មាំង មើលបន្ទាយខ្មាំងអីតែប៉ុណ្ណោះឯង។ សូមអស់។

[១១:១៦:៣៤]

**ស៖** អរគុណ។ លោកថា លោក ចេង អន បានតែងតាំងលោកធ្វើជាកងតូច។ អ៊ីចឹងកងតូចហ្នឹងគឺមានយោធាប៉ុន្មាន?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ! ចាំ វង់ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការសិន។

**លោក អ៊ុង វ៉ែន៖**

**ឆ៖** បាទ តាមពិតកងតូចហ្នឹង គឺមានតែ៣០នាក់ទេ ព្រោះមួយក្រុមមាន១០នាក់ ហើយបើមានកម្លាំងច្រើន គេរៀបដល់១២នាក់ក៏បានដែរមួយក្រុម។ ដូច្នេះមួយកងតូច ជួនកាលវា៣០ជាង។ ហើយដូច្នេះមួយអនុសេនាធំ វាមានបីអនុសេនាតូច។ ដូច្នេះអនុសេនាតូច ខ្ញុំអត់បានជម្រាបទេ ព្រោះជម្រាប ព្រោះមានបី ដូចជម្រាបមួយកងតូចហ្នឹងក៏អស់លោកយល់ហើយ។

**ស៖** អរគុណ។ សំណួរមួយទៀតសួរថា លោកសាក្សីពេលដែលលោកមកប្រជុំនៅស្តាតអូឡាំពិក ពេលហ្នឹងថ្នាក់ដឹកនាំជាន់ខ្ពស់បានប្រកាសតែងតាំងកងពលលេខ៨០១ និងក្នុងពេលនោះ ថ្នាក់ -- លោកដឹងថាពេលដែលប្រកាសតែងតាំងកងពលលេខ៨០១ហ្នឹង ក្នុងឯកសារដែលចៅក្រមស៊ើបអង្កេតបានសាកសួរលោក លោកបានឆ្លើយថា "ប៉ុល ពត ជាអ្នកប្រកាស"។ លោកដឹងថាពេលនុ៎ង ប៉ុល ពត ហ្នឹងជាអ្វីទេ? មានឋានៈ មានមុខងារ មានមុខបុណ្យស័ក្តិជាអ្វីទេនៅពេលប្រកាសហ្នឹង?

[១១:១៨:៣៣]

**ឆ៖** បាទ ខ្ញុំក្នុងបញ្ហាសំណួរនេះ ខ្ញុំសូមជម្រាបថា ពេលដែលកងទ័ពរួមគ្នាចូលហើយ គឺមានការប្រកាសហ្នឹងគឺនៅស្តាតអូឡាំពិកនេះ គឺមាន គឺថាជារួមមកគឺ ប៉ុល ពត គាត់អ្នកសម្រេច។ ប៉ុន្តែពីមុនមកមុននឹងសម្រេចនេះ ខ្ញុំក៏មិនដែលឃើញទេ។ ប៉ុន្តែគ្រាន់តែឮ តាសុន សេន នេះគាត់និយាយថា ប៉ុល ពតៗ ហ្នឹងហើយ។ ហើយដល់មកប្រកាសក្នុងស្តាតអូឡាំពិកនេះ បានៗស្គាល់។ ដូច្នេះតាំងពីណាពីណីមក ខ្ញុំមិនដែលស្គាល់ទេ។ ដូច្នេះ បានខ្ញុំកំណត់ថា ហើយឮគេនិយាយអ៊ីចឹង បានគេកំណត់ថា នេះប្រហែលជាលេខាបក្ស ឬក៏មជ្ឈិមបក្សហើយ។ បាទ ខ្ញុំជម្រាបប៉ុណ្ណឹង។

**ស៖** សូមលោកសាក្សីបញ្ជាក់ម្តងទៀតថា សុន សេន ថាប៉ុល ពតៗហ្នឹង សូមបញ្ជាក់ម្តងទៀតឱ្យច្បាស់បន្តិចមើល ខ្ញុំដូចជាមិនយល់សម្តីរបស់លោកត្រង់កន្លែងហ្នឹង។

**ឆ៖** តាមពិត ដូចខ្ញុំបានបញ្ជាក់ហើយ គឺថា មុនៗនឹងប្រកាស –ហ្នឹងតាមសំណួរលោកសួរបញ្ជាក់អ៊ីចឹង– តើលោកស្គាល់ថា ប៉ុល ពត ជាអ្វី? នេះខ្ញុំស្ដាប់បានអ៊ីចឹង ហើយខ្ញុំបញ្ជាក់មកវិញថា មុននឹង ប៉ុល ពត ស្គាល់ ប៉ុល ពត នេះ ហើយប្រកាសនេះ ខ្ញុំស្គាល់តាមរយៈ សុន សេន។ បាទ តាមរយៈ ០៦ បាទ។ ដូច្នេះមកប្រកាសនៅស្តាតអូឡាំពិកនេះ គឺបានខ្ញុំស្គាល់ថានេះជា ប៉ុល ពត។ នេះជា សុន សេន។

**ស៖** អរគុណ។ សុន សេន បានប្រាប់លោកថា ប៉ុល ពតៗ លោកបានជួប សុន សេន មុនមហាសន្និបាតនៅអូឡាំពិកហ្នឹង ពីកាលណា? មុនប៉ុន្មានថ្ងៃ? ឬក្រោយពេលប្រកាសហ្នឹងហើយ?

**ឆ៖** បាទ បញ្ហានេះ ដូចខ្ញុំបានជម្រាបម្ដងរួចទៅហើយ តាមពិត គឺមុននឹងចូលវ៉ៃទីក្រុងភ្នំពេញបាននេះ គឺខ្ញុំផ្ទាល់ និងកងពល។ ខ្ញុំនិងកងពល សុន សេន អញ្ជើញទៅជួបនៅវ៉ាដំណាក់ស្នាច់ បាទ។ ហើយណែនាំឲ្យវ៉ៃ បានស្គាល់តាមរយៈនោះឯង។ ហ្នឹងហើយ។

[១១:២១:៥១]

**ស៖** លោកបានជួប សុន សេន ផ្ទាល់នៅពេលវ៉ា -- អំមិញនិយាយថា វ៉ាណាន៎ុង ហើយផ្ទាល់បាននិយាយផ្ទាល់ជាមួយលោក ឬក៏លោកឮតាមរយៈគេប្រាប់?

**ឆ៖** បាទ ខ្ញុំបានទៅប្រជុំផ្ទាល់តែម្ដង។ អត់មានឮតែគេនិយាយទេ។

**ស៖** ពេលដែលលោកបានចូលប្រជុំផ្ទាល់ជាមួយលោក សុន សេន លោកដឹង សុន សេន ហ្នឹងជាអ្វីទេ? មានមុខងារជាអ្វី? មានឋានៈជាអ្វី?

**ឆ៖** បាទ ក្នុងសំណួរនេះ គឺខ្ញុំបញ្ជាក់ថា កាលដែលខ្ញុំទៅជួប សុន សេន នៅពេលនោះ ខ្ញុំយល់ថា គឺគាត់ជាអ្នកដឹក ហើយគាត់ជាអ្នកធំ ពីព្រោះធម្មតាបើអ្នកតូចតាចគេហៅមេខ្ញុំទៅប្រជុំយ៉ាងម៉េចនឹងបាន។ ដូច្នេះខ្ញុំកំណត់ពេលនោះថាគាត់ជាអ្នកដឹកនាំហើយ ហើយម្យ៉ាង ០៦ នេះ ដែលនៅ ដែលមេកងពេលនេះ គឺចេញមកពី សុន សេន នេះឯង។ ហៅ តាវ៉ែនតាៗ ពេលនោះ អត់មានហៅ សុន សេន ទេ ហៅ តាវ៉ែនតាៗទេ។ ដូច្នេះ គឺបានន័យថា ម្នាក់នេះឯងគឺអ្នកធំ ហើយម្នាក់នេះឯងជាអ្នកដឹកនាំហើយ។ ខ្ញុំមានប៉ុណ្ណឹងឯង។

[១១:២៣:៣៣]

**ស៖** ចម្លើយរបស់លោកហាក់ដូចជាច្របូកច្របល់បន្តិច ថាលោក -- សុន សេន ខ្ញុំសួរបញ្ជាក់ថា មានឋានៈជាអ្វី? មុខងារជាអ្វី? ហេតុអ្វីបានជាទៅនិយាយប្រាប់លោកថា ប៉ុល ពត ប្រកាសកងពល

អីៗអ៊ីចឹង។ អ៊ីចឹងអ្នកណាឲ្យតែអ្នកធំទៀត អាចប្រកាសបានអ៊ីចឹងដែរឬទយ៉ាងម៉េច?

**ឆ៖** បាទ ខ្ញុំបញ្ជាក់ថា បញ្ហាដែលខ្ញុំជួប សុន សេន នេះ មុនវ៉ៃភ្នំពេញ។ បាទ មុនវ៉ៃភ្នំពេញហើយខ្ញុំស្គាល់នេះ ក៏យល់ថា មិនដឹងជា សុន សេន ហ្នឹងគាត់ជាអ្នកដឹកនាំ ឬក៏អីទេ ប៉ុន្តែហេតុអីបានជាហៅប្រធានកងពលទៅប្រជុំបាន។ ខ្ញុំៗកំណត់ថា គាត់ជាអ្នកដឹកនាំជាន់ខ្ពស់ហើយ។ បាទ ហ្នឹងមួយ។ ប៉ុន្តែទី២ តាមរយៈ ០៦ ទេ គាត់ថា តាវ៉ែនតា បាទ។ តាវ៉ែនតា គាត់ ដល់អ៊ីចឹងគាត់ប្រាប់ថា តាកៀវ តែប៉ុណ្ណោះឯង។

**ស៖** គេប្រាប់លោកថា តាកៀវ, តាវ៉ែនតា ទាំងអស់ហ្នឹងលោកនៅតែមិនដឹងថាលោកមាន -- ថា សុន សេន មានបុណ្យស័ក្តិ ឬក៏មុខងារជាយោធា ជាស៊ីវិលអីអត់ដឹងដែរ?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេមុខងារជាស៊ីវិលអី ខ្ញុំអត់បានដឹងទេ រហូតមកដល់វ៉ៃភ្នំពេញឈ្នះហ្នឹងក៏ខ្ញុំក៏មិនដឹងលោកណាជាមេ លោកណាជា "ក" ប៉ុន្តែគ្រាន់ថាការវ៉ៃចូលភ្នំពេញនេះគឺមាន សុន សេន នៅពីក្រោយ ហើយទន្ទឹមនឹងនោះភារកិច្ចរបស់ខ្ញុំដែលចូលវ៉ៃភ្នំពេញនេះគឺ ខ្ញុំមានសិទ្ធិវាយការណ៍ត្រឹមតែកងពលរបស់ខ្ញុំទេ។

[១១:២៥:៤៣]

**ស៖** អរគុណ ខ្ញុំបានច្បាស់ចម្លើយរបស់លោក។ សំណួរខ្ញុំបន្តទៅទៀតថា នៅពេលដែលធ្វើមហាសន្និបាតនៅស្តាតអូឡាំពិក ពេលហ្នឹងលោកបានជម្រាបតុលាការថា មានបួននាក់ជាអធិបតី។ បួននាក់ហ្នឹងមាន ប៉ុល ពត, មាន នួន ជា, មាន អៀង សារី, មាន -- អៀង សារី, នួន ជា, មាន សុន សេន។ បើខ្ញុំនិយាយខុសសូមលោកកែផង អ៊ីចឹងត្រូវទេ?

**ឆ៖** បាទ ត្រូវ។

**ស៖** លោកដឹងថាបីនាក់ទៀត ក្រៅពីប៉ុល ពត មានមុខងារជាអ្វីទេ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា តាំងពីរំដោះភ្នំពេញមកទល់នឹងពេលបែកបាក់គ្នាភ្នំពេញនេះ វាមិនដឹងលោកណាជាប្រធាន មិនដឹងជាលោកណាធំប៉ុន្មាននាក់ នរណាធំបន្ទាប់ទី១ ទី២ទេ ប៉ុន្តែគ្រាន់ដឹងថា ប៉ុល ពត ជាទី១, អ៊ំ នួន ជា ជាទី២ ហើយក្រៅពីនោះមិនដឹងជាទី៣, ទី៤ ពីណាទៀតក៏មិនដឹងបាទ។ ខ្ញុំក្តាប់បានប៉ុណ្ណឹងឯង។

**ស៖** សូមបញ្ជាក់លោកម្តងទៀត អំមិញលោកមានជម្រាបតុលាការថា គ្រាន់តែដឹងថា ប៉ុល ពត ទី១, អ៊ំនួន ជា ទី២ អាហ្នឹងរាប់យ៉ាងម៉េច? រាប់ក្នុងឋានៈជាស្អី? លោកថាទី១, ទី២ហ្នឹង លោករាប់

ក្នុងរដ្ឋាភិបាល រាប់នៅក្នុងសភា រាប់នៅក្នុងអ្វី ដែលលោករាប់ហ្នឹង?

**ឆ៖** បាទ ខ្ញុំបញ្ជាក់បញ្ហានេះ គឺតាមដែលខ្ញុំដឹងថា នេះគឺថាគេរាប់ដូចថាឈ្មោះ ប៉ុល ពត ហ្នឹងគេហៅថាបងទី១, ហើយនួន ជា ហ្នឹងគេហៅថាបងទី២។ នេះគឺគ្រប់តែគ្នាគឺហៅតែអ៊ីចឹងឯង។ ដូច្នេះ មិនមានដឹងអ្វីក្រៅពីហ្នឹងទៀតទេ។ ហើយយល់ថាបើទី១ គឺច្បាស់ជាធំជាងទី២ ហើយ តែប៉ុណ្ណឹង។

[១១:២៨:៣៤]

**ស៖** អរគុណ។ សំណួរបន្តទៅទៀត ខ្ញុំសួរសាក្សីថា លោកជាមន្ត្រីយោធាជាន់ខ្ពស់នៅក្នុងកងទ័ពកម្ពុជាប្រជាធិបតេយ្យ គឺមេបញ្ជាការកងវរសេនាធំ។ កន្លងមកទាំងឯកសារផ្លូវការឆ្លើយតបទៅនឹងព្រះរាជអាជ្ញាក៏ដូចជាឆ្លើយទៅមេធាវីដើម --អ៎! ឆ្លើយទៅតុលាការ មេធាវី (សូមទោស) អំពីឈ្មោះ សុន សេន ជាញឹកញាប់ជូនភារៈលោកបានទទួលបញ្ជាផ្ទាល់។ ខ្ញុំសាឡើងវិញ ខ្ញុំអានមិនសូវច្បាស់ ឥឡូវខ្ញុំនិយាយសាឡើងវិញ។ លោកបានឆ្លើយទៅព្រះរាជអាជ្ញាអំពីឈ្មោះ សុន សេន។ ជាញឹកញាប់ លោកបានទទួលបញ្ជាផ្ទាល់ពីលោក សុន សេន ក្នុងកិច្ចប្រតិបត្តិការផ្សេងៗទៀតផង។ ជាញឹកញាប់ លោកបានទទួលបញ្ជាផ្ទាល់ពីលោក សុន សេន ឧទាហរណ៍មួយ ដូចពីម្សិលមិញលោកបាន ជម្រាបតុលាការថា “ពេលដែលបម្រុងវ៉ៃ រៀបចំវ៉ៃចូលភ្នំពេញ ពេលហ្នឹងលោកបាន ឮបញ្ជា ផ្ទាល់ពីលោក សុន សេន”។ អំមិញក៏លោកមានប្រសាសន៍អ៊ីចឹងដែរ។ បើដូច្នេះខ្ញុំសូមសួរលោក សាក្សីថា លោក សុន សេន មានមុខងារ តំណែងនៅក្នុងកងទ័ព ទាល់តែមានមុខងារ តំណែងក្នុង កងទ័ពបានអាចបញ្ជាកងទ័ពបាន អ៊ីចឹងទេ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ចំពោះបញ្ហានេះគឺ ខ្ញុំសូមឆ្លើយនឹងសំណួរនេះគឺថា តាមពិតគឺតាំងពីមុនរំដោះភ្នំពេញ ដូច្នេះការរាយការណ៍អី គឺកងពលខ្ញុំគឺរាយការណ៍ឲ្យ សុន សេន។ រហូតដល់ទៅរៀបចំកម្លាំងទៅរតនគិរីហើយហ្នឹង ក៏រាយការណ៍ -- ផ្នែកខាងយោធាក៏រាយការណ៍ឲ្យមក សុន សេន។ ផ្នែកខាងនយោបាយគឺរាយការណ៍ឲ្យ ប៉ុល ពត។ ដូច្នេះខ្ញុំយល់ថា សុន សេន ហ្នឹងគឺគាត់ទទួលខាងយោធា។ ដូច្នេះ ប៉ុល ពត គាត់ទទួលខាងនយោបាយ។ ខ្ញុំសូមជម្រាប។

[១១:៣២:១៤]

**ស៖** អរគុណ។ នេះនៅក្នុងការប៉ាន់ស្មានរបស់លោក មិនទាន់ប្រាកដជាក់លាក់ទេ ដែលលោកស្មានថាប្រហែលជា សុន សេន-- ព្រោះអីធ្វើរបាយការណ៍ខាងយោធាទៅលោក សុន សេន។ ហើយលោកអត់ច្បាស់ទេ អត់មានអីបញ្ជាក់ប្រាប់លោក ជាឯកសារ ជាលិខិតស្នាមអីថា សុន សេន ជាស្ទីនៅ

ក្នុងកងទ័ពទេ។ អ៊ីចឹងទេ យ៉ាងម៉េច?

**ឆ៖** បាទ គឺបញ្ហានេះគឺខ្ញុំដូចជម្រាបខាងដើមអ៊ីចឹង គឺតាំងពីមុនរំដោះ រហូតដល់រំដោះហ្នឹង គឺមេបញ្ជាការឲ្យខ្ញុំរាយការណ៍ឲ្យតែលោក សុន សេន នេះឯង។ ហើយគាត់ថា មេបញ្ជាការរបស់ខ្ញុំគាត់ថា រាយការណ៍ឲ្យទៅ សុន សេន ព្រោះគាត់ទទួលខាងផ្នែកទាហាន បាទ។ ឯ ប៉ុល ពត គាត់ទទួលខាងផ្នែកនយោបាយ បាទ។ ខ្ញុំចាំតាមមេបញ្ជាការខ្ញុំគាត់ប្រាប់តែប៉ុណ្ណោះឯង គឺគាត់ទទួលខាងយោធា គាត់រាយការណ៍ឲ្យខាងយោធា។

[១១:៣៣:៣៩]

**ស៖** អរគុណ។ ចំពោះខ្លួនលោកផ្ទាល់ជាមេបញ្ជាការកងវរសេនាធំ មានន័យបន្ទាប់កងពលលោកដែលធ្វើរបាយការណ៍អ្វី ជាឯក -- ជាលិខិតស្នាមទៅមេកងពលរបស់លោកហើយ ទៅលោក សុន សេន ទៀតទេ?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ។ តួនាទីរបស់ក្នុងវរសេនាធំគ្មានសិទ្ធិរំលងកងពលទេ នេះជាវិន័យ ឬជាច្បាប់អ៊ីចឹង។ ប៉ុន្តែក្នុងករណីពិសេសដែលកងពលមិននៅ ឥឡូវបើមានអី សភាពការណ៍អីយ៉ាងម៉េចៗ ហើយរាយការណ៍ទៅលើទៅ។ បាទ តែប៉ុណ្ណោះឯង។ នោះបានមានសិទ្ធិរាយការណ៍មកលើបាន តែបើកងពលនៅ ទាំងសមាជិក ទាំងនយោបាយ ទាំងយោធាទេ អត់! អត់មានសិទ្ធិទេ។

**ស៖** លោកមានប្រសាសន៍ជម្រាបតុលាការថា បើសិនជាមិននៅរាយការណ៍ទៅលើ ខាងណាលើហ្នឹង? សុន សេន ឬក៏កន្លែងណា?

**ឆ៖** បាទ បើសិនណាជាខាងផ្នែកយោធាមានបញ្ហាព្រំដែនយ៉ាងម៉េចៗទេ អាហ្នឹងគឺយោធារាយការណ៍មកមេបញ្ជាការខាងទាហាន ឧទាហរណ៍ សុន សេន។ ហើយផ្នែកនយោបាយ បើសិនណាមានអីស្មុគស្មាញ ខាងអារម្មណ៍ ខាងអី គឺរាយការណ៍មក ប៉ុល ពល។

**ស៖** ខ្លួនលោកផ្ទាល់ក្នុងឋានៈជាមេបញ្ជាការកងវរសេនាធំ លោកដែលរាយការណ៍ផ្ទាល់មក សុន សេន ឬក៏ខាងនយោបាយ រាយការណ៍ផ្ទាល់ទៅ ប៉ុល ពត ទេ?

[១១:៣៦:១៦]

**ឆ៖** ខ្ញុំមិនដែលរាយការណ៍ផ្ទាល់ទៅ ប៉ុល ពត ទេ។ តែបើ សុន សេន នេះអាចមានខ្លះ ដោយសារកងពលមិននៅអី។ បើសភាពការណ៍ចាំបាច់ ដូចសភាពការណ៍យោធា ឬក៏សភាពការណ៍នយោបាយអី ខ្ញុំអត់មានដែលរាយទេ។ បើសិនយោធាអី សភាពការណ៍ដែលវាទាន់ហាន់អី គឺខ្ញុំគ្រាន់តែ

រាយការណ៍មកថ្នាក់លើដែរ។ ដូចខ្ញុំបានបញ្ជាក់ពីខាងដើម ថាមិននៅ ក៏មេបញ្ជាការអវត្តមាន។

**សៈ** ក្រៅពី -- មុននឹងលោក ឧបមាថាមានព្រឹត្តិការណ៍កើតឡើងនៅតំបន់លោកខ្លាំងក្លា មានការប្រយុទ្ធ មេបញ្ជាការកងពលមិននៅ។ នៅក្នុងភូមិភាគហ្នឹង ភូមិភាគដែលលោកកាន់កាប់លោករស់នៅហ្នឹង កងរបស់លោករស់នៅហ្នឹង លោកដែលរាយការណ៍អ្វីទៅភូមិភាគទេ? ឬក៏ទៅកងពល បើមេមិននៅ គឺទៅ សុន សេន ផ្ទាល់តែម្តង?

**ឆៈ** បាទ ចំពោះបញ្ហានេះ គឺឧបមាកងពលមិននៅ ផ្ទេរសិទ្ធិឲ្យបុគ្គលណាម្នាក់ ឧបមាថាខ្ញុំចុះពិតមែនតែជាវរសេនាធំមួយរូប ហើយក្នុងកងពលមានបីបួនវរសេនាធំ។ តែប្រគល់សិទ្ធិឲ្យខ្ញុំអ្នកចាត់ចែង ខ្ញុំចាត់ចែងបានៗ។ ដូច្នេះគឺឧបមាថា ក្នុងអង្គភាពខ្ញុំមួយ សត្រូវមកវ៉ៃ ខ្ញុំហ៊ានដកកម្លាំងពីអង្គភាពផ្សេងទៅជួយ។ បាទ នេះជាសិទ្ធិរបស់ -- ព្រោះគេផ្ទេរសិទ្ធិហើយ គឺគេចង់និយាយថា ចាត់ចែងអីបានទាំងអស់បាទ។ បើអត់ចាត់ចែងទេ យើងអត់ទៅដល់ដោះស្រាយចេញទេ ទាល់តែស្នើមតិទៅកងពលសិនបានចាត់ចែងបាន។ ហើយបើមិនអ៊ីចឹងទេ អត់ៗ គឺអត់ត្រូវ។ បាទ បើផ្ទេរសិទ្ធិឲ្យគេ គេដឹងថាខ្ញុំអ្នកទទួលត្រូវរួម បើកងពលមិននៅ ដូច្នេះមានបញ្ហាអី ខ្ញុំហៅគេមកបាន ឬក៏ខ្ញុំទៅជួបគេបាន។ សុំកម្លាំង ១០០, ២០០ ទៅជួយកន្លែងនេះ កន្លែងនោះ បាន ព្រោះខ្ញុំមានសិទ្ធិ ព្រោះកងពលខ្ញុំផ្ទេរសិទ្ធិឲ្យ។ តែបើអត់ផ្ទេរសិទ្ធិទេ លំបាកដែរ។

[១១:៣៩:១៦]

**សៈ** សំណួររបស់ខ្ញុំអំមិញអ៊ីចេះ ខ្ញុំថា លោកដែលបានធ្វើរបាយការណ៍អ្វីទៅមេកងពលហើយហួសឡើងទៅលើទៀត។ ឧបមាធ្វើទៅដល់ សុន សេន ប៉ុន្តែចន្លោះហ្នឹង ដែលលោកមានដែលមានរាយការណ៍ទៅភូមិភាគ ដែលភូមិភាគមានសិទ្ធិនឹងមកដឹងអំពីប្រតិបត្តិការរបស់លោកទេ។ អានេះសំណួររបស់ខ្ញុំអ៊ីចឹង?

**ឆៈ** ខ្ញុំឆ្លើយនឹងសំណួរនេះ គឺទី១ សម្រាប់ផ្ទាល់ខ្លួនខ្ញុំ ដែលក្រោមការគ្រប់គ្រងរបស់កងពល បើមានបញ្ហាអីខ្ញុំរាយការណ៍ឲ្យកងពល បើកងពលគាត់រាយការណ៍ឲ្យភូមិភាគ ឬរាយការណ៍ អីយ៉ាងម៉េច គឺខ្ញុំក្តាប់មិនបាន។ ប៉ុន្តែការសហការគ្នា ភូមិភាគហើយនិងទាហាន វាមានការជាប់គ្នាដែរ ប៉ុន្តែអត់ដែលរាយការណ៍ឲ្យភូមិភាគទេ។ ខ្ញុំមានតែកងពលទេ សភាពការណ៍អីកងពលសហការអីជាមួយភូមិភាគអីយ៉ាងម៉េចៗ គឺខ្ញុំក្តាប់មិនបាន ប៉ុន្តែបើកងពលមកទាក់ទងអីជាមួយភូមិភាគ ខ្ញុំទៅបាទ។ ដូច្នេះអត់ដែលរាយការណ៍ឲ្យទៅ ឧទាហរណ៍ថា ខាងខ្ញុំមានបោះនៅសៀមប៉ាង មានភូមិ អំន៉ែ! មានស្រុក

មួយបាទ។ ប៉ុន្តែបើអត់អនុញ្ញាតឲ្យខ្ញុំទៅជួបស្រុកក៏ខ្ញុំអត់ទៅដែរ។ បាទ ខ្ញុំសូមបញ្ជាក់ឲ្យវែងបន្តិចចុះ គឺពេលដែលទៅបោះនៅកន្លែងនោះ គឺគ្មានការអនុញ្ញាតឲ្យទាក់ទងមូលដ្ឋានទេ ហ្នឹងទី១។ ទី២ គឺភារកិច្ចសំខាន់របស់អ្នកទៅៗព្រំដែន គឺទី១ ការពារព្រំដែន។ ទី២ បង្កបង្កើនផលឧបត្ថម្ភខ្លួន ដោយចបកាប់ និងពូថៅកាំបិតប៉ុណ្ណោះឯង គ្មាន--

[១១:៤១:២៦]

**ស៖** ខ្ញុំមិនសួរដល់ប៉ុណ្ណឹងទេ--

**ឆ៖** --ខ្ញុំចង់បញ្ជាក់ ដើម្បីឲ្យលោកយល់។

**ស៖** បាទ ខ្ញុំមិនសួរវែងអីចឹងទេ។ ឥឡូវខ្ញុំបន្តសំណួរហ្នឹងតទៅទៀត។ លោក សុន សេន ក្រៅពីតំណែងគាត់ធ្វើការងារផ្ទាល់ជាមួយយោធា ដែលលោកមិនបានដឹងថា មុខងារលោក សុន សេន ជាអ្វីនោះ។ លោកមានដឹងថា មុខងារក្រៅពីគាត់ធ្វើការផ្ទាល់ បញ្ជាផ្ទាល់ជាមួយយោធា មានមុខងារអីផ្សេង អ្វីផ្សេងទៀតទេ សុន សេន?

**ឆ៖** បាទ ចំពោះ សុន សេន មុខងារគាត់ជាអ្វី ដូចខ្ញុំបានជម្រាប ខ្ញុំអត់ដឹងទេ។ ព្រោះដឹងថាពីមុន គឺគាត់បញ្ជាទ័ពនៅខាងលិច ប៉ុន្តែក្រោយរំដោះភ្នំពេញហើយទេ គាត់ -- ខាងកងពលខ្ញុំនៅតែទទួលការបញ្ជាពីគាត់ ត្រូវរាយការណ៍ជូនគាត់ ហើយក្រោយមកបានគាត់ថា គាត់ជាមេដឹកនាំជាន់ខ្ពស់នៅក្នុងទាហានទាំងអស់ តែប៉ុណ្ណោះឯង។ ហើយមុខងារគាត់អីទៀតក៏ខ្ញុំមិនដឹង។ ហើយនិយាយមួយម៉ាត់មកវិញថា មុខងារខាងផ្នែកផ្ទៃក្នុងគាត់ជាសមាជិកអីៗ ក៏ខ្ញុំ រហូតទល់សព្វថ្ងៃក៏ខ្ញុំមិនដឹង។

[១១:៤២:៤៨]

**ស៖** អរគុណណាស់។ នៅពេលប្រតិបត្តិការសឹកម្តងៗ ហើយធំៗ ឧទាហរណ៍ដូចជា វ៉ៃក្រុងឧដុង្គ វ៉ៃកំពង់ចាម វ៉ៃខេត្តនេះ ខេត្តនោះ និងចុងក្រោយបំផុតវ៉ៃចូលក្រុងភ្នំពេញ ប្រតិបត្តិការសឹកទាំងអស់នោះ ក្រៅពីលោក សុន សេន ខ្លួនលោកផ្ទាល់នេះ លោក អ៊ុង វ៉ែន នេះដែលបានទទួលបញ្ជាពីលោក ប៉ុល ពត ផ្ទាល់ទេ?

**ឆ៖** បាទ ខ្ញុំឆ្លើយនឹងសំណួរនេះ។ ដូចជាប្រហាក់ប្រហែលគ្នាលើសំណួរមុនៗ តែខ្ញុំចង់បញ្ជាក់ជូនលោកថា កាលដែលវ៉ៃនៅកន្លែងណា ឬប្រយុទ្ធនាការកន្លែងណាធំៗ សម្រាប់ខ្ញុំផ្ទាល់មិនបានទទួលមតិណែនាំពី ប៉ុល ពត ផ្ទាល់ទេ។ ទទួលបានតែ សុន សេន នេះឯង។ ហើយខ្ញុំពិនិត្យនៅក្នុងមេបញ្ជាការកងពលខ្ញុំទៀត ក៏គាត់មិនដែលបាននិយាយថា បានទទួលជួប ប៉ុល ពត ឬក៏ជួបអ្នកណាផ្សេងក្រៅពី

សុន សេន ដែរ។ ហើយតាមរយៈនោះ តាមខ្ញុំពិនិត្យមើល គឺឃើញតែជិតវ៉ៃចូលភ្នំពេញទេ សុន សេន ក្រៅពីនោះគឺមិនដឹងនៅឯងណាទេ។

[១១:៤៤:៣០]

**ស៖** អរគុណណាស់។ នៅភូមិភាគ ឬតំបន់ស្រុកដែលលោកឈរជើង លោកដែលឮមានមន្ទីរសន្តិសុខនៅតំបន់នោះទេ?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយនឹងសំណួរ។ តាមពិតនៅក្នុងអង្គភាព៨០១ ឬក៏នៅតាមកន្លែងបោះទ័ពអីគឺខ្ញុំសូមជម្រាបដូចតទៅ៖ ទី១ នៅឆ្នាំដែលខ្ញុំនៅកន្លែងនោះគឺថា អត់ៗដឹងថាមានសន្តិសុខទេបាទ។ ខ្ញុំជម្រាបនៅដដែលៗថា ខ្ញុំនៅឆ្ងាយពីកន្លែងកងពលបាទ។ ហើយនៅមានគំនិតមួយថាប្រហែលជាកងពលមិនមានសន្តិសុខអីទេ អត់ដឹងទេបាទ។ ទាល់តែខ្ញុំមិននៅបឹងកន្សែងនេះ នៅលើបានលុងនេះបាទ។ ក្រោយពីទៅពីនេះទៅៗនៅបានលុងបាននេះ បានៗខ្ញុំនៅមួយរយៈបានខ្ញុំដឹង។ ដឹងទី១ ប្រជាជនមកតម្អូញតម្អែរពីរឿងគេចាប់កូនដាក់សន្តិសុខបាទ។ នេះដឹងទី១។

[១១:៤៦:១៧]

ដឹងទី២ អ្នកដែលជាប់គុកសន្តិសុខហ្នឹងរត់រួច គាត់គុករត់រួច បានខ្ញុំដឹងថាសន្តិសុខមានបាទ។ ប៉ុន្តែនៅកន្លែងណាៗអី ខ្ញុំក្តាប់វាមិនបាន។ ខ្ញុំសូមបើករង្វង់ក្រចកបន្តិចគឺថា បន្ទាប់ពីនោះមកបានខ្ញុំបានជួបកងពល គាត់មកពីសមរភូមិវិញខ្ញុំ គាត់មកចូលលេងខ្ញុំនៅជាប់នឹងផ្លូវប្រហែលផ្ទះខ្ញុំ ប្រហែលផ្លូវប្រហែល៥ម៉ែត្រទេ។ ខ្ញុំបានជួបគាត់ហ្នឹង ព្រោះធ្លាប់នៅជាមួយគ្នាក៏បាននិយាយថា "អូបង! ឥឡូវប្រជាជនសំណូមពរកូនគាត់ហ្នឹងអត់មានខុសអីខ្លាំងធំដុំទេ គ្រាន់តែយក កាប់ដំឡូងហូបហ្នឹងក៏ចោទគ្នាថាអីចេះថាអីចុះ ទៅចាប់គ្នាប្អូនដប់ម្ភៃនាក់យកទៅនាក់នៅអូរកន្សែង"។ បាទ ហើយខ្ញុំសួរទៀតថា ឥឡូវកន្លែងអូរកន្សែងហ្នឹង តើអ្នកណាគ្រប់គ្រងបាទ? ហើយខាងមូលដ្ឋាន ឬក៏ទាហានបាទ? ហើយគាត់អត់មាននិយាយប្រាប់ខ្ញុំទេ។ បាទ អត់មាននិយាយប្រាប់ថានរណាៗទេ ដល់ជជីកសួរយូរបានគាត់ថាសន្តិសុខនៅកន្លែងខាងកងពលគ្រប់គ្រង។ ហើយបានខ្ញុំនិយាយថា "ឥឡូវខ្ញុំដូចថា ខុសត្រូវអីបងអធ្យាស្រ័យ ខ្ញុំសូមតែឲ្យជួយកម្លាំងប្រជាជនដែលចាប់ហ្នឹងឲ្យគ្នារួចទៅអី គ្រាន់តែរឿងដំឡូង រឿងអីចឹងៗ បងគិតយ៉ាងម៉េច?" ដល់ពិគ្រោះគ្នាសាចុះសាឡើងក៏អស់អីចឹង ឲ្យរួចទៅ។ ក៏បាន ២០នាក់ជាងរួចពីកន្លែងឃុំឃាំងហ្នឹងមក។ បានខ្ញុំដឹងថា សន្តិសុខនៅក្នុងកងពល៨០១ គឺមាននៅក្នុងអូរកន្សែងនេះឯង។ ជម្រាបប៉ុណ្ណឹង។

**ស៖** អរគុណ។ បើអ៊ីចឹងមន្ទីរសន្តិសុខហ្នឹងនៅក្រោមការគ្រប់គ្រងរបស់កងពលប្រាំបីរយ -- របស់កងពល អ៊ីចឹង?

**ឆ៖** បាទ តាមពិត គឺសន្តិសុខហ្នឹងគឺនៅអូរកន្សែងគឺក្នុងការគ្រប់គ្រងរបស់កងពល។ ប៉ុន្តែកម្លាំងរបស់កងពល ប៉ុន្តែកងពលអ្នកគ្រប់គ្រងសន្តិសុខនេះឯង។ អត់មែនមូលដ្ឋានទេ។

[១១:៤៩:១៨]

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ សួរលោកថា នៅក្រោយពេល -- មុនខ្ញុំ មុនសំណួរ មុននឹងខ្ញុំឡើងសួរលោកចៅក្រម ឡាវែន៍ គាត់បានសួរលោកអំពីរដ្ឋសភាកម្ពុជាប្រជាធិបតេយ្យ។ លោកបានដឹងថាខ្លួនជាសមាជិករដ្ឋសភា នៅពេលដែលកងពល ប្រធានកងពលរបស់លោកហ្នឹងបានប្រាប់ថា លោកមានឈ្មោះក្នុងបញ្ជីសមាជិករដ្ឋសភាតំណាងប្រជាជន។ ដល់លោកដឹងអ៊ីចឹងទៅ លោកដឹងថាអ្នកណាជាប្រធានរដ្ឋសភាហ្នឹងទេ?

**ឆ៖** បាទ ខ្ញុំមិនដឹងថា ពីណាជាប្រធានរដ្ឋសភាទេ។ អត់ដឹងទេ។

**លោក សុន អរុណ៖**

ខ្ញុំសូមអរគុណលោក អ៊ឹង រ៉ែន ខ្ញុំអស់សំណួរហើយ។ ខ្ញុំសូមអរគុណលោកប្រធាន ខ្ញុំអត់មានសំណួរតទៀត។ ប៉ុន្តែសហភាតាខ្ញុំនឹងមានសំណួរបន្តិច ប្រហែលជាកន្លះម៉ោង។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបាទ!

**លោក វ៉ិចទ័រ កូប៉េ៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំឈ្មោះ កូប៉េ ជាមេធាវីការពារក្តីរបស់លោក នួន ជា។ ខ្ញុំមានសំណួរតែពីរបីសំណួរទេ។

[១១:៥០:៤៦]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ពីម្សិលមិញគឺលោកថាបានផ្តល់សក្ខីកម្ម ថាលោកបានចូលរួមក្នុងការវាយសម្រុកចូលទីក្រុងភ្នំពេញ ក្នុងនាមជាមេបញ្ជាការកងវរសេនាធំ។ ខ្ញុំចង់ដឹងថាតើកងវរសេនាធំមួយណាដែរ ដែលលោកដឹកនាំវាយចូលទីក្រុងភ្នំពេញនោះ?

**លោក អ៊ុង វ៉ែន៖**

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ។ វរសេនាធំ៨២ វ៉ៃចូលភ្នំពេញគឺតាមផ្លូវវត្តតាំងកសាង និងបុករុលមកពោធិ៍ចិនតុង។

**ស៖** លោកចាំទេ ពេលវាយសម្រុកចូលទីក្រុងភ្នំពេញហ្នឹង តើនៅថ្ងៃណាដែរ?

**ឆ៖** អត់ ខ្ញុំមិនចាំទេ វ៉ៃចូលភ្នំពេញនៅថ្ងៃណា ព្រោះគ្រាន់តែបានវ៉ៃ។

[១១:៥២:១៦]

**ស៖** ពីម្សិលមិញលោកបានឆ្លើយថា លោកត្រូវរបួសនៅថ្ងៃ១៧ មេសា ហើយលោកបានចូលមកសម្រាកនៅមន្ទីរ ម្តុំពោធិ៍ចិនតុង។ តើមន្ទីរពេទ្យដែលលោកសម្រាកហ្នឹង តើវានៅខាងណាផ្លូវព្រលានយន្តពោធិ៍ចិនតុងនេះដែរ? នៅខាងកើត ឬក៏នៅខាងលិចផ្លូវព្រលានយន្តពោធិ៍ចិនតុងនេះ?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ។ បញ្ហានេះខ្ញុំបានបញ្ជាក់ពីម្សិលហើយ គឺពេទ្យរបស់វរសេនាធំហ្នឹង គឺរបស់ -- ហ្នឹងគឺនៅម្តុំវត្តតាំងកសាង ជិតនឹង ជាប់នឹងផ្លូវរទេះភ្លើង ខាងជើងផ្លូវ។ ខាងជើងផ្លូវ ផ្លូវក្រហមនេះ ផ្លូវក្រួសនេះៗ ហើយជាប់នឹងផ្លូវរទេះភ្លើង។

**ស៖** ខ្ញុំគ្រាន់តែសួរថាតើនៅខាងកើត ឬខាងលិចព្រលានយន្តពោធិ៍ចិនតុង? ឬខាងកើតៗ ឬខាងលិចផ្លូវពោធិ៍ចិនតុងនេះតែម្តង?

**ឆ៖** ខ្ញុំកន្លែងនោះ ខ្ញុំវង្វេងដែរ ប៉ុន្តែគ្រាន់តែចាំបានថា ជិតពោធិ៍ចិនតុងហើយ គឺវត្តតាំងកសាងហ្នឹង។ នេះពេទ្យៗធុនស្រាល សម្រាប់ត្រូវរបួសអីហើយ រុញយកទៅដាក់នៅពូនភ្នំ វត្តពូនភ្នំ។

[១១:៥៤:០៩]

**ស៖** លោកសាក្សីពីម្សិលមិញលោកបានឆ្លើយថា ទោះបីជាលោកសម្រាកអស់រយៈពេល១៧ថ្ងៃក៏ដោយនៅក្នុងមន្ទីរពេទ្យនោះ។ ប៉ុន្តែតើលោកមានបានទាក់ទងជាមួយនឹងកងទ័ពរបស់លោក ដែលចូលរួមវាយរំដោះទីក្រុងភ្នំពេញនោះដែរឬទេ? ដែល -- តើទាក់ទងជាមួយកងទ័ពរបស់លោក ដែលចូលរួមក្នុងការជម្លៀសប្រជាជននោះដែរទេ?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ គឺថាពេលដែលបួសនោះហ្នឹង គឺថាពេលនោះហើយពេលវ៉ៃសម្រុក។ ពេលដែលខ្ញុំរបួសហើយ កម្លាំងហ្នឹងចូលដល់ៗពោធិ៍ចិនតុងហើយ ខ្ញុំនៅលាងរបួសនៅវត្តតាំងកសាងហ្នឹង។ ប្រហែលជាកន្លះម៉ោងក្រោយមក គឺថាគេថារំដោះអស់ហើយ បាទ រំដោះអសហើយ។ ដូច្នេះខ្ញុំអត់ចូលភ្នំពេញទៀតទេ កុំឲ្យវាច្របូកច្របល់អី។ ព្រោះខ្ញុំថា អ!តោះនាំវាដើរទៅវត្តពូនភ្នំទៅ បាទទៅ

ចំនួនដប់ម្ភៃនាក់ហ្នឹង។ អ្នកខ្លះក៏វាថា ទៅលេងភ្នំពេញសិន ចូលភ្នំពេញសិន។ បាទ ដល់ពេលនោះ ក៏ចាប់ផ្ដើមឃើញប្រជាជនរុលមក មិនដឹងជាគេជម្លៀស ឬក៏អីដូចខ្ញុំបានឆ្លើយសំណួរពីម្សិលហើយ។ ទាល់តែបានមួយរយៈក្រោយមក ប្រហែលជាខ្ញុំឃើញប្រជាជនអ៊ីចឹង បានខ្ញុំតែមក១ សឿន ដែលនៅវរសេនាធំជាមួយខ្ញុំ។ "ឥឡូវយ៉ាងម៉េចហើយ បានជាប្រជាជនចេញ? ថាគេឲ្យជម្លៀស១។ ហើយខាងណាគេ -- ដែលកម្លាំងយើងដល់ណា កម្លាំងយើង គេឲ្យនៅពហុកីឡាហ្នឹងហើយ។ សឿនឯងអីទៅឯណា? ថាខ្ញុំនៅផ្ទះ សាក់ ស៊ុតសាខន។ ហើយបងឯងនៅខាងលិចខ្ញុំហ្នឹងទៅ បើមក។ ខ្ញុំថាខ្ញុំអត់ទៅទេ ព្រោះធ្វើម៉េចទេ បើប្រជាជនច្របូកច្របល់ហើយ ខ្ញុំនៅឯណោះចុះ ហើយគ្រប់គ្រងកម្លាំងឲ្យបានល្អផង។ ហើយទ័ពខាងណាគេជម្លៀសប្រជាជនចេញមកលិចនេះ? បាទ គាត់ថាកងពល ៨០២"។ នេះខ្ញុំសូមជម្រាបប៉ុណ្ណឹង។

[១១:៥៦:៤៥]

**ស៖** តើលោកមានបាននិយាយជាមួយនឹងសមមិត្តរបស់លោកហ្នឹង អំពីការជម្លៀសប្រជាជននេះដែរទេ? គេរបៀបនៃការជម្លៀសប្រជាជននេះ?

**ឆ៖** ដូចខ្ញុំបានបញ្ជាក់ពីខាងដើមហើយ គ្រាន់តែដឹងថា គេជម្លៀសប្រជាជន។ ហើយតាមពិតតាមខ្ញុំយល់ទេ បើសិនណាជាផែនការជម្លៀសប្រជាជនចេញនេះ បើមិនមានផែនការពីលើទេ គឺក៏ធ្វើមិនរួច។ ហើយបើមានផែនការពីលើហើយ យើងមិនជម្លៀស ក៏យើងមិនរួចខ្លួន។ ខ្ញុំបញ្ជាក់ប៉ុណ្ណឹង។

**ស៖** នៅពេលនោះ តើលោកមានបានពួសួរហេតុផលដែលបណ្ដាលឲ្យគេជម្លៀសប្រជាជនចេញពីទីក្រុងនេះទេ?

**ឆ៖** បាទ ខ្ញុំមិនបានដឹងទេ ប៉ុន្តែដល់ប្រជាជន -- ដល់ក្រោយមួយខ្ញុំសួរ ប្រហែលជាស្អែកឡើងខ្ញុំសួរមក សឿន ដែលនៅវងខ្ញុំនេះថា "ម៉េចបានជាមូលហេតុអីបានជាប្រជាជនចេញព្រាតព្រោងមកលិចច្រើន ហើយគ្រប់កន្លែងអ៊ីចឹង។ ហើយគាត់ថា ព្រាតព្រោងពេញហ្នឹងឯង។ ហើយយ៉ាងម៉េច? បានគេឲ្យថា ប្រធានកងពលឲ្យជម្លៀសហើយ។ ហើយហេតុអីបានឲ្យជម្លៀស? គាត់ថាខ្លាចខ្មាំង វាបង្កប់ខ្លាចខ្មាំង ប្រជាជនជួយលាក់ខ្មាំងអីចុះ ហ្នឹងហើយ"។ ហើយមួយទៀតគឺថាអាមេរិកទម្លាក់គ្រាប់បែកអ៊ីចេះអ៊ីចុះ។ ហើយដល់អ៊ីចឹងសម្រាប់ផ្ទាល់ខ្លួនខ្ញុំ ក៏មិនដឹងថាទៅដោះស្រាយម៉េច ក៏មិនអាចប៊ានប្រឆាំងទៅលើ។ ដូច្នេះទៅក៏ទៅ១។ រួចដើរទៅអ៊ីចឹងទៅធ្លាក់ដល់ ពួនភ្នំ ក៏ឃើញមនុស្សខ្មោចដឹងព្រាកត្រង់ហ្នឹងឯង។ មិនដឹងទៅសួរម៉េច។ អាខ្លះពរកូន អាខ្លះលីស្ពាយ១ អូ!យ៉ាប់។ នេះខ្ញុំជម្រាបប៉ុណ្ណឹង។

[១១:៥៩:៣០]

**ស៖** តើនៅពេលជម្លៀសប្រជាជនហ្នឹង កងវរសេនាធំរបស់លោកហ្នឹងឈរជើងឬក៏បោះទីតាំងនៅត្រង់កន្លែងណាដែរ ក្នុងទីក្រុងភ្នំពេញហ្នឹង?

**ឆ៖** បាទ ចំពោះវរសេនាធំខ្ញុំដែលឈ្នះភ្នំពេញហើយ គឺនៅតែមួយវរសេនាតូចទេនៅក្នុងភ្នំពេញនេះ ចាប់ពីពេទ្យលោកសង្ឃមកទៅទល់ផ្ទះ១ សាក់ ស៊ុតសាខន ដែលគេជាប់នឹងពហុកីឡដ្ឋានហ្នឹង។ ហើយសល់ប៉ុន្មាននៅខាងក្រៅចាប់ពីវត្តពូនភ្នំមកដល់តាមបណ្តាយផ្លូវ ភូមិនៅជិតៗផ្លូវនេះ។ នៅតាមហ្នឹង ព្រោះនេះជាបទបញ្ជារបស់ថ្នាក់លើថា ឲ្យនៅតែមួយវរសេនាធំបានហើយ -- អ៎! មួយវរសេនាតូចបានហើយព្រោះកម្លាំងក្រែងលោកមានសត្រូវខាងក្រៅអីមកអីចឹង យើងអត់ម្ចាស់ការទេ។ អ៊ីចឹងដូច្នេះ ខាងខ្ញុំនៅទទួល ខ្ញុំរបួសផង ខ្ញុំក៏នៅជាមួយអង្គភាពនៅខាងៗក្រៅនេះឯង។ ឯសល់កម្លាំងប៉ុន្មានបានចូលទៅនៅភ្នំពេញនេះ។ បានប្រហែលជា១អាទិត្យបាន ហៅចូលភ្នំពេញទាំងអស់ គឺរៀបចំកម្លាំងទៅផ្លាស់កន្លែងតែម្តង។

**ស៖** តើកងទ័ពនៅក្នុងកងវរសេនាធំរបស់លោកនោះ គឺថាបានប្រាប់ទៅលោកថា គេឲ្យពួកទាហានទាំង របស់លោកទាំងនោះនៅតែមួយកន្លែង ឬក៏មានល្បាតនៅក្នុងទីក្រុងផងដែរ?

[១២:០១:៣៤]

**ឆ៖** បាទ ចំពោះបញ្ហានេះ គឺខ្ញុំសូមជម្រាបថា អង្គភាពដែលនៅភ្នំពេញគឺមានល្បាត អង្គភាពណាឈរជើងនៅចំណុចណា ត្រង់កន្លែងណា អង្គភាពនោះល្បាតត្រឹមចំណុចនោះឯង។ ដូច្នេះគ្មានទាក់ទិនមកលិច ឬក៏ចូលជ្រៅក្រៅព្រំដែនដែលអង្គភាព ដែលខ្លួនរៀបចំទេ។ ហ្នឹងមួយ។ ឯទី២ ទៀតអ្នកនៅខាងក្រៅ គឺត្រៀមប្រយុទ្ធ ប៉ែកមកពីខាងលិច ឯមកពីណាៗ ខាងជើងភ្នំពេញពីណាៗ គឺរៀបចំលម្អិតអ៊ីចឹងឯង។ បើមានសភាពការណ៍អីអត់មានចាំបាច់ប្រទាំងប្រទើសគ្នា ឥឡូវចេញពីភ្នំពេញមកជួយវ៉ៃគ្នាអីណា អីណីទេ។ គឺថាកម្លាំងខាងក្រៅគេរៀបចំដើម្បីប្រយុទ្ធក្រែងមានខ្មាំងសត្រូវមកពីខាងក្រៅទៀត។

**ស៖** តើកងទ័ពនៃវរសេនាធំរបស់លោកហ្នឹងមានប្រាប់លោកថា មានអ្វីកើតឡើងចំពោះពួកគេទេ បើសិនជាណាគេដើរឆ្លងរង្វង់ដែនកំណត់ ឬក៏រង្វង់ទឹកដីដែលគេត្រូវឲ្យឈរជើងនោះ? តើកងទ័ពរបស់លោកហ្នឹងត្រូវគេដាក់ទណ្ឌកម្ម ឬក៏ដាក់វិន័យអីដែរឬទេ?

[១២:០៣:១៦]

**ឆ៖** បាទ តាមពិត គឺគ្រាន់តែចែកការងារ ចែកមុខព្រួញគ្នាទទួលខុសត្រូវទេ ប៉ុន្តែការដើរឆ្លង

កាត់អីទាក់ទងគ្នាពេលថ្ងៃអីបាន អត់មាន -- បើសិនណាជា ចុះពេលនោះមានច្បាប់មានទម្លាប់អីណាដើរទៅៗ ប៉ុន្តែពេលល្ងាចឡើង យប់ឡើងអីមូលគ្នា។ អង្គភាពណានៅអង្គភាពហ្នឹងអត់មានឆ្វេកឆ្វាចទេពេលយប់បាទ។ តែបើដើរពេលយប់ខុសច្បាប់ទម្លាប់ គ្រាន់តែថា ណែនាំ -- ប្រគល់ជូនអង្គភាពវិញថាឲ្យណែនាំទៅវាខុសបទបញ្ញា ខុសច្បាប់ ព្រោះដើរយប់។ បាទ តែប៉ុណ្ណឹងអត់មានស្អីទេ។

**ស៖** លោកសាក្សីខ្ញុំចូលទៅប្រធានបទមួយ ចុងក្រោយមួយទៀត--

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ ឥឡូវនេះដល់ពេលសមល្មមសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកថ្ងៃត្រង់ចាប់ពីពេលនេះទៅរហូតដល់ម៉ោងមួយសាមសិបនាទីសូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនូវក្នុងអំឡុងពេលសម្រាកអាហារថ្ងៃត្រង់នេះ ចំពោះសាក្សីនៅបន្ទាប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោងមួយសាមសិបនាទី។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោម ហើយនិងឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្ម -- ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៥ នាទី ដល់ម៉ោង ១៣:៣៤ នាទី)*

[១៣:៣៤:២៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី នៅចាំបានទេ មុនសម្រាកពិសាបាយថ្ងៃត្រង់នេះ ខ្ញុំបានសួរសំណួរមួយចំនួនទៅលោកពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ ហើយខ្ញុំក៏បានសួរលោកថាតើលោកមានដឹងអំពីមូលហេតុនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដែរ? ហើយហេតុផលមួយ គឺលោកប្រើពាក្យថា "ដោយសារខ្លាចអាមេរិកាំងទម្លាក់គ្រាប់បែក" តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ កាលណានិយាយពាក្យថា "មូលហេតុមួយ គឺខ្លាចអាមេរិកាំងទម្លាក់គ្រាប់បែក"?

**លោក អ៊ុង វ៉ែន៖**

**ឆ៖** បាទ មតិនេះ គឺខ្ញុំសូមបញ្ជាក់ថា កន្លងមក គឺជម្លៀសដូចខ្ញុំបានបញ្ជាក់ហើយ គឺខ្ញុំនៅខាងក្រៅទេ ប៉ុន្តែគ្រាន់ថា សួរកម្លាំងដែលនៅចូលដល់កន្លែងបោះទ័ពហើយ គឺថាមូលហេតុអីបានជាប្រជាជនឲ្យប្រជាជនជម្លៀស។ ហើយតាមរយៈនោះ គឺថាខ្លាច ទី១ ខ្មាំងបង្កប់នៅក្នុងភ្នំពេញ។ ទី២ គឺខ្លាចយន្តហោះ។ ដូច្នេះហើយ គឺយន្តហោះមានពីណា គឺមានតែពីខាងក្រៅមានអាមេរិកអី ដូច្នេះគឺ នេះគឺតាមពាក្យដែលតៗគ្នា គេរាយការណ៍តាមតេអូក្ដី គឺតាមមាត់ គឺខ្លាច គឺមូលហេតុហ្នឹងឯង។ ដូច្នេះ កម្លាំងខ្ញុំក៏រាយការណ៍មកឲ្យខ្ញុំនៅខាងក្រោយនេះ ក៏អ៊ីចឹងដែរ។ ដូច្នេះ គឺបានសេចក្ដីថា មូលហេតុ ខ្ញុំឃើញមានតែពីរហ្នឹងឯង គឺខ្លាច។ ទី១ គឺមានខ្មាំងបង្កប់ហើយ ពេលយប់ព្រលប់ហើយវារ៉ែអ៊ីចឹងទៅ មានច្របូកច្របល់ជាមួយប្រជាជន។ ដូច្នេះអាចថា ដើម្បីជម្លៀសប្រជាជនចេញឲ្យអស់ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងភ្នំពេញនេះ។

[១៣:៣៧:០១]

**ស៖** តើខ្លួនលោកផ្ទាល់ធ្លាប់មានបទពិសោធន៍ៗជួបប្រទះការទម្លាក់គ្រាប់បែកដោយអាមេរិកាំងទេ?

**ឆ៖** បាទ ចំពោះផ្ទាល់ខ្លួនខ្ញុំ ខ្ញុំនិយាយតែផ្ទាល់ខ្លួនខ្ញុំទេ។ បើចំពោះការទម្លាក់គ្រាប់បែករបស់អាមេរិកាំង រាប់មិនអស់ទេ មុននឹងវ៉ៃភ្នំពេញនេះ។ ឧទាហរណ៍ នៅតាមដងផ្លូវជាតិលេខ២៦នេះ ហើយនិងតាមជនបទផ្សេងៗ គឺទម្លាក់គ្រប់ទីកន្លែង។ សុទ្ធតែយន្តហោះ មានតែយន្តហោះអាមេរិកនេះឯង។

**ស៖** តើលោកអាចរៀបរាប់ឲ្យបានលម្អិតបន្តិចបានទេ រៀបរាប់បទពិសោធន៍ជួបប្រទះ និងការ

ទម្លាក់គ្រាប់បែកនេះឲ្យលម្អិតបន្តិចបានទេ?

**ឆ៖** បទពិសោធន៍អាមេរិកទម្លាក់គ្រាប់បែក គឺខ្ញុំធ្លាប់ពិសោធន៍ថា ឧបមាថា នៅតាមជួរខ្សែត្រៀម ក្រោយពេលយើងត្រៀមហើយ គឺយន្តហោះក្រវែល១ហើយ ទម្លាក់គ្រាប់បែក។ ពិសោធន៍ត្រង់ថា បើសិនណាជានៅក្នុងត្រង់សេ វាងាប់ទាំងអស់ហ្នឹងឯង។ ដូច្នេះ ទាល់តែកប៉ាល់ហោះរៀបទម្លាក់ហើយវាក្រវែលទាបមកហើយ គឺនាំគ្នារត់ចេញ រត់ចេញហើយ ទម្លាក់ហើយចូលវិញ។ នេះពិសោធន៍អ៊ីចឹងឯង។ ព្រោះពិសោធន៍មួយទៀត គឺបើមិនរត់ទេ ឧទាហរណ៍នៅផ្លូវលេខ២៦, ២០ ត្រង់សេកប់ទាំងអស់ មិនដឹងទៅឯណាមកណីទេ។ នេះខ្ញុំមានពិសោធន៍ប៉ុណ្ណឹងទេក្នុងការដែលយន្តហោះអាមេរិកធ្លាប់ទម្លាក់អ៊ីចឹងឯង។

[១៣:៣៩:២៧]

**ស៖** លោកចាំបានទេ តើការទម្លាក់ដែលលោកនិយាយនេះ គឺនៅក្នុងឆ្នាំណាដែរ?

**ឆ៖** ចិត -- ៦៩ អ្ហឺស! ខ្ញុំមិនចាំឆ្នាំទេ ប៉ុន្តែមុននឹងវៃភ្នំពេញនេះ គឺវៃ ទម្លាក់រហូតទាល់តែដល់ជិតភ្នំពេញបានបាត់។ បើនិយាយពីខែឆ្នាំ ខ្ញុំមិនចាំទេ គឺនិយាយរួមគឺថា មានកងទ័ពពេលណាគឺទម្លាក់រហូត តាមភូមិតាមស្រុក តាមកន្លែង(ឮមិនច្បាស់)នៅ តាំងពីត្រពាំងឆ្នោតឡើងទៅលើទៅ គេទម្លាក់រហូត។ ទាល់តែវៃដល់ពោធិ៍ចិនតុងហើយ អត់មានឃើញមានទម្លាក់ទេ ឃើញតែមានបាញ់រះអឺ។ ដល់កៀកមែនទែន ឈប់ទាំងបាញ់រះទៀត ក៏ចប់ប៉ុណ្ណោះឯង។

[១៣:៤០:៣៤]

**ស៖** តើលោកជួបប្រទះបទពិសោធន៍នឹងការទម្លាក់គ្រាប់បែករបស់ពួកអាមេរិកាំង នៅមុនពេលដែលលោកចូលធ្វើទ័ពដែរឬទេ?

**ឆ៖** បាទ ខ្ញុំមិនដែលមានពិសោធអីជាមួយយន្តហោះអាមេរិកាំងមុនធ្វើកងទ័ពនេះទេ។

**ស៖** តើលោកមានបានឮពីក្រុមគ្រួសាររបស់លោក ពីបទពិសោធន៍របស់ពួកគាត់មុនពេលដែលលោកចូលធ្វើកងទ័ពនោះ?

**ឆ៖** បាទ សំណួរនេះខ្ញុំមិនយល់។

**ស៖** តើលោកមានដែលនិយាយទៅកាន់សមាជិកគ្រួសាររបស់លោក សួរគាត់អំពីបទពិសោធន៍របស់ពួកគាត់ដែលជួបប្រទះទៅនឹងការទម្លាក់គ្រាប់បែកហ្នឹង មុនពេលដែលលោកចូលកងទ័ពនោះដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់មានសួរនាំអី មានពិសោធអី ឬមុនចូល មិនបានសួរគ្រួសារ ឬក៏ម៉ែឪអីទេ។

[១៣:៤២:២៤]

**ស៖** នៅក្នុងឆ្នាំ១៩៧៥ តើលោកគិតថា លទ្ធភាពនៃការទម្លាក់គ្រាប់បែកអាមេរិកាំវាមានកិតប៉ុនណាដែរ? ហើយនៅក្នុងកងវរសេនាធំរបស់លោក តើមានការរៀបចំពិសេសណាមួយដែរ ដើម្បីទប់ទល់នឹងការទម្លាក់គ្រាប់បែកនោះ?

**ឆ៖** ការត្រៀមរៀបចំក្នុងឆ្នាំ១៩៧៥ មុនរំដោះ ឬក៏ក្រោយរំដោះអី គឺថាសម្រាប់អង្គភាពកងទ័ពខ្ញុំពិនិត្យឃើញថា គ្មានការរៀបចំអីសម្រាប់បាញ់យន្តហោះអីទេ ព្រោះអត់មានមធ្យោបាយអីទៅកម្ទេចយន្តហោះទេ។ ដូចខ្ញុំបានជម្រាបពីសំណួរមុនហ្នឹង គឺថាបើទម្លាក់ចំហើយ មានតែរត់ទេ បើមិនរត់ទេគឺថានៅហ្នឹងឯង។ ដូច្នេះអត់មានកាំភ្លើងបាញ់យន្តហោះ អត់មានអីទេ។ ដូច្នេះ អត់មានផែនការអីទៅកម្ទេចយន្តហោះបានទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ខ្ញុំអស់សំណួរហើយ។ សូមអរគុណលោកសាក្សី សូមអរគុណលោកប្រធាន។

[១៣:៤៣:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម។ សួស្តីសហព្រះរាជអាជ្ញា សហភាតាទាំងអស់។ សួស្តីលោក អ្នកទាំងឡាយចូលរួមនៅក្នុងសវនាការ ទោះនៅក្នុងបន្ទប់ ឬក្រៅបន្ទប់ក្តី។

**សួរដោយលោក អាង ឧត្តម៖**

**ស៖** សួស្តីលោក អ៊ុង រ៉ែន ខ្ញុំ អាង ឧត្តម ហើយខាងស្តាំដៃខ្ញុំនេះគឺលោក ម៉ៃខល កាណាវាស។ យើងខ្ញុំជាសហមេធាវីការពារក្តីលោក អៀង សារី។ ពេលនេះខ្ញុំមានសំណួរមួយចំនួននឹងសួរលោក។

ជាបឋមខ្ញុំសូមសួរសំណួរដែលទាក់ទងនឹងអ្វីដែលលោកបានឆ្លើយពីម្សិលមិញ និងក្រោយមកទៀត។ ពីម្សិលមិញលោកចៅក្រមប្រធាន និល ណុន បានផ្តើមសួរលោកថា លោកបានជួបផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតរបស់ការិយាល័យ សហចៅក្រមស៊ើបអង្កេតចំនួនប៉ុន្មានដង?

ហើយលោកបានឆ្លើយច្បាស់ថា ចំនួនបីដង។ តើនៅរក្សាចម្លើយហ្នឹងដដែលឬទេ?

**ឆ៖** បាទ ធម្មតាដែលខ្ញុំបានជួបហើយ គឺចម្លើយវាច្រើន ដូច្នេះការក្ដាប់គ្រប់សព្វចម្លើយ គឺវាចាំមិនអស់។

**ស៖** សូមលោកបញ្ជាក់ឲ្យច្បាស់ ខ្ញុំចង់និយាយពីចំនួនដង ប៉ុន្មានដង? លោកបានឆ្លើយថា បានផ្ដល់កិច្ចសម្ភាសន៍បីដង។ តើលោកនៅរក្សាថា នៅតែចំនួនបីដងដដែល ឬលោកកែប្រែ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប! ចាំស្ដាប់ ចាំក្បាលមីក្រូហ្វូប្រតិបត្តិការសិន។

**លោក អ៊ុង វ៉ែន៖**

**ឆ៖** បាទ ខ្ញុំមិនបានចាំត្រង់ថានេះទេ ប៉ុន្តែតាមខ្ញុំមើលដូចទំនងតែបីដងប៉ុណ្ណោះឯង ហើយមិនលើសពីបី ទៅបួន។

**សួរដោយលោក អាង ឧត្តម៖**

**ស៖** អ៊ីចឹងខ្ញុំអាចសរុបសេចក្ដីជូនលោកថា អំមិញថាលោកមិនលើសពីបីដងទេ ប្រហែលជាបី ឬបួន។ អ៊ីចឹងម្សិលមិញលោកថា បីដង ថ្ងៃនេះបីដង ឬបួនដង មិនអាចលើសបីដង។ អ៊ីចឹងខ្ញុំអាចសរុបថា លោកមិនប្រាកដថាចំនួនប៉ុន្មានដងទេ តើត្រឹមត្រូវទេ?

[១៣:៤៧:០៨]

**ប្រធានអង្គជំនុំ៖**

លោកៗឆ្លើយ លោកសាក្សី!

**លោក អ៊ុង វ៉ែន៖**

**ឆ៖** បាទៗ។

**សួរដោយលោក អាង ឧត្តម៖**

**ស៖** ក្រោយមកទៀត លោកចៅក្រមប្រធានបានសួរលោកថា មុននឹងចូលមកក្នុងបន្ទប់សវនាការដើម្បីផ្ដល់សក្ខីកម្មនេះ ថាលោកបានពិនិត្យមើលកំណត់ហេតុនៃការស្ដាប់ចម្លើយរបស់លោកទាំងអស់នោះត្រឹមត្រូវទេ ហើយលោកបានឆ្លើយថា លោកបានពិនិត្យមើលឃើញថាត្រឹមត្រូវហើយ។ ខ្ញុំចង់សួរបន្ថែមទៀតថា ពេលពិនិត្យមើលឯកសារទាំងអស់ហ្នឹង លោកពិនិត្យមើលឯកសារអ្វីខ្លះ ហើយចំនួនប៉ុន្មាន?

**ឆ៖** ដូចខ្ញុំបានឆ្លើយអម្បាញ់មិញហ្នឹង គឺថាបើតាមសំណួរដែលសួរហ្នឹងគឺវាច្រើន ហេតុដូច្នេះ ខ្ញុំវាចាំវាមិនអស់។ ដូច្នេះ ខ្ញុំចាំបានប៉ុនណា គឺខ្ញុំឆ្លើយប៉ុណ្ណឹង។ ហើយបើយកឯកសារមកសួរតាមចម្លើយ ខ្ញុំឆ្លើយបាន។

**ស៖** បាទ សូមអរគុណ។ ក្រោយមកទៀត សហព្រះរាជអាជ្ញាមុននឹងចាប់ផ្ដើមសួរលោកនូវសំណួរលម្អិតបានប្រគល់ឯកសារនូវកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីរបស់លោក តើលោកបានទទួលព្រះរាជអាជ្ញាពីម្សិលមិញបានចំនួនប៉ុន្មាន?

**ឆ៖** បាទ តាមពិតខ្ញុំបានទទួល បើឯកសារដែលត្រូវស៊ើបអង្កេតដល់ផ្ទះខ្ញុំ ខ្ញុំបានទទួលមួយច្បាប់។ ប៉ុន្តែដោយឡែក គឺដូចថាខ្ញុំចូលមកក្នុងសវនាការនេះ គឺខ្ញុំមានឯកសាររបស់ខ្ញុំដែរ ប៉ុន្តែឯកសារហ្នឹងសួរម្ដងមួយច្បាប់ៗ ដល់អ៊ីចឹងវាច្របូកច្របល់គ្នា។ ដូច្នេះបានខ្ញុំថា ឆ្លើយតបទៅវិញ ប្រហែលជាបានបីដង។ បានខ្ញុំថាអ៊ីចឹងឯង។

[១៣:៤៩:១៥]

**ស៖** ខ្ញុំសូមបញ្ជាក់ជាមួយនឹងលោកបន្តិច។ ម្សិលមិញសហព្រះរាជអាជ្ញាកញ្ញា សុង ឆវន្ត បានប្រគល់កំណត់ហេតុនៃការស្ដាប់ចម្លើយរបស់លោកជូនលោក គឺខ្ញុំនិយាយម្សិលមិញនៅក្នុងបន្ទប់សវនាការនេះ។ លោកបានទទួល លោកចាំថាបានចំនួនប៉ុន្មានទេ? ឯកសារហ្នឹងមានប៉ុន្មានទេ?

**ឆ៖** បាទ ម្សិលមិញខ្ញុំបានទទួលឯកសារដែរ ប៉ុន្តែអារឿងប៉ុនណានោះ ខ្ញុំអត់បានចាំទេ។ ពីព្រោះខ្ញុំមិនបានរាប់មើលឲ្យប៉ុន្មានៗមក គឺទុកមុខខ្ញុំនេះ ហើយដល់ពេលនេះចប់ហើយ គេយកវិញអស់ដែរ មិនដឹងប៉ុន្តែច្បាប់។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹង លោកចាំជួយបញ្ជាក់ជាមួយខ្ញុំមើល៍ ហើយលោកទទួលស្គាល់យ៉ាងម៉េច។ ខ្ញុំសូមជម្រាបលោកថា តាមឯកសារដែលយើងមាននៅក្នុងសំណុំរឿងនេះ កំណត់ហេតុនៃការស្ដាប់ចម្លើយរបស់លោកមានបួន។ ទី១ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩ នេះកិច្ចសម្ភាសន៍ទី១។ ទី២ គឺថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៩។ ទី៣ ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៩ និងទី៤ ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១០។ តើលោកអះអាងយ៉ាងម៉េចក្នុងករណីដែលថា ខ្ញុមាន -- មិនមែនខ្ញុំមានទេ គឺនៅក្នុងសំណុំរឿងរបស់យើងហ្នឹង មានកំណត់ហេតុនៃការស្ដាប់ចម្លើយរបស់លោករហូតដល់បួននោះ។ តើលោកស្គាល់ថា មានអ៊ីចឹងមែនអត់?

[១៣:៥១:៤៣]

**ឆ៖** ម្សិលមិញ ខ្ញុំបានឆ្លើយថាប្អូនដូចខ្ញុំបញ្ជាក់អ៊ីចឹង គឺថាពេលដែលទៅសម្ភាសនៅកន្លែងខ្ញុំហ្នឹង ដូចខ្ញុំបានថា -- ជម្រាបអ៊ីចឹង គឺជួនកាលថ្ងៃណេះមួយច្បាប់ទៅ ជួនកាលៗស្អែកមួយច្បាប់ ជួនកាលខានស្អែកម្តងទៀតអ៊ីចឹងទៅ។ ដូច្នេះ បានខ្ញុំថា តាមមើលប្រហែលជាបីច្បាប់ហ្នឹងទេ បាទ។ ហើយដល់ទៅលោកសួរ ខ្ញុំថា បើដល់ប្អូន គឺមានតែប្អូនច្បាប់ហ្នឹងឯង។

**ស៖** សូមអរគុណ។ ថ្ងៃសម្ភាសលើទី១ គឺថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩ មុនកាលបរិច្ឆេទហ្នឹង មុនថ្ងៃហ្នឹង មុនៗៗពេលសម្ភាសហ្នឹង មុនថ្ងៃហ្នឹង មុនថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩ ហ្នឹង ខ្ញុំសូមជម្រាបលោកថា កិច្ចសម្ភាសន៍ទាំងប្អូននេះ គឺធ្វើឡើងដោយតែអ្នកសម្ភាសតែពីរនាក់ដដែលៗទេ គឺលោក ស៊ឹម សុរិយ៉ា និងលោក ថូម៉ាស ហ្វ្រេគ្គនដ៍ ម៉ូរ៉ូ។ ខ្ញុំចង់សួរថា មុនកិច្ចសម្ភាសន៍លើកទី១នោះ លោកបានជួបជាមួយអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ?

[១៣:៥៣:៣២]

**ឆ៖** បាទ ចំពោះបញ្ហាសំណួរនេះ ខ្ញុំឆ្លើយថា មុននឹងសម្ភាស គឺគាត់បាន ថាទី១ ស្អែក ខ្ញុំមក បាទ។ ដូច្នេះ ឲ្យសំណួរអីហ្នឹងមើល បាទ។

**ស៖** បាទ សូមអរគុណ។ តើការជួបជជែក -- ខ្ញុំនិយាយជជែក ប្រជុំថ្ងៃនោះ មានការកត់ត្រាអីទេ?

**ឆ៖** បាទ មានការកត់ត្រាសម្រាប់ខាងលោកដែលទៅសួរសម្ភាសជាមួយខ្ញុំនេះ សម្រាប់ខ្ញុំអត់បានកត់ត្រាទេ។

**ស៖** ខ្ញុំសូមបញ្ជាក់ជូនលោក ខ្លាចក្រែងលោកច្រឡំ។ ខ្ញុំចង់និយាយថ្ងៃដែលលោកបានជួបអ្នកស៊ើបអង្កេតទាំងពីរនាក់នោះ មុនថ្ងៃទី១នៃការសម្ភាសជាផ្លូវការ គឺថ្ងៃសម្ភាសមុនថ្ងៃទី១ហ្នឹង។ សំណួរខ្ញុំបន្តទៀតថា មុននឹង គឺថ្ងៃសម្ភាសក្រៅផ្លូវការទៅចុះ មានធ្វើថតសំឡេងអីដែរអត់?

**ឆ៖** បាទ តាមខ្ញុំចាំគឺថ្ងៃដែលទៅសម្ភាសនុ៎ងអត់មានទៅពីរនាក់ម្តងទេ គឺទៅម្តងទាំងបីប្អូននាក់តែម្តង ហើយទៅមានថត មានសម្ភាស។

**ស៖** ខ្ញុំសូមបញ្ជាក់លោកដដែលទេថា ខ្ញុំអត់ទាន់ចូលដល់កិច្ចសម្ភាសន៍ផ្លូវការចាប់ពីសម្ភាសលើកទី១ ទេ។ ខ្ញុំចង់និយាយពីកិច្ចសម្ភាសក្រៅផ្លូវការមុនកិច្ចសម្ភាសលោកទី១ ហ្នឹង។ ខ្ញុំចង់ដឹងថា ការជួបរវាងលោក ហើយនិងមន្ត្រីអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតហ្នឹង ប្រព្រឹត្តទៅអត់រយៈពេលប៉ុនណា?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! មេធាវីអាចផ្អាកបន្តិចសិន!

[១៣:៥៦:០៧]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៥៧:៣៥]

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរដែលសួរដោយលោកមេធាវីជាតិការពារក្តីលោក អៀង សារី ដែលសួរលោកចុងក្រោយនេះទេ។ សំណួរនេះមិនពាក់ព័ន្ធទេ។

លោកមេធាវីសូមរៀបចំសំណួរណាដែលមានការពាក់ព័ន្ធទៅនឹងអង្គហេតុដែលអង្គជំនុំជម្រះកំណត់សម្រាប់ធ្វើសវនាការពិភាក្សាដេញដោលចំពោះសាក្សីរូបនេះ។

**លោក អាង ឧត្តម៖**

តុលាការជាទីគោរព! ក្រៅពីមុខងារការពារក្តី ខ្ញុំក៏មានមុខងារជួយតុលាការក្នុងការស្វែងរកការពិត--

**ប្រធានអង្គជំនុំ៖**

យើងបានសម្រេចរួចហើយ ហើយលោកមានសំណួរអីសួរទៀតទេ សូមអញ្ជើញ! យើងមានឆន្ទានុសិទ្ធិនៅក្នុងការដកចេញនូវកិច្ចពិភាក្សាដេញដោលណាដែលឥតប្រយោជន៍ ឥតស្វែងរកឈានទៅដល់ការរួមវិភាគទានស្វែងរកការពិត! យើងសម្រេចរួចហើយ សំណួរអម្បាញ់មិញនេះ។

[១៣:៥៩:២៤]

**លោក អាង ឧត្តម៖**

ខ្ញុំសូមបន្តសំណួរខ្ញុំទៀត។ ដោយសារតែខ្ញុំមិនអនុញ្ញាតឲ្យបន្តសំណួរអ្វីដែលខ្ញុំត្រូវសួរ អ៊ីចឹងខ្ញុំបន្តសំណួរខ្ញុំទៀត។

**សួរដោយលោក អាង ឧត្តម៖**

**ស៖** នៅក្នុងកិច្ចសម្ភាសន៍ទី១របស់លោក នៅលើឯកសារ E3/402។ នៅទំព័រចុងក្រោយភាសាខ្មែរគឺ ERN 00379450 ហើយអង់គ្លេស 00381037, បារាំង 00424052។ សំណួរចុងក្រោយនេះសួរថា “តើទូរលេខនោះមានរូបភាព ឬលក្ខណៈសរសេរដូចម្តេច?” លោកឆ្លើយថា “ខ្ញុំគ្រាន់តែចាំថា

ខាងក្រោមមានដាក់ថា មន្ទីរ៨៧០ ប៉ុណ្ណោះ។ ចំណែកឯខាងលើដាក់យ៉ាងម៉េច ខ្ញុំមិនចាំទេ”។ សំណួរខ្ញុំចង់សួរលោកថា កាលនុង លោកពិតជាបានឆ្លើយថា មន្ទីរ៨៧០ ឬផ្សេងពីនេះ?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយនឹងសំណួរនេះ ដូចខ្ញុំបានជម្រាបពីខាងដើមហើយគឺ ចំពោះសារទូរលេខដែលខ្ញុំបានទទួលនៅអូរកន្សែង អំរ៉ែ!បឹងកន្សែងនេះ គឺខ្ញុំគ្រាន់តែចាំបានថា មកពីមន្ទីរ៨៧០ បាទ។ ឯសរសេរយ៉ាងណានោះគឺ សរសេរដៃជាធម្មតា បាទ អត់មានវាយអង្គុលីលេខអីទេ គឺសរសេរដៃបាទ។ នេះកាលខ្ញុំដែលថាហៅខ្ញុំមកភ្នំពេញវិញ ហ្នឹងសរសេរដៃ ហើយ៨៧០ បាទ។

**លោក អាង ឧត្តម៖**

បាទ សូមអរគុណ។ តុលាការជាទីគោរព ខ្ញុំបានស្នើទៅសុំ សុំឲ្យអង្គភាពពាក់ព័ន្ធដើម្បីវាយចម្លងចេញនូវប្រតិចារឹកនៃកិច្ចសម្ភាសន៍លើកទី១នេះ នូវភាគដែលពាក់ព័ន្ធនេះ។ ប្រហែលជា២ឬ៣ថ្ងៃហើយ ថ្ងៃនេះ ខ្ញុំឃើញថាចេញមកហើយ ប្រតិចារឹករបស់ខ្ញុំ តែខ្ញុំមិនទាន់ឃើញមិនដឹងនៅឯណា។ ប្រហែលជាមានការ ឮសួរថាមានការដាក់លេខខុសយ៉ាងម៉េចអត់ទាន់ដឹង។ ដើម្បីបញ្ជាក់យ៉ាងណាមិញឲ្យច្បាស់ថា លោក អ៊ុង រ៉ែន ពិតជាបានចាំ ពិតជាបានឆ្លើយថា មន្ទីរ៨៧០ ឬយ៉ាងណានោះ ឬផ្សេងពីនោះ ខ្ញុំស្នើសុំតុលាការអនុញ្ញាតឲ្យអង្គភាពពាក់ព័ន្ធចាក់សំឡេងរបស់គាត់ ប្រហែលជា មើលទៅប្រហែលជាកន្លះ មិនដល់កន្លះនាទីទេ ប្រហែលជា២០វិនាទី។ គឺនៅឯកសារ D232/21R ចាប់ផ្ដើមពីនាទី ម៉ោង០២ នាទី២៤ ទៅម៉ោង០២ នាទីប្រហែលជា២៥។ សូមលោកមេត្តាអនុញ្ញាត!

[១៤:០៤:១៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ដោយក្ដីគោរពចំពោះការលើកឡើងរបស់សហមេធាវីការពារក្ដីដូចជាមិនចាំបាច់ មានភាពចាំបាច់ត្រូវការស្ដាប់ខ្សែអាត់សំឡេងនោះទេ។ យើងដឹងហើយថា សហមេធាវីការពារក្ដីស្នើសុំឲ្យធ្វើការវាយឡើងវិញទៅប្រតិចារឹក គឺវាពាក់ព័ន្ធទៅនឹងឯកសារ D232/21.1 នៅចុងបញ្ចប់នៃប្រតិចារឹកនេះ គឺបានលើកឡើងថា “អ្នកបកប្រែ៖ តើនរណាគេជាអ្នកឆ្លើយទៅលើខ្លឹមសារនេះ?” គឺនៅក្នុងនេះយើងឃើញវាមានមន្ទីរ៨៧០។ សាក្សីពិតជាបានឆ្លើយថា សារទូរលេខនោះមកពីមន្ទីរ៨៧០។ ដូច្នេះហើយយើងគ្មានភាពចាំបាច់អ្វីត្រូវស្ដាប់ខ្សែអាត់សំឡេងនេះឡើងវិញនោះទេ។

**លោក អាង ឧត្តម៖**

ខ្ញុំ កន្លែងវាមានបញ្ហាអីមួយ ព្រះរាជអាជ្ញាគាត់មានអាប្រតិចារឹកហ្នឹង ហើយខ្ញុំអ្នកសុំ ខ្ញុំអត់បានទទួល មិនដឹងជាបញ្ហាអី ខ្ញុំអត់ដឹង។ ខាងមន្ទីរ -- អង្គភាពពាក់ព័ន្ធអត់ទាន់បាន ឬមួយបញ្ជូនទៅតុលាការអត់បញ្ជូនមកខ្ញុំ ខ្ញុំអត់បានដឹង។ ខ្ញុំអត់ចង់ចាក់ អត់ចង់អីទេ តែបើបានដឹង ខ្ញុំក៏ស្រួលដែរ តែដោយសារខ្ញុំអត់មាន ខ្ញុំត្រូវចាក់សំឡេងរបស់កិច្ចសម្ភាសន៍សាក្សីហ្នឹងផ្ទាល់។ មួយណាក៏ខ្ញុំទទួលយកបានដែរ។ សូមអរគុណ។

[១៤:០៦:២៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:០៧:២០]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនៅលើសំណើសុំរបស់លោកមេធាវីជាតិការពារក្តីលោក អៀង សារី ដែលបានស្នើសុំឲ្យអង្គភាពពាក់ព័ន្ធចាក់ផ្សាយនូវខ្សែអាត់សំឡេង ឯកសារ D232/2.1R នេះ ដោយមូលហេតុមិនមានភាពចាំបាច់ទេ ហើយមានបញ្ហាអីគឺសាក្សីនៅទីនេះហើយ លោកអាចសួរដេញដោលបានតាមបច្ចេកទេសរបស់លោក នៅក្នុងការតាំងសំណួរដេញដោល។ ហើយការវាយតម្លៃភស្តុតាង គឺអង្គជំនុំជម្រះនឹងពិនិត្យ ពិចារណា វាយតម្លៃតាមសមត្ថភាព និងសមត្ថកិច្ចរបស់ខ្លួន។

**លោក អាង ឧត្តម៖**

សូមអរគុណលោកប្រធាន។ ក៏ប៉ុន្តែយ៉ាងណាក្តី ការអនុវត្តបែបនេះក៏ធ្លាប់មានដែរពីមុនមក។

**ប្រធានអង្គជំនុំ៖**

យើង -- វាមានលក្ខណៈដោយឡែកពីគ្នាណ៎ះ! វាមិនមែនតែមួយ ជាពុំគំរូសុទ្ធសាធនោះទេ។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា មានបញ្ហាអី? បញ្ហាដដែលនេះមិនគប្បីនិយាយទៀតទេ ព្រោះយើងបានសម្រេចរួចហើយ លើកលែងតែមានបញ្ហាថ្មីផ្សេងប៉ុណ្ណោះ ដែលអនុញ្ញាតឲ្យនិយាយ។

[១៤:០៨:៤៨]

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំចង់តែបញ្ជាក់ប្រតិចារឹកឲ្យបានច្បាស់លាស់ មិនមែនតែខ្ញុំទទួលព័ត៌មាននេះដោយសម្ងាត់ណាមួយនោះទេ។ គឺថាឯកសារនេះបានបញ្ជូនដំណឹងទៅដល់គ្រប់ភាគីនៅល្ងាចម្សិលមិញ

នោះ ទៅដល់គ្រប់ភាគីទាំងអស់ហើយ។ ដូច្នេះហើយ គឺថាមេធាវីអាចធ្វើការពិនិត្យ និងរកឯកសារនេះបាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឯកសារនេះត្រូវបានជូនដំណឹងទៅភាគីរួចហើយកាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ ២០១៣ វេលាម៉ោងបីហាសិបបួននាទី។

**លោក អាង ឧត្តម៖**

បាទ សូមអរគុណ។ ក៏ប៉ុន្តែតាមរយៈការឆ្លើយឆ្លងថ្មីៗនេះ ក្នុងពេលបាយខ្ញុំបានឃើញនេះ គឺថាឯកសារនោះត្រូវបានចុះលេខខុស លេខច្រឡំ។ ហើយអ៊ីចឹងបានគេអត់បានសម្រេច ខ្ញុំអត់បានទទួល។ តែយ៉ាងណាក្តី ខ្ញុំបន្តទៀតចុះ។

[១៤:០៩:៥០]

**សួរដោយលោក អាង ឧត្តម៖**

**ស៖** លោក អ៊ុង រ៉េន ម្សិលមិញលោកបានឆ្លើយដល់សហព្រះរាជអាជ្ញាដែរថា "លោក សឹន សេន គ្មានលេខ គ្មានឈ្មោះជាលេខកូដទេ លោក ឆ្លើយច្បាស់"។ តែក្រោយពីបង្ហាញឯកសារហួរហែមក ភ្លាមៗនោះ លោកឆ្លើយថា "អូ៎! បង៨៩ហ្នឹងគឺ សឹន សេន ហ្នឹងឯង"។ បាទ ខ្ញុំនិយាយ សឹន សេន តាមគាត់។ គាត់ឈ្មោះ សឹន សេន ទេ មិនមែន សុន សេន ទេ។ តែយើងហៅគាត់ជាភាសាអង់គ្លេសទៅទៅជា សុន អ៊ីចឹងទេ។ ឈ្មោះខ្មែរគាត់ សឹន សេន។ តើលោកអះអាងយ៉ាងម៉េច? មួយភ្លាមលោកឆ្លើយថា លោក សឹន សេន ហ្នឹងអត់មានលេខ ឈ្មោះជាលេខកូដទេ។ បន្ទាប់បន្តិចមកលោកឆ្លើយថា បង៨៩ហ្នឹងហើយ គឺសឹន សេន តើលោកអះអាងថាម៉េចដែរ?

**លោក អ៊ុង រ៉េន៖**

**ឆ៖** បាទ ចំពោះសំណួរនេះដូចខ្ញុំសូមបញ្ជាក់ថា ធម្មតាសំណួរដែលបានសួរនេះគឺខ្ញុំ គឺបានពិនិត្យពិចារណាហើយ ប៉ុន្តែអ្វីដែលខ្ញុំឆ្លើយទៅ គឺខ្ញុំមិនចាំត្រង់ថា គាត់មានលេខកូដ ទាល់តែមើលក្នុងសេចក្តីរាយការណ៍របស់ ធិន នេះបានខ្ញុំដឹងថាគាត់ បានជាខ្ញុំដឹងថា អូ៎!គាត់នៅមានប្រើលេខកូដនេះដដែល ហៅ៨៩ ហ្នឹងហើយ។

[១៤:១១:៤០]

**ស៖** ខ្ញុំអាចទទួលយកបាន បើសិនលោកឆ្លើយថាមិនចាំ។ ក៏ប៉ុន្តែកាលនោះលោកឆ្លើយថា

មិនមាន អាហ្នឹងខ្ញុំគ្រាន់សុំបញ្ជាក់លោកទេ។ ខ្ញុំតទៅសំណួរមួយទៀត ដែលមានលម្អិតនៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីលើកទី២របស់លោក គឺឯកសារ E3/84 ខ្ញុំអត់បានត្រៀមឯកសារនេះជូនលោក ខ្ញុំនឹកស្មានថាលោកបានទទួលឯកសារហ្នឹងម្សិលមិញហើយ អត់នឹកឃើញថា ឯកសារនោះត្រូវបានដកពីដៃលោកវិញ។ តែយ៉ាងណា ខ្ញុំនៅមានបញ្ហាំងនៅលើ។

**លោក អាង ឧត្តម៖**

ខ្ញុំសូមអនុញ្ញាតពីតុលាការបញ្ចាំងឯកសារទាំងនេះនៅលើកញ្ចក់ទូរទស្សន៍ដើម្បីជូនលោកតាមដាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

បាទ បើកក្បាលមីក្រូហ្វូន!

**លោក អាង ឧត្តម៖**

សូមទោស។

**សួរដោយលោក អាង ឧត្តម៖**

**ស៖** ភាសាខ្មែរគឺទំព័រទី៣ បើនិយាយពីលេខ ERN វិញគឺ 00398513, ជាភាសាអង់គ្លេស 00408395, ភាសាបារាំង 00434422។ នៅប្រហែលជាកណ្តាលបំផុតនេះ សំណួរមួយសួរថា តើគណៈ៨៧០--

**ប្រធានអង្គជំនុំ៖**

មានបញ្ហាអី? លោកតំណាងសហព្រះរាជអាជ្ញា។ សូមអញ្ជើញ!

[១៤:១៤:១០]

**លោក ឌេល លីសាក់៖**

ជាការពិតលោកប្រធាន គឺឯកសារដែលដកស្រង់ ដកចេញពីសាក្សីកាលពីម្សិលមិញនោះ គឺថាយើងខ្ញុំគិតថាបានដកចេញមែន ដូច្នេះហើយខ្ញុំនៅសល់មួយច្បាប់ទៀត។ ហើយប្រសិនបើសាក្សីត្រូវការនោះគឺថាខ្ញុំអាចផ្តល់ជូនបាន។ ហើយខ្ញុំគិតថាសាក្សីចាំបាច់មានឯកសារនេះនៅចំពោះមុខ លោកប្រធាន។

**លោក អាង ឧត្តម៖**

បាទ សូមអរគុណព្រះរាជអាជ្ញា។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាស់ពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីទាំងបីទាំងកំណត់ហេតុទាំងបីតែម្តងទៅ ដែលបានដាក់ជូនកាលពីម្សិលមិញ យកតែទាំងកំណត់ហេតុដែលសួរដេញដោលដោយអ្នកស៊ើបអង្កេត។

**លោក អាង ឧត្តម៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាង ឧត្តម៖**

**ស៖** លោក អ៊ុង រ៉េន ខ្ញុំនិយាយឡើងវិញ គឺនៅទំព័រ៣ ខ្ញុំមិនបាច់និយាយឡើងវិញជាលេខ ERN ទេ នៅកណ្តាលគេហ្នឹង សំណួរមួយថា "តើគណៈ៨៧០ គឺជាគណៈមជ្ឈិមមែនទេ?" ហើយលោកឆ្លើយថា "បាទ ជាគណៈមជ្ឈិម ដែលអាចនិយាយបានថា គឺជាមេដឹកនាំជាន់ខ្ពស់"។ សំណួរខ្ញុំ គឺថា តើគណៈមជ្ឈិម និងគណៈ៨៧០ហ្នឹង មានសញ្ញាណ មានភាពខុសប្លែកគ្នាយ៉ាងម៉េចដែរ?

[១៤:១៦:២៧]

**លោក អ៊ុង រ៉េន៖**

**ឆ៖** បាទ ចំពោះបញ្ហានេះ មានពីរ។ ទី១ គេហៅថា មន្ទីរ៨៧០។ ឯទី២ គេហៅថាគណៈ៨៧០។

**ស៖** តើទី១ មន្ទីរ៨៧០? ទី២ គណៈ៨៧០ហ្នឹង ខុសគ្នា ឬដូចគ្នា?

**ឆ៖** ខុសគ្នា ដូច្នេះគឺមន្ទីរ៨៧០ គឺចេញមកពីគណៈ៨៧០ ហ្នឹង បានវាកើតជាមន្ទីរ៨៧០។

**ស៖** ហើយលោកថា គណៈមជ្ឈិម អាចនិយាយបានថា គឺមេដឹកនាំជាន់ខ្ពស់។ តើលោកអាចបញ្ជាក់បានទេថា មេដឹកនាំជាន់ខ្ពស់ហ្នឹង មានសមាសភាពយ៉ាងម៉េចខ្លះទៅ?

**ឆ៖** បាទ បញ្ហានេះ ខ្ញុំបញ្ជាក់ថា ក្នុងគណៈមជ្ឈិមហ្នឹង គឺដូចខ្ញុំជាបានបញ្ជាក់ពីមុនរួចមកហើយ គឺខ្ញុំដឹងថា ទី១ គឺប៉ុល ពត, ទី២ គឺ នួន ជា ចំពោះខ្ញុំដឹងតែពីរនាក់ហ្នឹងទេ ដែលក្នុងគណៈហ្នឹងឯង។ ក្រៅនោះទៀត ខ្ញុំមិនដឹង ឧមាថាលោក អៀង សារី, ខៀវ សំផន មិនដឹងជាគាត់ធ្វើ-- វាក្នុងៗហ្នឹងដែរ ប៉ុន្តែមិនដឹងជាគាត់ធ្វើ ចូលក្នុងហ្នឹងដែរក៏មិនដឹង។ ដូច្នេះ បើនិយាយក្នុងគណៈវិញ តែពីរបី -- អ៎! បីបួននាក់ឡើងទៅ ហៅ គណៈហើយ។ ប៉ុន្តែខ្ញុំដឹងតែពីរនាក់ទេ ដែលធំជាងគេ។ ដូច្នេះ គណៈ៨៧០ហ្នឹងគឺ ប៉ុល ពត, នួន ជា ហ្នឹងឯង។ ហើយទៅក្រោមទៀត ខ្ញុំក្តាប់មិនបាន មិនដឹងអ្នកណាទេ ព្រោះ

អត់ដែលប្រកាសថា ឥឡូវមជ្ឈិមមានប៉ុនណេះៗ បាទឲ្យខ្ញុំនិយាយថាម៉េច។

**ស៖** បាទ សូមអរគុណ។ សំណួររបស់ខ្ញុំបន្តទៀត គឺទំព័រ៤ គឺជាភាសាខ្មែរដែលមានលេខ ERN 00398514, ជាភាសាអង់គ្លេស 008396, ជាភាសាបារាំង 00434423។ សំណួរចម្លើយនៅខាងលើគេបំផុត។ ខ្ញុំសូមអានសំណួរនិងអានចម្លើយ បានខ្ញុំសួរលោក "សំណួរ៖ ហេតុដូចម្ដេចបានជាមន្ទីរសេនាធិការ និងមន្ទីរកងពល៨០១ ដែលសុទ្ធតែមានម៉ាស៊ីនទូរលេខដូចគ្នា មិនផ្ញើមកឲ្យ ស៊ូ សារឿន ដែលពេលនោះកំពុងនៅមន្ទីរសេនាធិការនៅភ្នំពេញនោះ? ឆ្លើយ៖ តាមខ្ញុំសង្កេតបញ្ហាដែលទាក់ទងនឹងវិន័យដូចនេះ គឺត្រូវតែឆ្លងកាត់មន្ទីរ៨៧០។ ខ្លឹមសារបច្ចេកទេស ឬក៏សមរភូមិអាចនឹងត្រូវផ្ញើទៅមកដោយផ្ទាល់បាន។ តាមខ្ញុំដឹងអ្នកធំៗដូចជា គណៈមជ្ឈិម ឬគណៈ៨៧០ ជាទូទៅតែងតែជជែកពិភាក្សាគ្នាអំពីបញ្ហាដែលកើតឡើង ទើបសម្រេចអ្វីមួយ"។ សំណួរខ្ញុំថា លោកដឹងថាអ្នកធំៗគណៈមជ្ឈិម ឬគណៈ៨៧០ហ្នឹង ជាទូទៅ ហើយតែងតែពិភាក្សាគ្នាអំពីបញ្ហាដែលកើតឡើង ទើបសម្រេច។ តើលោកដឹង -- "តាមខ្ញុំដឹង" នេះសម្ដីរបស់លោក។ ខ្ញុំចង់សួរលោកថា តើលោកដឹងពីកិច្ចពិភាក្សាជជែកគ្នារបស់គណៈមជ្ឈិម ឬគណៈ៨៧០ ហ្នឹងយ៉ាងដូចម្ដេចទៅ?

[១៤:២២:២០]

**ឆ៖** បាទ ខ្ញុំឆ្លើយលើបញ្ហាសំណួរនេះ គឺក្នុងនេះតាមពិត គឺជាសំណួរដែលខ្ញុំបានឆ្លើយពិតមែន តែខ្ញុំចង់បញ្ជាក់ថា ក្នុងខ្លឹមសារទាំងអស់នេះ សម្រាប់ខ្ញុំដកពិសោធន៍ គឺថាផ្ទាល់ខ្លួនមកប្រៀបធៀបនឹងគណៈ៨៧០នេះ។ ដូច្នេះក្នុងកងមួយ បើសម្រេចអ្វីម្នាក់ឯងក៏ទៅមិនរួចទេ វាទាល់តែក្នុងគណៈហ្នឹងសម្រេចថា ឥឡូវយ៉ាងនេះ យ៉ាងនោះឯកភាពគ្នាបានសម្រេចបាន។ ដូច្នេះក្នុងគណៈ៨៧០ មិនមែនមានតែម្នាក់ពីរនាក់ហ្នឹងទេ។ ហើយមានប៉ុន្មាននាក់ក្នុងគណៈរបស់គាត់ហ្នឹង គណៈកម្មការអចិន្ត្រៃយ៍របស់គាត់ហ្នឹង គាត់អាចពិគ្រោះគ្នាហើយ បានសម្រេចទៅគាត់ដោះស្រាយបញ្ហានេះ បញ្ហានោះបាទ។

**ស៖** ពេលអស់លោកទាំងអស់ហ្នឹងប្រជុំ ដើម្បីសម្រេចពីកិច្ចការអ្វីមួយនោះ។ ពេលប្រជុំពិភាក្សាហ្នឹងលោកដែលបាន ដែលធ្លាប់ចូលរួមប្រជុំជាមួយអស់លោកនុ៎ងទេ?

[១៤:២៣:៤០]

**ឆ៖** បាទ សម្រាប់ផ្ទាល់ខ្លួនខ្ញុំ គឺគ្មានសិទ្ធិអីទៅចូលរួមទេ ក្នុងការប្រជុំជាមួយខាងលើៗអី។ មិនពិគ្រោះពិភាក្សារឿងអីក្នុងគណៈរបស់គាត់ហ្នឹងមិនដែលចូលរួមទេ បាទ។ តែគ្រាន់តែពិសោធន៍កន្លងមកដូចជា ដូចខ្ញុំបានបញ្ជាក់អ៊ីចឹង។ បើក្នុងអង្គភាពតែមួយ បើសម្រេចម្នាក់ឯង ក៏មិនឯកភាពគ្នា។ វា

ទាល់តែពីរនាក់បីនាក់ក្នុងគណៈហ្នឹងបានសម្រេចបាន។ ដូច្នេះខ្ញុំថា បញ្ហា៨៧០ នេះក៏ដូចតែគ្នាដែរ ពីព្រោះលំនាំតែមួយ។

**ស៖** លោកមិនបានចូលរួមប្រជុំកិច្ចពិភាក្សារបស់អស់លោកទាំងប៉ុន្មានគណៈហ្នឹងទេ។ ក្រោយពីការប្រជុំរបស់អស់លោកប៉ុន្មានគណៈហ្នឹងមក តើមានអ្នកណាបាន -- ខ្ញុំចង់និយាយអ្នកណាក៏បានឲ្យតែលោក -- តើមានអ្នកណាដែលប្រាប់លោកពីកិច្ចដំណើរការនៃការប្រជុំ របៀបវារៈនៃការប្រជុំ និងសេចក្តីសម្រេចនៃកិច្ចប្រជុំទាំងអស់ហ្នឹងទេ? ដែលមានអ្នកណាប្រាប់លោកក្រោយពីការប្រជុំណាមួយនោះទេ?

**ឆ៖** បាទ ចំពោះបញ្ហានេះ គឺខ្ញុំ ដូចខ្ញុំបញ្ជាក់អ៊ីចឹងគឺថា ពីព្រោះខ្ញុំនៅខាងក្រោម ហើយគ្មានក្នុងគណៈមជ្ឈិម ឬក៏អីបានមកប្រាប់ខ្ញុំអ៊ីចេះអ៊ីចុះគឺអត់ទេ បាទ។ ដូច្នេះគ្រាន់តែពេលខ្លះក្នុងខ្លឹមសារឯកសារអីគឺ គណៈមជ្ឈិមបានឯកភាពគ្នាអ៊ីចេះៗអី សម្រេចប្រមូលកម្លាំង ឬក៏រៀបចំកម្លាំងយ៉ាងនេះយ៉ាងនោះហត្ថលេខាខាង៨៧០។ អាហ្នឹងដែលឃើញ។ ប៉ុន្តែឲ្យខ្ញុំទៅទាក់ទិនអីសម្រេច ឬក៏អ្នកណាមកប្រាប់ មិនមែនគណៈអចិន្ត្រៃយ៍ ឬគណៈមជ្ឈិមមកប្រាប់ខ្ញុំឯណា ខ្ញុំមានសិទ្ធិឯណាទៅឲ្យអ៊ំៗ បងៗទាំងអស់មកប្រាប់ខ្ញុំ។

[១៤:២៦:០០]

**ស៖** សូមអរគុណ។ អ៊ីចឹងដោយហេតុថា លោកអត់ដែលបានចូលរួមប្រជុំជាមួយអស់លោកនៅក្នុងគណៈៗទាំងអស់ហ្នឹងទេ ហើយក៏មិនដែលបានឮពីកិច្ចប្រជុំហ្នឹង ពីអ្នកណាម្នាក់ដែលនោះ ខ្ញុំអាច -- បើខ្ញុំខុស ជួយកែ-- ខ្ញុំអាចនិយាយបានថា ការដែលលោកដឹងថា ជាទូទៅតែងតែមានការជជែកពិភាក្សាគ្នាអំពីបញ្ហាកើតឡើង ទើបសម្រេចបាននោះ ជាការសន្និដ្ឋាន ជាការស្មានរបស់លោកទេ។ តើត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ អានេះសម្រាប់ ដូចខ្ញុំបានបញ្ជាក់អ៊ីចឹង គឺសម្រាប់អង្គភាព គឺមានបញ្ហាអីគឺសម្រេចគ្នាហើយ។

**ស៖** ខ្ញុំចូលមកដល់សំណួរថ្មីទៀត គឺនៅទំព័រទី៧ គឺ ERN លេខ 0 -- ជាភាសាខ្មែរ 00398517, អង់គ្លេស 00408399, បារាំង 00434426។ នៅសំណួរមួយដែលគេសួរលោកថា "នៅពេលដែលកងពល១៤ ដូរទៅជា១០៨ ហ្នឹង តើគេប្រជុំគ្នានៅឯណា? គេរៀបចំយ៉ាងម៉េច? តើអ្នកណាចូលរួមខ្លះ?" ខ្ញុំខុស សហការី -- សហភាតាខ្ញុំថាខ្ញុំខុសលេខ អានលេខ។ ខ្ញុំសូមអានម្តង

ទៀត "នៅពេលដែលកងពលលេខ១៤ ដូរទៅជា៨០១ហ្នឹង តើគេប្រជុំគ្នានៅឯណា? គេរៀបចំយ៉ាងម៉េច? តើអ្នកណាចូលរួមខ្លះ?" ហើយលោកឆ្លើយថា "កាលពីប្រកាសកងពល៨០១ គឺមានថ្នាក់ដឹកនាំជាន់ខ្ពស់ទាំងអស់ចូលរួម គឺមាន ប៉ុល ពត, នួន ជា, អៀង សារី, សុន សេន ជាអ្នកប្រកាសតែងតាំងនៅស្តាតអូឡាំពិក ក្រោយពីរំដោះភ្នំពេញបានប្រហែល១៥ថ្ងៃ"។ សំណួររបស់ខ្ញុំ គឺថាកិច្ចប្រជុំហ្នឹងប្រព្រឹត្តឡើងនៅប្រហែលជា១៥ថ្ងៃ បន្ទាប់ពីរំដោះភ្នំពេញអ៊ីចឹង តើលោកនៅរក្សាចម្លើយហ្នឹងឬអត់?

[១៤:២៩:២៥]

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់សាជាថ្មី គឺទី១គឺ មុននឹងវៃភ្នំពេញ គឺកងពល១៤បាទ--

**ស៖** សូមទោសលោក លោក -- ខ្ញុំមិនចង់ឱ្យខាតពេលច្រើន។ ខ្ញុំចង់សួរលោកថា លោកបាននិយាយថា "ការប្រជុំនៅស្តាតអូឡាំពិកហ្នឹង គឺនៅប្រហែលជា១៥ថ្ងៃក្រោយពីរំដោះភ្នំពេញ"។ តើលោកនៅរក្សាពេលហ្នឹងអ៊ីចឹងឬអត់ ១៥ថ្ងៃក្រោយរំដោះភ្នំពេញហ្នឹង គេប្រជុំបង្កើតកងពលហ្នឹង ៨០១ ហ្នឹងមែនឬអត់?

**ឆ៖** បានខ្ញុំនៅចាំថាថ្ងៃ១៥ហ្នឹង គឺបង្កើតកងពល៨០១។ ទិសដៅរៀបចំ គឺថាត្រៀមទៅកន្លែងផ្សេង ទៅរតនគិរី។

**ស៖** លោកមានប្រសាសន៍ថា ថ្ងៃ១៥ តែក្នុងនេះលោកថាប្រហែល១៥ថ្ងៃក្រោយរំដោះភ្នំពេញ។ រំដោះភ្នំពេញនេះ ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥។ អ៊ីចឹង១៥ថ្ងៃក្រោយមក ទើបមានមហាសន្និបាតកិច្ចប្រជុំហ្នឹង។ តើលោកនៅរក្សាអ៊ីចឹងឬអត់? សូមលោកឆ្លើយម្តងទៀត។

**ឆ៖** បាទ ខ្ញុំនៅរក្សាពាក្យហ្នឹងដដែល។

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរសំណួរបន្ត កាលពីប្រកាសកងពល៨០១ហ្នឹង គឺមានថ្នាក់ដឹកនាំជាន់ខ្ពស់ទាំងអស់ចូលរួម គឺមានប៉ុល ពត, នួន ជា, អៀង សារី, សឺន សេន។ ថ្នាក់ដឹកនាំជាន់ខ្ពស់ទាំងអស់មានតែប៉ុន្មាននាក់ហ្នឹងទេ អ៊ីចឹងមែនទេ?

[១៤:៣១:៣០]

**ឆ៖** តាមពិតនៅក្នុងកន្លែងចម្លើយរបស់ខ្ញុំដែលសួរមុនៗ ខ្ញុំបានបញ្ជាក់ហើយគឺថាមានតែ ប៉ុល ពត, នួន ជា, អៀង សារី និង សុន សេន។

**ស៖** បាទ សូមអរគុណ។ នៅថ្ងៃសវនាការម្សិលមិញ ក៏មានសំណួរព្រះរាជអាជ្ញាសួរដែលថា ពេលប្រកាសចាត់តាំងហ្នឹង មានបីបួននាក់នឹងចូលរួម។ ហើយគេបានសួរថា "តើលោកស្គាល់លោក

អៀង សារី យ៉ាងម៉េចទៅ?" លោកបានឆ្លើយថា គឺលោកមិនយល់ដែរ។ អ៊ីចឹងខ្ញុំសូមសួរលោក ពេលមហាសន្និបាតហ្នឹង ហេតុអីបានលោកដឹងថាអ្នកណាឈ្មោះអី អ្នកណាឈ្មោះអី ដែលបានចូលរួមអស់លោកធំៗអស់ហ្នឹង?

**ឆ៖** បាទ ខ្ញុំ ដូចខ្ញុំបញ្ជាក់អ៊ីចឹង គឺកាលដែលរៀបចំ ខ្ញុំដឹងតែប៉ុនណា គឺខ្ញុំរៀបរាប់បានតែប៉ុណ្ណឹង។ ហើយក្រៅពីនោះទៀត គឺខ្ញុំមិនបានដឹងទេ ហើយតាមពិតអស់លោកនៅខាងក្រោយខាងក្រោមទៀតមក ដូចជាលោក ខៀវ សំផន អី។ តាមពិតខ្ញុំមិនដែលឃើញ មិនដែលស្គាល់ទេ ហើយអាដែងន៉ែ អៀង សារី អីនេះ។ ទើបតែមកដល់ហ្នឹង គឺបានឃើញនៅក្នុងសារដែលការរៀបចំចាត់តាំងតែម្តង។ ហើយក៏មិនដឹងនេះទេ គឺដឹងថាច្បាស់ជាមេធំហើយ។ ហើយកន្លងមកឮ ដល់ពេលនេះគឺឃើញថាបង អៀង សារី អីអ៊ីចេះៗអ៊ីចឹងទៅ បានយល់ថាមេដឹកនាំនេះ។ បើថា សុន សេន គឺខ្ញុំច្បាស់លាស់របស់ខ្ញុំ គឺពីព្រោះគាត់រៀបចំវ៉ៃភ្នំពេញ។ ហើយក្រៅពីនោះទេទៀត--

[១៤:៣៤:០០]

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមបន្តទៅទៀត។ សូមអរគុណដែលខ្ញុំបានកាត់លោក ហើយសូមអធ្យាស្រ័យផង។ សំណួរអំមិញហ្នឹង ដែលសហព្រះរាជអាជ្ញាបានសួរហ្នឹង វានៅក្នុងចម្លើយរបស់លោក ឯកសារដដែលហ្នឹង ពីទំព័រ៨ ទំព័របន្ទាប់។ ខ្ញុំសូមសួរសំណួរហ្នឹងតែមួយទៀតទេ ដើម្បីឲ្យច្បាស់គឺនៅទំព័រ៨ហ្នឹង គឺខ្មែរ ERN 003958-- អ៉! សូមទោស 398518, អង់គ្លេស 408400, បារាំង 00434427។ គេសួរលោកថា "តើហេតុអ្វីបានជាលោកស្គាល់ថា អ្នកនោះជា ប៉ុល ពត, ជា អៀង សារី, ជា នួន ជា, ជា សុន សេន" ហើយលោកឆ្លើយថា "សោម បានឧទ្ទេសនាមនៅក្នុងទីនោះ"។ ខ្ញុំចង់សួរថានៅពេលនោះ គេប្រកាសលោក អៀង សារី ថា គេមិនហៅលោកទេ សូមទោស គេហៅថា អៀង សារី ឬក៏សមមិត្ត អៀង សារី អ៊ីចឹងដែរ ឬក៏យ៉ាងម៉េច?

**ឆ៖** ចំពោះពេលនោះ គឺថានៅក្នុងពេលឧទ្ទេសនាមប្រកាសចាត់តាំងហ្នឹង គឺថាតាមពិតគេហៅ មិនហៅសមមិត្តទេ គេហៅ បងៗ។

[១៤:៣៦:០៧]

**ស៖** បន្ទាប់ពីបងមក គេបញ្ចេញឈ្មោះឬអត់?

**ឆ៖** បាទ បន្ទាប់ពីបងមក គេបញ្ចេញឈ្មោះ។ ឧទាហរណ៍ថា "បងទី១", "បងទី២"។ បងទី១ គឺដឹងថា ប៉ុល ពត។ បងទី២ គឺដឹងថា បង នួន ជា ហើយបាន បង អៀង សារី, បងអីអ៊ីចឹងទៅ។

**ស៖** បាទ សូមអរគុណលោក។ ខ្ញុំសល់តែមួយសំណួរទៀតទេនឹងសួរលោក គឺទំព័រដែលខ្ញុំអានអម្បាញ់មិញដដែលហ្នឹង ហើយដែលមានសំណួរចម្លើយរបស់លោកច្រើន ខ្ញុំសូមអានបន្តបន្ទាប់ ហើយចាំលោកជួយបញ្ជាក់ឲ្យខ្ញុំ។ សំណួរ "មុនពេលមកប្រកាសកងពល៨០១ តើលោកបានជួបមេដឹកនាំប៉ុន្មាននាក់ហ្នឹងទេ?" លោកឆ្លើយថា "ខ្ញុំធ្លាប់នៅពេលមុនបែកភ្នំពេញ"។ អ៊ីចឹង ខ្ញុំសង្ខេបមកវិញថា មុនពេលបែកភ្នំពេញ លោកបានជួបមេដឹកនាំប៉ុន្មាននាក់ហ្នឹង គឺចង់សំដៅប្អូននាក់អំមិញដែលលោកនិយាយអំមិញហ្នឹង។ សំណួរបន្ទាប់ទៀត សួរថា "លោកធ្លាប់បានជួបមេដឹកនាំទាំងនេះ នៅមុនពេលបែកភ្នំពេញ? តើលោកបានជួបនៅទីណា? ក្នុងឱកាសអ្វី?" ហើយលោកឆ្លើយថា "ខ្ញុំបានជួប សឺន សេន តែម្នាក់ទេ" អ៊ីចឹងចម្លើយខាងលើលោកឆ្លើយថា លោកធ្លាប់បានជួបអ្នកប៉ុន្មាននាក់ហ្នឹង មុនបែកភ្នំពេញ។ ចម្លើយបន្ទាប់មក លោកឆ្លើយថា "បានជួបអ្នកអស់ហ្នឹងមុនហ្នឹង តែលោក សឺន សេន ម្នាក់ទេ"។

[១៤:៣៨:២៩]

សំណួរបន្ទាប់ទៀត "តើពេលនោះ លោកមានបានជួបអ្នកណាផ្សេងទៀត ក្រៅពី សឺន សេន ទេ?" ហើយលោកឆ្លើយថា "ខ្ញុំមិនដែលជួបទេ"។ អ៊ីចឹង វាសំណួរទី១ ថាបានជួបអ្នកទាំងអស់ប៉ុន្មាននាក់ហ្នឹង មុនបែកភ្នំពេញ។ ហើយទី២ លោកថា មុនហ្នឹងលោកជួបតែ សឺន សេន។ ហើយក្រោយទៀត លោកថា ក្រៅពី សឺន សេន លោកអត់បានជួបអ្នកណាទេ។ តើលោកអះអាងយ៉ាងម៉េចចំពោះភាពខុសភាពគ្នាទាំងនេះ?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយនឹងសំណួរនេះ។ ជារួមមក ខ្ញុំនៅតែប្រកាន់ថា ខ្ញុំជួបតែ សុន សេន ម្នាក់គត់ មុនវៃភ្នំពេញ បាទ។ អត់មានបងណា ឬនរណាដែលមានក្រៅពីហ្នឹង បានជួបទេ។ ទើបតែចូលភ្នំពេញហើយ បានគេឃើញអ្នកនេះ អ្នកនោះ បានខ្ញុំស្គាល់តាមរយៈហ្នឹង។ មុននឹងប្រកាសកងពល៨០១ នៅស្តាតនេះ។ អត់មានស្គាល់មុនបែកភ្នំពេញទេ។ បើស្គាល់មុនបែកភ្នំពេញ ខ្ញុំស្គាល់តែម្នាក់នុ៎ងឯង។

[១៤:៣៩:៥៤]

**ស៖** បាទអ៊ីចឹង ខ្ញុំអាចសរុបសេចក្ដីថា មុនពេលប្រកាសកងពល៨០១ហ្នឹង លោកបានជួបតែ សឺន សេន។ អ៊ីចឹង ម្នាក់ទេ? អ៊ីចឹង ត្រឹមត្រូវទេ?

**ឆ៖** បាទ។

**លោក អាង ឧត្តម៖**

បាទ សូមអរគុណលោក អ៊ុង រ៉ែន ខ្ញុំអស់សំណួរសួរលោកហើយ។ យ៉ាងណាក្តីតាងនាមលោក អៀង សារី ខ្ញុំទាំងពីរនាក់សូមអរគុណលោកជាច្រើនដែលបានឡើងមកផ្តល់សក្ខីកម្មជូនតុលាការ ដើម្បីជួយតុលាការក្នុងការស្វែងរកការពិត។ សូមលោកបានប្រកបសេចក្តីសុខសប្បាយចាប់ពីពេលលោកធ្វើដំណើរត្រឡប់ទៅវិញ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ម៉េចទៅលោក ម៉ៃខល កាណាវាស?

[១៤:៤០:៥១]

**លោក ម៉ៃខល កាណាវាស៖**

ជម្រាបសួលោកប្រធាន លោក លោកស្រីចៅក្រម អស់លោក លោកស្រីទាំងក្នុង និងក្រៅបន្ទប់សវនាការ។ ខ្ញុំសូមធ្វើការបញ្ជាក់ និងសូមសំណើសំណូមពរមួយ។ ការបញ្ជាក់នេះ គឺថាយើងបានដាក់ជូននៅផ្នែកមួយនៃខ្សែអាត់ថតសំឡេង មិនដឹងថាធ្វើឡើងដោយចេតនា ឬអចេតនាទេ។ ប៉ុន្តែសហព្រះរាជអាជ្ញាបាននាំឲ្យអង្គជំនុំជម្រះយល់ខុស ដោយសារថា គឺផ្នែក ជាមួយផ្នែកមួយដែលយើងចង់ឲ្យធ្វើទៅជាប្រតិចារឹកដែលបានដាក់កាលពីម្សិលមិញ។ ដូច្នេះខ្ញុំសូមឲ្យអង្គជំនុំជម្រះចេញសេចក្តីសម្រេចឲ្យបានច្បាស់លាស់ពាក់ព័ន្ធទៅនឹងខ្សែអាត់សំឡេងនេះ។ ដោយសារយើងយល់ឃើញថា អង្គជំនុំជម្រះបានដាក់មកនេះអាចធ្វើឲ្យអង្គជំនុំជម្រះមានការយល់ច្រឡំ ដោយខ្ញុំយល់ឃើញថា អង្គជំនុំជម្រះបានសម្រេចទៅលើបញ្ហាការសម្ភាសដោយមានថតខ្សែអាត់សំឡេងនេះកាលពីមុនរួចមកហើយ។

[១៤:៤១:៥៥]

ដូចដែលសាក្សីបានបញ្ជាក់ហើយនៅក្នុងកិច្ចសម្ភាសន៍ទី១ គឺថាមិនមានការថតជាសំឡេងទេ ប៉ុន្តែមានការកត់ត្រាដោយអ្នកស៊ើបអង្កេត ហើយការកត់ត្រាទាំងនេះគ្រាន់តែជាផ្នែកៗនៃការស៊ើបអង្កេតតែប៉ុណ្ណោះ។ ហើយជាការពិតទៅវាគ្រាន់តែផ្នែកមួយនៃកំណត់ហេតុស្តាប់ចម្លើយតែប៉ុណ្ណោះ។ ហេតុដូច្នេះឯងយើងខ្ញុំសូមសំណូមពរឲ្យអង្គជំនុំជម្រះធ្វើការស៊ើបអង្កេតទៅលើបញ្ហានៃការស៊ើបអង្កេតពាក់ព័ន្ធទៅនឹងកំណត់ត្រាដែលធ្វើការស៊ើបអង្កេតដោយមិនមានការថតជាខ្សែអាត់សំឡេងនោះ។

នេះគឺជាការសុំបញ្ជាក់មួយហើយ និងជាសំណូមពរផង ដោយសារថា យើងកំពុងតែនិយាយគ្នាអំពីប្រភពនៃការដឹងឮថា តើយើងចង់ដឹង ថាតើកំណត់ត្រាមួយណាដែលយកនោះ? ថាតើនៅពេលសាក្សីផ្តល់ចម្លើយនោះមានការកត់ត្រា មានការថតខ្សែអាត់សំឡេងទេ? បើមិនមានព័ត៌មាននេះទេ គឺខ្ញុំសូមសង្កត់ធ្ងន់ថា គ្រាន់តែស្តាប់ទៅលើខ្សែអាត់នោះ គឺវាជាហេតុផលមួយហើយ ដែលថាអាចឱ្យអង្គជំនុំជម្រះ គឺថាអាចនឹងមានការបដិសេធដោយដល់សំណើរបស់យើងខ្ញុំ។ សូមអរគុណ។

[១៤:៤៣:១៧]

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ការដែលធ្វើឱ្យមានការយល់ច្រឡំនោះ គឺថាពីក្រុម អៀង សារី នោះទេ។ ខ្ញុំមិនបាននិយាយថា ក្រុមមេធាវីការពារក្តីមួយណាដែលជាអ្នកស្នើសុំនោះទេ។ ដូច្នេះខ្ញុំគ្រាន់តែយល់ឃើញថា មេធាវីគឺមួយក្រុមក្នុងចំណោមមេធាវីដែលបានស្នើសុំឱ្យផ្តល់នូវខ្សែអាត់ថតសំឡេងដើម្បីយកទៅធ្វើជាប្រតិចារឹក។ នៅពេលដែលមេធាវីការពារក្តីក្រោកឡើង ហើយដោយបញ្ជាក់ថាសាក្សីមិនបាននិយាយនៅក្នុងកិច្ចសម្ភាសន៍របស់គាត់ថា សារទូរលេខនោះមកពីមន្ទីរ៨៧០ នោះទេ។ មិនមានការធ្វើឱ្យទៅជាប្រតិចារឹកពីខ្សែអាត់ថតសំឡេងនោះទេ យើងខ្ញុំយល់ច្បាស់ថា សាក្សីនិយាយថាសារទូរលេខមកពីមន្ទីរ៨៧០ ខ្ញុំមិនដឹងថា មេធាវីក្រុម អៀង សារី ឬក្រុមដទៃទៀតយល់យ៉ាងម៉េចទេ? គួរណាស់ជំទាស់តាំងពីម្សិលមិញ ប៉ុន្តែនៅពេលដែលមេធាវីឡើងនិយាយថា សាក្សីមិនបាននិយាយនៅក្នុងខ្សែអាត់ទេ។ ពេលពីម្សិលមិញគាត់និយាយថា សារទូរលេខនេះ គឺពិតជាមកពីមន្ទីរ៨៧០ ហើយ។

[១៤:៤៤:៤៣]

**លោក ម៉ៃខល កាណាវាស៖**

យើងមានផ្នែកពីរនៃខ្សែអាត់សំឡេងនោះ។ សហព្រះរាជអាជ្ញា ឡើងនិយាយថា អ្វីដែលយើងខ្ញុំដាក់ក្នុងសំណុំរឿងនោះ គឺថាគាត់ -- យើងបានធ្វើសំណើសុំដាច់ពីគ្នា ដោយសារយើង បើសិនណាជាៗគាត់ស្តាប់ខ្សែអាត់គាត់ថតសំឡេងហ្នឹង គឺគាត់អាចនឹងមានការជំទាស់ហើយ។ នេះជាការធ្វើឱ្យអង្គជំនុំជម្រះយល់ច្រឡំហើយ នូវអ្វីដែលបានដាក់ចូលទៅក្នុងសំណុំរឿង។ ហេតុដូច្នេះបានជាខ្ញុំស្នើសុំឱ្យមានការដាក់ខ្សែអាត់សំឡេងនេះ ធ្វើឱ្យជាប្រតិចារឹកដាក់ទៅក្នុងសំណុំរឿង។ ដោយសារចំណុចនេះឯងទើប

ធ្វើឲ្យយើងមានការយល់ច្រឡំ។ អ៊ីចឹងហើយបានយើងខ្ញុំសូមឲ្យមានការបញ្ជាក់ឲ្យបានច្បាស់ពីអង្គជំនុំជម្រះ។ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៤៧:០០]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក៣០នាទី ចាប់ពីពេលនេះទៅរហូតដល់ម៉ោងបីដប់ប្រាំនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅវេលាម៉ោងបីនិងដប់ប្រាំនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៧ នាទី ដល់ម៉ោង ១៥:២៦ នាទី)*

[១៥:២៦:៤៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ជាបន្តនេះសួរថាលោកមេធាវីអន្តរ-ជាតិការពារក្តីលោក អៀង សារី មានសំណួរអ្វីចង់សួរសាក្សីនេះដែរឬទេ?

**លោក ម៉ៃខល កាណាវ៉ាស៖**

អត់មានទេលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ លោកមេធាវី អង្គជំនុំជម្រះសូមអញ្ជើញលោកក្រោកឈរ លោកមេធាវី ម៉ៃខល កាណាវ៉ាស!

[១៥:២៧:៣២]

បាទ ដើម្បីឆ្លើយតបទៅនឹងសំណើសុំរបស់លោក ដែលបានសុំឲ្យអង្គជំនុំជម្រះបញ្ជាក់ឲ្យបាន

កាន់តែច្បាស់លាស់នូវសេចក្តីសម្រេច ពាក់ព័ន្ធនឹងសំណើសុំរបស់មេធាវី អាង ឧត្តម ដែលសុំឱ្យផ្នែកដែលពាក់ព័ន្ធបង្ហាញ បញ្ចាំងនូវឯកសារមួយដែលមានលេខ D232/2.1R អម្បាញ់មិញនេះ ហើយអង្គជំនុំជម្រះបានសម្រេចរួចហើយ។ ប៉ុន្តែលោកមេធាវីបានស្នើសុំថា ឱ្យមានការបញ្ជាក់លើសំអាងហេតុឱ្យកាន់តែច្បាស់លាស់។

ជាការបន្ថែមលើសំអាងហេតុ ដែលយើងបានចេញរួចហើយ គឺអង្គជំនុំជម្រះសំអាងហេតុទៅលើសេចក្តីសម្រេចរបស់ខ្លួន ដែលចេញកាលពីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២ សេចក្តីសម្រេចលើសំណើសុំរបស់ក្រុមមេធាវីការពារក្តី ពាក់ព័ន្ធនឹងភាពមិនប្រក្រតីដែលតាមការចោទប្រកាន់ ថាបានកើតឡើងនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ។ ឯកសារលេខ E221, E223, E224, E224/2, E234, E234/2, E241 និងE241/1 សូមលោកមេធាវីមើលសំអាងហេតុត្រង់កថាខណ្ឌ២២ នៃសេចក្តីសម្រេច។

[១៥:២៩:១៣]

ដោយសារនេះជាសេចក្តីសម្រេចដែលអង្គជំនុំជម្រះបានសម្រេចលើបញ្ហានេះរួចហើយ។ ហេតុដូច្នេះនេះជាការបន្ថែម បញ្ជាក់បន្ថែមលើសំអាងហេតុនៃសេចក្តីសម្រេចដែលអង្គជំនុំជម្រះបានសម្រេចលើបញ្ហានេះនៅក្នុងអំឡុងពេលនៃដំណើរការសវនាការអម្បាញ់មិញនេះ។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ដើម្បីបញ្ជាក់ថាប្រតិចារឹកត្រឹមត្រូវឬក៏អត់នោះ -- បាទ ខ្ញុំបានត្រូវបានប្រាប់ថាឱ្យរង់ចាំមួយភ្លែតសិន។ ដូច្នេះខ្ញុំរង់ចាំ។

[១៥:២៩:៥៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៣០:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ សូមបញ្ជាក់បន្ថែមលោកមេធាវីថា សំអាងហេតុនេះគឺជាចម្លើយតបទៅនឹងសំណើសុំទាំងមូលរបស់លោកមេធាវីការពារក្តី ដែលបានស្នើសុំមុនពេលអង្គជំនុំជម្រះសម្រាកដកថយទៅពិចារណាអម្បាញ់មិញនេះ ហើយនិងសុំឱ្យមានប្រតិចារឹកច្បាស់លាស់ថាដូច្នេះ។

សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់បញ្ជាក់ថាប្រតិចារឹកនេះច្បាស់លាស់សម្រាប់យើងខ្ញុំយល់។ ចំណុចទី១ យើងខ្ញុំសូមបញ្ជាក់ថា យើងបានដាក់ផ្នែកមួយចំនួននៅក្នុងខ្សែអាត់ដើម្បីធ្វើប្រតិចារឹកឡើងវិញ។ ដូច្នេះហើយចំណុចនេះហើយ ដែលលោក អាង ឧត្តម បានលើកឡើង។ ផ្នែកហ្នឹងគឺមិនទាន់បានធ្វើប្រតិចារឹកទេ កាលពីម្សិលមិញ។ ដូច្នេះហើយវាហាក់ដូចជាបង្ហាញថា សហព្រះរាជអាជ្ញាបានបញ្ជាក់ជូនអង្គជំនុំជម្រះតុលាការថា កំណត់ហេតុប្រតិចារឹកនោះគឺថា ការធ្វើប្រតិចារឹកនោះ គឺបានបញ្ចូលនៅក្នុងសំណុំរឿងរួចហើយ។ ចំណុចនេះហើយដែលយើងខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់លាស់។

[១៥:៣១:៤៩]

ហើយមួយទៀត គឺទាក់ទងទៅនឹងសំណើសុំស៊ើបអង្កេត។ ខ្ញុំយល់អំពីសេចក្ដីសម្រេចអង្គជំនុំជម្រះ ក៏ប៉ុន្តែវាគ្រប់គ្រាន់ត្រូវលើកឡើងថា នេះគឺជាបញ្ហាដោយឡែក សាក្សីដោយឡែក សាក្សីនេះបានបញ្ជាក់ថា គាត់បានធ្វើសម្បថ ហើយក៏បានដាក់កំណត់ហេតុនេះនៅចំពោះមុខអង្គជំនុំជម្រះ។ ដើម្បីជាប្រតិចារឹក គ្រប់សាក្សីទាំងអស់ដែលចូលខ្លួននៅចំពោះមុខអង្គជំនុំជម្រះ ប្រសិនបើអ្នកស៊ើបអង្កេតមានការសួរស្ដាប់ចម្លើយមុនពេលថតខ្សែអាត់នោះ ដូច្នេះហើយយើងខ្ញុំត្រូវតែសួរបញ្ជាក់ឲ្យបានច្បាស់លាស់ទៅលើចំណុចនេះ ដើម្បីឲ្យថាយើងច្បាស់ទាំងអស់គ្នាដូចពន្លឺថ្ងៃ អ៊ីចឹងយើងយល់ច្បាស់ទាំងអស់គ្នា។

**ប្រធានអង្គជំនុំ៖**

អរគុណ ប៉ុន្តែសូមលោកគោរព និងអនុវត្តនូវសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះដែលបានសម្រេចរួចហើយ។ មធ្យោបាយតែមួយគត់ដែលលោកមានលទ្ធភាព គឺប្ដឹងសាទុក្ខទៅតុលាការជាន់ខ្ពស់ ដើម្បីពិនិត្យសេចក្ដីសម្រេចនោះឡើងវិញ។ រាល់បញ្ហាដែលលើកឡើងណាផ្ទុយនឹងអ្វីដែលអង្គជំនុំជម្រះសម្រេចរួចហើយ យើងនឹងប្រើប្រាស់សិទ្ធិ ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះក្នុងការកាត់មិនឲ្យលោកតាំងសំណួរ ឬក៏មិនឲ្យសាក្សីណាមួយដែលត្រូវឆ្លើយតបហ្នឹង គឺឆ្លើយតបនឹងសំណួរបែបនេះទេ។

បាទ ជាបន្តអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

[១៥:៣៣:២៧]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គសវនាការ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** សូមជម្រាបសួរលោក អ៊ុង វ៉ែន។ ខ្ញុំមេធាវី គង់ សំអុន ជាមេធាវីជាតិការពារលោក ខៀវ សំផន ហើយតទៅនេះ ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរលោក។ ដំបូងខ្ញុំសុំសួរលោកទាក់ទងទៅនឹងការងាររបស់លោកជាលេខាវរសេនាធំ៨២ បាទលេខ៨២។ ខ្ញុំចង់សួរថា តើលោកបានធ្វើជាលេខាវរសេនាធំលេខ៨២នេះ ចាប់ពីពេលណាមកដែរ?

**លោក អ៊ុង វ៉ែន៖**

**ឆ៖** បាទ ខ្ញុំឆ្លើយថា ពេលដែលខ្ញុំធ្វើវរសេនាធំ៨២នេះ គឺចាប់តាំងពីថ្ងៃ ដូចថាចាត់តាំងកងពល ៨០១ គឺខ្ញុំមានទទួលជាលេខា៨២ ពីពេលនោះឯង។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងមានន័យថា ២សប្តាហ៍ក្រោយ តាមចម្លើយរបស់លោកគឺ១៥ ថ្ងៃក្រោយថ្ងៃរំដោះភ្នំពេញ ថ្ងៃ១៧ មេសា ១៩៧៥ អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** បាទ សូមអរគុណ។ ក្រោយពីលោកទទួលតំណែងជាលេខាវរសេនាធំលេខ៨២ ហើយលោកត្រូវបានគេបញ្ជូនទៅមូលដ្ឋានភ្លាម ឬមួយក៏លោកស្ថិតនៅកន្លែងណា មួយរយៈពេលណាដែរ?

**ឆ៖** បាទ ដូចខ្ញុំបានបញ្ជាក់ហើយ គឺថាកម្លាំងក្នុង៨២ -- វរសេនាធំ៨២នេះ គឺនៅក្នុងចាប់តាំងពីខាងលិចពហុកីឡាដ្ឋាន មកទាល់នឹងពេទ្យលោកសង្ឃ។ ហើយកម្លាំងមួយចំនួននៅម្តុំវត្ត គឺម្តុំ-- ឈ្មោះយាយយ៉ាតទៅចុះ ព្រោះខ្ញុំនឹកឃើញវាមិនឃើញ វត្តពូនភ្នំ បាទ វត្តពូនភ្នំ។

**ស៖** លោកអាចបញ្ជាក់ទីតាំងវត្តពូនភ្នំ វត្តស្ថិតនៅក្នុងសង្កាត់ ឬក៏នៅក្នុងតាមផ្លូវត្រង់ម្តុំណាដែរ លោកអាចបញ្ជាក់បានទេ ទីតាំងពិតប្រាកដ?

[១៥:៣៦:០៧]

**ឆ៖** ទីតាំងពិតប្រាកដនោះ គឺនៅម្តុំពូនភ្នំ គឺមានផ្លូវលំមួយចេញពី-- ខ្ញុំថាចេញពីព្រែកញ្ចៅ មក ៗត្បូង ហើយចាក់ អ៎! មកលិច ចាក់មកត្បូងវិញ បាទ។ ហើយកម្លាំងមួយចំនួនបោះនៅម្តុំហ្នឹងឯង។

**ស៖** បាទ សូមអរគុណ។ រហូតដល់ពេលណា ទើបលោកចាកចេញពីលេខកងវរសេនាធំលេខ ៨២នេះ?

**ឆ៖** ដូចខ្ញុំបានឆ្លើយពីម្សិលហើយ គឺខ្ញុំទៅវ៉ឺនសៃ -- សៀមប៉ាងហ្នឹង អស់រយៈ២ឆ្នាំ។ ហើយតាមពិត គឺខ្ញុំវាចាំត្រង់ថា ពីព្រោះវារដូវច្រូតកាត់ហ្នឹងពីរសា។ ដូច្នេះ ខ្ញុំកំណត់ថាវា២ឆ្នាំ។ ដូច្នេះមកនៅ

ក្នុងកងពល៨០១ ហ្នឹង បានរយៈក៏មករៀន ដូចខ្ញុំបានបញ្ជាក់ពីម្សិលហើយ។

**ស៖** បាទ សូមអរគុណ។ ក្នុងកងពល៨០១ហ្នឹង លោកមានឋានៈជាអ្វីដែរ នៅពេលហ្នឹង?

**ឆ៖** ម្សិលមិញហើយ នៅក្នុងកងពល៨០១ គ្រាន់តែបានជួបគ្នាហើយហ្នឹង ក៏រៀបចំជាកង -- រៀបចំបញ្ចូល ដកខ្ញុំមកពីសៀមប៉ាងមក ហើយនិង កែវ សារឿន មកពីសាលាកងមក គឺគ្រាន់តែខាងលើមកនៅជាមួយខ្ញុំ ហ្នឹង ស៊ូ សារឿន គាត់ថាអ៊ីចឹងឯង។ ហើយខ្ញុំបាន នេះទៀត គឺអត់មានសំបុត្រមានសេចក្ដីបញ្ជាក់ពីណាទេ បាទ គឺថាឲ្យទទួលខុសត្រូវជំនួស ០៦ ហើយខ្ញុំក៏សួរថា ០៦ ទៅណា? គាត់ថា មណ្ឌលគិរីហើយ តែប៉ុននុ៎ង។

[១៥:៣៨:១៥]

**ស៖** លោកអាចបញ្ជាក់បានទេថា ០៦ ហ្នឹង គាត់មានឋានៈជាអ្វីដែរនៅពេលហ្នឹង?

**ឆ៖** បាទ ០៦ ហ្នឹង ខ្ញុំសូមបញ្ជាក់ថា គាត់ហៅថាអនុ១កងពល៨០១។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹង បានន័យថា លោកក្លាយទៅជាអនុកងពល៨០១នោះ ជំនួសអ្នកដែលមានលេខកូដ០៦ នេះ អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ។

**ស៖** លោកធ្វើជាអនុកងពលនោះ រយៈពេលប៉ុន្មានដែរ?

**ឆ៖** ពីព្រោះខ្ញុំជម្រាបពីម្សិលមិញ គឺថាខ្ញុំបាននៅហ្នឹងប្រហែលជាមិនដល់១ខែទេ ក៏ត្រូវហៅមករៀននៅភ្នំពេញនេះឯង ហើយក៏ឈឺគ្រុន នៅដេក មកដេកពេទ្យនៅភ្នំពេញនេះឯង។

[១៥:៣៩:៣២]

**ស៖** បាទ សូមអរគុណ។ មានការណែនាំអ្វីពិសេសពីថ្នាក់លើរបស់លោកទេ នៅពេលហ្នឹង? នៅពេលដែលលោកទៅជំនួស០៦ហ្នឹង?

**ឆ៖** បាទ ដូចខ្ញុំឆ្លើយអម្បាញ់មិញហើយ គឺថាខ្ញុំទៅជំនួស០៦ហ្នឹង មានតែ០៥ទេ ដែលជាអ្នកហៅខ្ញុំពីសៀមប៉ាង ហៅ កែវ សារឿន ពីសាលាកងមកដើម្បីមកជួបថា "ឥឡូវខាងលើឲ្យមិត្តទាំងពីររូបហ្នឹងមកនៅជាមួយខ្ញុំក្នុងនាទីនិងឋានៈដូចខ្ញុំបានជម្រាបពីម្សិលហើយ គឺទទួលខុសត្រូវជំនួស០៦"។ ដូច្នេះឲ្យមានគ្នាក្នុងគណៈហ្នឹងបីនាក់។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមសួរបញ្ជាក់លោកទាក់ទងទៅនឹងចម្លើយរបស់លោកដែលបានឆ្លើយពីម្សិលមិញនៅវេលាម៉ោង១៥:៣១:៣៦ វិនាទី។ ខ្ញុំសូមសង្ខេបថា លោកបានឆ្លើយទាក់ទងទៅនឹង

មន្ទីរសន្តិសុខនៅក្នុងអូរកន្សែង។ លោកបញ្ជាក់ពួកខ្ញុំមានពួពាក្យមួយចុងក្រោយពីព្រឹកមិញនេះ គឺលោកបញ្ជាក់ពាក្យ “អូរកន្សែង” និងពាក្យ “បឹងកន្សែង” តើពាក្យណាពិតប្រាកដ?

[១៥:៤១:១៧]

**ធ៖** ពិតប្រាកដគឺបឹងកន្សែង នេះគឺនៅក្នុងតួអន្លង់ ឯអូរកន្សែងគឺមិនដឹងនៅម្តុំណាទេ ប៉ុន្តែគ្រាន់ថា នៅម្តុំហ្នឹងគឺមានអូរកន្សែង ប៉ុន្តែបឹងកន្សែងក៏មាន។ បឹងកន្សែងមិនមានសន្តិសុខទេមានតែពួកពិការពួកអីនៅ។

**ស៖** បាទ អ៊ីចឹងបញ្ជាក់ឡើងវិញ គឺនៅអូរកន្សែងទើបមានមន្ទីរសន្តិសុខរបស់កងពល អ៊ីចឹងត្រឹមត្រូវទេ?

**ធ៖** បាទ ត្រឹមត្រូវ។

**ស៖** បាទ លោកបានឆ្លើយពីម្សិលមិញតាមពេលវេលាដែលខ្ញុំបានបញ្ជាក់ហ្នឹងថា “លោកអត់បានដឹងពីមន្ទីរសន្តិសុខនេះទេ រហូតទៅដល់អ្នកស្រុកមកផ្តល់ព័ត៌មានជូនលោកអំពីការចាប់កូនរបស់គាត់ជាដើម ទាក់ទងនឹងរឿងលួចដំឡូងដុតហូប”។ លោកអាចបញ្ជាក់បានទេថា ហេតុម៉េចបានជាលោកអត់បានដឹងអំពីមន្ទីរសន្តិសុខនៅអូរកន្សែងនៅពេលនោះ?

**ធ៖** បាទ ដូចខ្ញុំឆ្លើយសំណួរពីមុនហើយគឺតាមពិត ខ្ញុំមកនៅកន្លែងក្នុង -- នៅកងពលនេះទទួលជំនួស០៦នេះ វាមានពេលរយៈខ្លីណាស់ ហើយតាមពិតខ្ញុំមិនដឹងថាកងពលមានសន្តិសុខទេ មានកន្លែងឃុំឃាំងទេ។ ដូច្នេះដល់ត្រឡប់ពីនេះទៅវិញ គឺថាឲ្យខ្ញុំទទួលខុសត្រូវនៅអង្គភាពខ្ញុំចាស់ដដែល ប៉ុន្តែតាមពិតជិះយន្តហោះទៅដល់វ៉ឺនសៃក៏ចាប់ផ្តើមម៉ូតូមួយឌុបយកទៅដាក់នៅត្រពាំងកន្សែងនេះឯង។ នៅបួនប្រាំថ្ងៃ ឬក៏មួយរយៈមកហ្នឹងបានឃើញប្រជាជនមកជួបខ្ញុំនិយាយអំពីកូនចៅរបស់គាត់នេះឯង។ បាទ ដល់សួរគាត់ទៅថាកូនចៅនេះគឺគេចាប់យកទៅដាក់សន្តិសុខអូរកន្សែង។ បាទ សន្តិសុខអូរកន្សែង។

[១៥:៤៣:៣០]

ដូច្នេះខ្ញុំដឹងតាមរយៈប្រជាជនហ្នឹងមួយ។ ប៉ុន្តែទី២ ប្រជាជនដដែលហ្នឹងគឺគាត់និយាយពីបញ្ហាដែលសន្តិ -- មនុស្សដែលសន្តិសុខយកទៅហ្នឹងរត់គាស់គុករត់។ បាទ ហើយវ៉ៃអ្នកយាមហ្នឹងស្លាប់។ ហ្នឹងខ្ញុំដឹងប៉ុណ្ណឹងទេ មុនដែលនេះ។

**ស៖** បាទ សូមអរគុណ។ លោកបានបញ្ជាក់អំពីការជួយអន្តរាគមន៍របស់លោក នាំឲ្យមានការដោះលែងប្រជាជនប្រហែលជា២០នាក់។ ខ្ញុំសូមសួរលោកថា តើការជជែក ស្នើសុំរបស់លោកជាមួយ

នឹងប្រធានកងពលរបស់លោកនៅពេលនោះមានទំនាក់ទំនងអ្វីជាមួយនឹងថ្នាក់លើថែមទៀតទេ មុននឹងការដោះលែង ឬមួយក៏ក្រោយពីលោកនិយាយជាមួយប្រធានកងពលហើយ ក៏បញ្ជាឲ្យមានការដោះលែងភ្លាមៗនៅពេលនោះ?

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ថាក្រោយពីបានដំណឹងនេះហើយ គាត់មកពីសមរភូមិវិញក៏គាត់មក -- ពីព្រោះផ្ទះខ្ញុំហើយនិងបឹងកន្សែងវានៅជាប់គ្នាប្រហែលជាបួនប្រាំម៉ែត្រពីគ្នា ហើយគាត់ក៏ចូល។ ចូលទៅប្រាជ្ញលេងលិចកើត ក៏និយាយពីរឿងបញ្ហាប្រជាជនឲ្យដំណឹងថាកូនចៅគាត់ហ្នឹង ហើយនិងមានអ្នកគាស់គុកគាស់អីហ្នឹង។ ហើយដល់អ៊ីចឹង ក៏ខ្ញុំសុំលើក ខ្ញុំបញ្ជាក់ថា “កូនប្រជាជនប៉ុន្មាននាក់នេះ គឺមិនមានបញ្ហាអីធំដុំទេ មានតែគាស់ដំឡូងដុត លួចទៅ គេចោទថាអ៊ីចេះ ថាអ៊ីចុះ យកឃ្មុំស៊ីទៅ យកស៊ីម្នាក់ឯងទៅ ថាក្បត់សមូហភាព ក្បត់ពីគ្នាឯង ក៏យកគ្នាទៅដែរ”។ ខ្ញុំចង់បញ្ជាក់អ៊ីចឹងគឺថា ដល់អ៊ីចឹងលើកបញ្ហាហ្នឹងឡើង ខ្ញុំថាឥឡូវបើរឿងប៉ុណ្ណឹងយើងដោះស្រាយយ៉ាងម៉េច? ឥឡូវស្នើបងឯងពិចារណាទៅ ហើយយ៉ាងណាគឺបងឯងស្នើទៅលើក៏យ៉ាងម៉េច ក៏តាមជាក់ស្តែង ប៉ុន្តែសំណូមពរពិនិត្យហេតុផលខ្ញុំឃើញតែប៉ុណ្ណឹងទេ អ្នកដែលមកជួបខ្ញុំនោះ។ អើ! គាត់ថា “អើ! ចាំមើលខ្ញុំទៅលើសិន ចាំខ្ញុំទៅដល់កន្លែងសិន”។ បានជាពីរបីថ្ងៃកន្លងមក ឃើញមនុស្សហ្នឹងរួចហើយ មកជួបនៅផ្ទះខ្ញុំហ្នឹងឯងបាទ។ ថា “អូ! អរគុណហើយបានអ៊ំជួយជួបមេកងពល៨០១នេះ”។ ខ្ញុំមានប៉ុណ្ណឹងទេ។

**ស៖** បាទ សូមបញ្ជាក់សាឡើងវិញ តើលោកអាចបញ្ជាក់បានទេថា មេកងពលរបស់លោកហ្នឹងបានស្នើសុំទៅថ្នាក់លើទៀត ឬមួយគាត់សម្រេចដោយខ្លួនឯងនៅពេលនោះ?

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ថា បញ្ហាដែលមតិខ្ញុំស្នើទៅគាត់នេះ ហើយគាត់ថា ឥឡូវទៅដល់កន្លែងសិន ហើយគាត់ក៏មកវ៉ុនសៃមក។ ហើយរយ:២ថ្ងៃ ទៅ៣ថ្ងៃ មិនដឹងជាគាត់បានស្នើមតិយោបល់មកខាងលើ ឬក៏យ៉ាងណា អាហ្នឹងខ្ញុំវាក្តាប់អត់បានទេ។ ប៉ុន្តែគ្រាន់ថា បីបួនប្រាំថ្ងៃមក គឺក្រោយពីគាត់ទៅវ៉ុនសៃពីរបីថ្ងៃក៏ឃើញមនុស្សហ្នឹងគេលែងមកឲ្យទៅផ្ទះវិញ ក៏មកចូលកន្លែងខ្ញុំហ្នឹងឯង។

[១៥:៤៧:០៨]

**ស៖** បាទ សូមអរគុណ។ ចុះលោកដឹងទេថា អ្នកណា អង្គការណាជាស្ថាប័នថ្នាក់លើរបស់កងពលលោក? កងពល ៨០១នោះ?

**ឆ៖** បាទ តាមពិតគឺស្ថាប័នខាងលើ កងពលមានតែមកខាងលើ ដូចខ្ញុំបានជម្រាបមុនៗហើយ មានគណ:តែ៨៧០ហ្នឹងហើយមាន -- ខាងលើកងពល។

**ស៖** ចុះទាក់ទងទៅនឹងសេនាធិការរបស់ខាងកងទ័ពវិញ ខាង សុន សេន វិញតើជាថ្នាក់លើរបស់កងពលលោកទេ?

**ឆ៖** បាទ បញ្ហាថ្នាក់លើ គឺថា សុន សេន ក៏ជាថ្នាក់លើ, ប៉ុល ពត ក៏ជាថ្នាក់លើ ហើយក្រៅពីនោះមកគឺ ដូចខ្ញុំបានបញ្ជាក់អ៊ីចឹងថាពេលរាយការណ៍បញ្ហានយោបាយ ឬក៏ខាងយោធាអី គឺមានតែពីរនាក់ហ្នឹង ដែលជាអ្នកដើរតួ ហើយឃើញថា ០៥ ក៏រាយការណ៍ឲ្យ ជួនកាលគាត់ថា "អ៊ំ" ជួនកាលគាត់រាយការណ៍មកឲ្យកន្លែង សុន សេន ហើយក្រៅពីនោះគឺមិនដែលរាយការណ៍អីលើបុគ្គលណាអី អត់មានដែលឃើញទេ។ ដូច្នេះ ក៏កំណត់ថា អង្គការខាងលើកងពលគឺមាន សុន សេន, មាន ប៉ុល ពត មានអី ទាំងអស់នេះហើយ ដូចខ្ញុំបានជម្រាបពីខាងមុនអ៊ីចឹង។

[១៥:៤៨:៥៣]

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ឲ្យច្បាស់បន្តិចមើល៍ បន្ទាប់ពីកងពលទៅ អ្នកណាអ្នកគ្រប់គ្រងកងពល? ហើយពីលើស្ថាប័នដែលគ្រប់គ្រងកងពលនោះមានស្ថាប័នណាទៀត បើសិនជាលោកអាចបញ្ជាក់បានសូមលោកជួយបញ្ជាក់ពីឋានានុក្រមបាទ។

**ឆ៖** ខ្ញុំថាបញ្ហាគ្រប់គ្រងកងពល គឺមាន ទី១គឺខាងផ្នែកយោធាមាន សុន សេន។ សុន សេន ហ្នឹងហើយជាអ្នកគ្រប់គ្រងកងពលទាំងអស់។ ឯពីលើ សុន សេន ហ្នឹង ខ្ញុំថាគ្មាននរណាក្រៅពី ប៉ុល ពត ទេ ដែលគ្រប់គ្រង សុន សេន ហ្នឹងក្នុងរចនាសម្ព័ន្ធ តាមខ្ញុំមើលគឺអ៊ីចឹងឯង។

**ស៖** បាទ សូមអរគុណ។ លោក អ៊ឹង រ៉ែន ខ្ញុំអត់មានសំណួរអីទៀតទេ។

**លោក គង់ សំអុន៖**

សូមអរគុណ លោកប្រធាន តែសហមេធាវីរបស់ខ្ញុំមានសំណួរពីរបីសំណួរទៀតបាទ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញបាទ!

[១៥:៥០:០១]

**លោក អាកឡូវ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក អាកឡូវ វែកគែន៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ អាកឡូវ វែកគែន ជាមេធាវីអន្តរជាតិរបស់លោក ខៀវ

សំផន។ សំណួរទី១របស់ខ្ញុំគឺថា តើដណ្តើមបានភ្នំពេញនេះ លោកត្រូវរបួសពេលដែលមុនចូលភ្នំពេញនេះរយៈពេលប៉ុន្មានដែរ?

**លោក អ៊ុង វ៉ែន៖**

**ឆ៖** ខ្ញុំត្រូវរបួសនេះ គឺថ្ងៃដែលដាច់ភ្នំពេញហ្នឹងតែម្តង។

**ស៖** ហើយលោករបួសរបៀបម៉េចដែរ? ប្រភេទរបួសធំ ហើយតូច?

**ឆ៖** បាទ ពេលរបួសហ្នឹង គឺរបួសត្រង់ថា របួសយើងដើរបានអីបាន ប៉ុន្តែគ្រាន់តែខ្ញុំរបួសហើយក៏ ចូលដល់ -- មុនរបួសហ្នឹងចូលដល់ផ្ទះពោធិ៍ចិនតុងហ្នឹង គឺដល់ត្រូវរបួស ខ្ញុំត្រូវរបួសនៅវត្តតាំងកសាង ហើយបានកម្លាំងចូលទៅ--

**ស៖** លោកសាក្សី ខ្ញុំសូមកាត់លោក។ ខ្ញុំយល់ ខ្ញុំ -- សំណួរដែលខ្ញុំសួរលោកនោះ ថាតើលោករបួសរបៀបម៉េច? លោកត្រូវគ្រាប់ ឬក៏លោកដើរទៅថ្កោះជើង ឬក៏យ៉ាងម៉េច? សូមលោករៀបរាប់ប្រាប់ខ្ញុំបាទ។

**ឆ៖** បាទ ត្រូវរបួសហ្នឹងមិនមែនគ្រេចជើងគ្រេចដៃទេ គឺត្រូវគ្រាប់។

**ស៖** បាទ ត្រូវគ្រាប់កន្លែងណាទៅលោក?

**ឆ៖** នេះ កន្លែងភ្លៅនេះ។

[១៥:៥២:០៩]

**ស៖** ហើយក្រោយពីរបួសមកនោះ រយៈពេលប៉ុន្មានក្រោយពេលរបួសហ្នឹង ដែលលោក -- ដែលគេជូនលោកទៅមន្ទីរពេទ្យនោះ? ថ្ងៃដែលហ្នឹងតែម្តង ឬក៏ក្រោយមកច្រើនថ្ងៃហើយបានគេជូនលោកមកមន្ទីរពេទ្យ?

**ឆ៖** របួសភ្លាម គឺត្រូវទៅៗពេទ្យភ្លាមតែម្តង អត់មានចាំស្អែកទេ។ ព្រោះវត្តតាំងកសាងហើយនិងនេះហ្នឹងជាប់គ្នាហ្នឹងឯង ហៅថាពេទ្យធុនស្រាល សមរភូមិមុខ មិនមែនទៅពេទ្យបង្អែកឆ្ងាយទេ។

**ស៖** ហើយនៅក្នុងមន្ទីរពេទ្យចល័តលោកហ្នឹង តើលោកស្នាក់នៅរយៈពេលប៉ុន្មានដែរ?

**ឆ៖** ខ្ញុំស្នាក់នៅប្រហែលជា ១៧ថ្ងៃនៅម្តុំពូនភ្នំហ្នឹង។ តែកម្លាំងខ្ញុំចូលនៅនុំង ហើយកម្លាំងនៅចាំខាងក្រៅនៅកន្លែងពូនភ្នំដែល។ ដូច្នេះខ្ញុំនៅតែនុំង។

**ស៖** ហើយគេបញ្ជូនទៅណាដែរ?

[១៥:៥៣:៥០]

**ឆ៖** ហើយខ្ញុំនៅនោះគឺ មិនទាន់ថាបញ្ជូនទៅណាទេ ប៉ុន្តែរងរបស់ខ្ញុំគឺគាត់មកបានជួបខ្ញុំ ថាឥឡូវខាងលើមានផែនការ ទី១ បន្តិចទៀតនេះនឹងរៀបចំកង រំលាយកង១៤នេះ ចូលទៅក្នុង៨០១។ ហ្នឹងខាងគាត់មកជួបខ្ញុំនៅកន្លែងខ្ញុំសម្រាក។ ទី២ ត្រូវរៀបចំសតិអារម្មណ៍នយោបាយ គឺទៅរតនគិរី។ ហ្នឹងឯង។

**ស៖** បន្ទាប់ពីសម្រាកនៅពេទ្យ១៧ថ្ងៃហើយ លោកធ្វើអ្វីនៅពេលដែលលោក -- ក្រោយពេលដែលលោកចេញពីមន្ទីរចល័តហើយនោះ តើលោកទៅធ្វើអី?

**ឆ៖** ក្រោយពីចេញពីពេទ្យអង្គភាពខ្ញុំហើយ គឺខ្ញុំមកជួបគ្នានៅភ្នំពេញនេះ គឺពិគ្រោះគ្នារឿងបញ្ហា។ ខ្ញុំឆ្ងល់ថា យើងទើបតែដាច់ភ្នំពេញ ឥឡូវទៅឯងណាទៀត? គេថាឲ្យអង្គភាពកងពលនេះទៅកន្លែងវៀសាន គេមិនប្រើរតនគិរី គេថាវៀសាន។ ប៉ុន្តែពេលនោះគឺមិនទាន់រៀបចំជាបញ្ចូលគ្នានៅឡើយទេ ប៉ុន្តែនៅក្នុងពួកកងពល១៤នៅឡើយទេ។ គ្រាន់តែបង្អើបឲ្យដឹងថា ត្រៀម ហើយនិងទៅមុខ។ តែប៉ុណ្ណឹង។

**ស៖** ហើយកាលពិភាក្សាដំបូងៗដែលលោកធ្វើជាមួយនឹងអនុប្រធានរបស់លោក ហើយនិងអ្នកផ្សេងទៀតទាក់ទងទៅនឹងការបង្កើតកងពល៨០១ តើលោកពិភាក្សាជាមួយគាត់ហ្នឹងតាំងពីពេលដែលលោកនៅក្នុងមន្ទីរពេទ្យ ឬក៏លោកពិភាក្សាក្រោយពេលដែលចេញពីមន្ទីរពេទ្យហើយដែរទេ?

**ឆ៖** ពិភាក្សានៅក្នុងនេះ ខ្ញុំរបួសនៅម្ដុំវត្តពូនភ្នំនេះឯង។

[១៥:៥៦:៣៧]

**ស៖** បាទ ខ្ញុំហើយថា ខ្ញុំចង់ដឹងថាតើនៅពេលដែលលោកនៅស្នាក់នៅមន្ទីរពេទ្យនៅឡើយ ឬក៏នៅពេលដែលលោកចេញពីមន្ទីរពេទ្យហើយ ដែលលោកពិភាក្សាអំពីការបង្កើតកងពល៨០១នេះ?

**ឆ៖** ដូចខ្ញុំថាហើយនិងជម្រាបអ៊ីចឹង គឺថា គ្រាន់តែព្រាង ហើយគ្រាន់តែក្នុងរងខ្ញុំបញ្ជាក់ទេ គឺថារៀបចំបញ្ចូលគ្នាហើយ។ មិនដឹងពីណាទៅណា នៅក្នុងអង្គភាពណា ពីណានៅក្នុងអង្គភាពណាទេ? អាហ្នឹងគាត់បញ្ជាក់នៅពូនភ្នំ អាហ្នឹងមិនទាន់ប្រកាសនៅឡើយទេ។

**ស៖** លោកស្ដាប់សំណួរខ្ញុំឲ្យច្បាស់ ខ្ញុំសួរលោកថា នៅពេលដែលលោកពិភាក្សាជាមួយនឹងអនុប្រធានរបស់លោកអំពីគម្រោងបញ្ចូលកងកម្លាំងទៅក្នុងកងពល៨០១នេះ តើពេលនុ៎ងលោកនៅមន្ទីរពេទ្យនៅឡើយ ឬក៏លោកបានចេញពីមន្ទីរពេទ្យហើយ ដើម្បីទៅជួបកងម្លាំងរបស់លោក។ អ៊ីចឹងខ្ញុំគ្រាន់តែសួរលោកថា តើនៅពេលដែលពិភាក្សាហ្នឹង លោកនៅមន្ទីរពេទ្យ ឬក៏លោកចេញពីមន្ទីរពេទ្យហើយ?

**ឆ៖** បាទ ពេលដែលដំណឹងនេះ គឺថាមានរងខ្ញុំគាត់នៅភ្នំពេញហ្នឹងហើយ។ បានជួបជាមួយកងពលហើយបានគាត់ទៅជម្រាបខ្ញុំនៅកន្លែងពេទ្យ។

[១៥:៥៨:២២]

**សៈ** បាទសូមអរគុណ។ ហើយបន្ទាប់មកទៀតនៅពេលដែលអ្នកស៊ើបអង្កេតនៃតុលាការយើងនេះទៅសម្ភាស ហើយនិងនៅក្នុងអង្គជំនុំជម្រះនេះដែរ។ លោកបាននិយាយអំពីការប្រជុំនៅស្តាតអូឡាំពិក ដើម្បីនិយាយអំពីការបង្កើតកងពល៨០១នេះ។ ហើយសំណួរខ្ញុំដូចតទៅនេះ នៅពេលដែលលោកចូលប្រជុំ ឬក៏សន្និបាតនៅស្តាតអូឡាំពិកនេះ ទាក់ទងទៅនឹងការបង្កើតកងពល៨០១នេះ តើពេលនុ៎ងលោកចេញពីមន្ទីរពេទ្យហើយ មែនទេ?

**ឆ៖** បាទ ខ្ញុំចេញពីមន្ទីរពេទ្យហើយ។

**សៈ** តាមលោកចាំនោះ តើការប្រជុំនៅស្តាតអូឡាំពិកនោះ តើកើត ប្រព្រឹត្តទៅក្រោយពេលដែលលោកចេញពីមន្ទីរភ្លាម ឬក៏យូរមកហើយដែរទេ? តើលោកអាចផ្តល់ ធ្វើការប៉ាន់ស្មានបានទេ បើធៀបទៅនឹងការប្រជុំនៅស្តាតអូឡាពិកនេះ តើលោកចេញពីពេទ្យយូរហើយ ឬក៏ទើបតែនឹងចេញទេ?

**ឆ៖** បាទ គឺខ្ញុំជម្រាបដែរថា ពេទ្យគឺនៅ ដូចខ្ញុំជម្រាបអ៊ីចឹង។ ដូច្នេះ បញ្ហារៀបចំកងពលនេះ គឺអត់បាច់ចេញពីពេទ្យទេ គឺនៅហ្នឹងដដែលទេ ដល់ពេលវេលាគឺមកៗតែម្តង។ ពីព្រោះខ្ញុំជម្រាបហើយថា ក្នុងវរសេនាធំនេះ បើមានមួយនៅក្នុងភ្នំពេញ មានមួយនៅប្រចាំការនៅខាងក្រៅ។ ដូច្នេះ ខ្ញុំបានបញ្ជាក់ពីម្សិលហើយ ដូច្នេះ ត្រូវនឹងខ្ញុំរបួសនៅនោះផង ដូច្នេះ ខ្ញុំអត់ទៅទេ។ ប៉ុន្តែការងារពីកងពល ឬពីអីមក គឺមានអនុរបស់ខ្ញុំ គឺជាអ្នកទទួលខុសត្រូវហើយ មកប្រាប់ខ្ញុំថា ឥឡូវចេះៗអី។ ខ្ញុំបានបញ្ជាក់ពីម្សិលមិញអ៊ីចឹង។

**សៈ** ហើយថ្ងៃដែលលោកទៅស្តាតអូឡាំពិកដើម្បីចូលប្រជុំ ឬសន្និបាតហ្នឹង អ៊ីចឹងបានន័យថាពេលហ្នឹង លោកស្នាក់នៅមន្ទីរពេទ្យនៅឡើយទេ មែនទេ?

[១៦:០១:១៨]

**ឆ៖** ដូចដែលខ្ញុំជម្រាបអ៊ីចឹង ប៉ុន្តែដូចថា ស្តាប់មិនបាន។ ខ្ញុំចង់និយាយថា ក្នុងអង្គភាពខ្ញុំមួយហ្នឹង មានមេមួយ វរសេនាធំមួយនៅក្នុងភ្នំពេញ ហើយមេវរសេនាធំមួយ មានខ្ញុំនៅរបួសនៅខាក្រៅ បាទ នៅខាងក្រៅ។ ដូច្នេះ គឺអ្នកទាំងពីរហ្នឹង មានការពិគ្រោះគ្នា មានការជួបគ្នា តាមតែអូអីផ្សេងៗ គឺតាមរយៈតេអូ ឬក៏មកជួបផ្ទាល់តែម្តង ដើម្បីដោះស្រាយបញ្ហាអីដែលចាំបាច់ បាទ។ ដូច្នេះ មិនបាច់មក

ភ្នំពេញ បើថាមកលេងមួយភ្លែតអី ក៏ទៅវិញទៅ ហើយមានបញ្ហាអីគឺមានមេមួយនៅហ្នឹង។ ដូច្នេះអត់មានចេញពេទ្យទេ គឺសឹងទេគឺនៅក្នុងអង្គភាពហ្នឹង បើខាងលើត្រូវការរៀបចំម៉េចៗតម្រូវការឲ្យខ្ញុំមកប្រជុំមកអី គឺខ្ញុំមកបាន បាទ។ ព្រោះពេលនោះ មានមធ្យោបាយហើយ មានម៉ូតូអីខ្លះហើយ។ ដូច្នេះនៅនោះផង ដេកនៅនោះផង ចាក់ថ្នាំនោះផង ហើយការងារក៏នៅនោះ។ មានបញ្ហាអី គឺដោះស្រាយបានទាំងខាងក្រៅទាំងខាងក្នុង។

**លោក អាកទួរ វែកគែន៖**

លោកប្រធាន ខ្ញុំគិតថាប្រហែលខ្ញុំមិនអាចសួរចប់ទេ តាមមើលទៅ។

**ប្រធានអង្គជំនុំ៖**

លោកត្រូវការពេលវេលាទំនងប្រហែលប៉ុន្មានទៀត?

**លោក អាកទួរ វែកគែន៖**

លោកប្រធាន ខ្ញុំគិតថា ប្រហែលយ៉ាងយូរបំផុត៤០នាទី ប្រហែលជាអាចតិចជាងហ្នឹង។ ខ្ញុំសង្ឃឹមថានឹងចំណាយតិចជាងហ្នឹងលោកប្រធាន។ ដោយសារយល់ឃើញថា សួរគ្នាទៅ ដូចវាមិនសូវយល់គ្នា។ ខ្ញុំមិនដឹងថា ស៊ីពេលប៉ុន្មានទេ ឲ្យជាក់ច្បាស់លាស់តែម្តងនោះ។

[១៦:០៣:៥០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:០៤:៤៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកសាក្សី លោក អ៊ុង រ៉ែន ហើយឥឡូវនេះដល់ដំណើរការសវនាការថ្ងៃនេះដល់ពេលត្រូវសម្រាកហើយ ហើយអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ ហើយសវនាការលើកបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃសុក្រទី១១ ខែមករា ឆ្នាំ២០១៣ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយថ្ងៃស្អែកនេះគឺអង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សីលោក អ៊ុង រ៉ែន បញ្ចប់ ហើយនិងផ្តើមសក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-100 ដែលនឹងផ្តើមសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញាមុនភាគីដទៃទៀតនៃរឿងក្តី សូមភាគី និងសាធារណជនជ្រាប។

លោក អ៊ុង រ៉ែន ការស្តាប់សក្ខីកម្មរបស់លោកនៅពេលនេះនៅមិនទាន់ចប់នៅឡើយទេ ហើយ

អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មលោកនៅថ្ងៃស្អែកទៀត។ ដូច្នេះអង្គជំនុំជម្រះសូមកោះអញ្ជើញលោកមកបន្តផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។

[១៦:០៥:៥៩]

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:០៧:៤៩]

**ប្រធានអង្គជំនុំ៖**

បាទ នេះគឺបន្តទៅថ្ងៃស្អែកទៀត ហើយអង្គជំនុំជម្រះសូមអញ្ជើញលោកមកផ្ដល់ បន្តផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀត។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សីនិងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះវិលត្រឡប់ទៅកាន់ទីលំនៅ អ៎! ទីកន្លែងដែលគាត់ស្នាក់នៅ ហើយនិងឲ្យអញ្ជើញគាត់ឲ្យត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែកនៅវេលាម៉ោងប្រាំបួន។

ហើយទន្ទឹមនឹងនេះអង្គជំនុំជម្រះក៏សូមជម្រាបជូនដំណឹងផងដែរថានៅថ្ងៃស្អែកនេះអង្គជំនុំជម្រះនឹងពិភាក្សាលើបញ្ហាមួយទៀត ដែលពាក់ព័ន្ធជាមួយនឹងសំណើរបស់ខាងមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-94 សូមឲ្យភាគីជ្រាប។

ហើយអង្គជំនុំជម្រះក៏នឹងពិភាក្សា ហើយនិងធ្វើលិខិតជូនភាគីជ្រាបលើបញ្ហានេះ អំពីពាក់ព័ន្ធទៅនឹងបញ្ហាការស្ដាប់ ឬមិនស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-94នេះ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបញ្ជាក់ដល់អ្នកស្ដាប់ជាភាសាអង់គ្លេស។ យើងដោយសារមិនមានពេលវេលាទំនាក់ទំនងនៅឡើយនោះ ដូច្នេះយើងខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ថាកម្មវត្ថុដែលយើងត្រូវយកមកពិភាក្សាទាក់ទងទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណី TCCP-94 នៅថ្ងៃស្អែកតាមសំណើសុំនេះ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែកឲ្យបាន

មុនម៉ោងប្រាំបួន។ ហើយដោយឡែកលោក អៀង សារី ឲ្យនាំខ្លួនមកនៅត្រឹមបន្ទប់ឃុំខ្លួនខាងក្រោម ដែលមានរៀបចំនូវឧបករណ៍សោតទស្សន៍ សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការ សវនាការពីចម្ងាយ។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:១០ នាទី)*